ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




◆ តួនាទីរបស់អាស៊ាននៅក្នុងសាលាក្ដីខ្មែរក្រហម

◆ យុត្តិធម៌សម្រាប់ខ្មែរកម្ពុជាក្រោម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២៦ ខែមិថុនា ឆ្នាំ២០១០

លេខ១២៦ ខែមិថុនា ឆ្នាំ២០១០

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆គួនាទីរបស់អាស៊ាននៅក្នុងសាលាក្តីខ្មែរក្រហម ....................................១

**ផ្នែកឯកសារ**

◆មិនបំភ្លេចនូវពាក្យបណ្តាំរបស់ឪពុក .................................................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆អតីតអ្នកយាមនៅមន្ទីរស-២១ ....................................................៨

◆រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ .......................................១០

◆អំពើល្អរបស់ខ្មែរក្រហម...........................................................១២

◆ការពិតដែលលាក់ទុកអស់រយៈពេល៣១ឆ្នាំ ....................................១៤

◆ពិព័រណ៍សំណុំរឿង០០២ ..........................................................១៦

◆កែវ សុខា : រូបរស់ជីវិតដោយសារលាក់បាំងប្រវត្តិរូប .....................១៨

**ផ្នែកច្បាប់**

◆យុត្តិធម៌សម្រាប់ខ្មែរកម្ពុជាក្រោម..............................................២១

◆ចំណងរវាងចៅហ្វាយ-កូនចៅ.....................................................២៣

◆ការបង្ហាញពីគោលបំណងនៃអំពើប្រល័យពូជសាសន៍.........................៣២

◆សេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល .........................................៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆យុត្តិធម៌អន្តរកាលដែលស្រពេចស្រពិល ....................................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ជីវិតគ្រួសារខ្ញុំក្នុងរបបខ្មែរក្រហម ...........................................៥៨

◆ការអត់ឱនទោសជាការពិបាកណាស់សម្រាប់ វក ទី.....................៦០




### ស្លាកនៅក្របមុខ

*ចំណារមួយផ្ទាំងនេះសរសេរឡើងដើម្បីរំឭកដល់ដំណើររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក អាន់ឌ្រូ ធី ខេឡី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមកកាន់ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១០ ។ សូមឲ្យអ្នកដែលបានអានសំណេរមួយផ្ទាំងនេះនៅពេលខាងមុខ ចងចាំការឈឺចាប់ និងសោកនាដកម្មទាំងឡាយដែលបានកើតមានឡើងចំពោះប្រជាជនខ្មែរកម្ពុជាក្រោម ក្នុងរយៈកាលនៃរបបខ្មែរក្រហមដើម្បីកុំឲ្យអំពើបែបនេះកើតមានឡើងសាជាថ្មីម្តងទៀត ។*




**ពិធីចែកសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ នៅវិទ្យាល័យអន្លង់វែង ក្រោមអធិបតីភាពលោកជំទាវ ទន់ សារ៉ុម**


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ :*** *សុខ វណ្ណៈ, ឆាយ ឈុនលី, ស សេងគា, ចន ឆរធីអារី, ចន មាំងហ្គី, រ៉ែអ៊ិន អ៊ី.ផាក, ប៉ែត វ៉ាន់ស្កាត់, ខាល ដែលបឹក, ញិល សល្យ, អេង កុកថាយ* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *តាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា* ***អ្នកបកប្រែ:*** *ជា ផល្លា, ទេស ម៉ារ៉ែម* ***និពន្ធនាយកទូទៅ:*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយកៈ*** *ញាណ សុជាតិ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្រ្ត* ***គ្រប់គ្រងការចែកផ្សាយៈ*** *ម៉ម សុជាត*

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# តួនាទីរបស់អាស៊ាននៅក្នុងសាលាក្ដីខ្មែរក្រហម

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន់ គីមូន បានកោតសរសើរទៅលើកិច្ចខំប្រឹងប្រែងរបស់សាលាក្ដីខ្មែរក្រហម ព្រមទាំងបញ្ជាក់ម្ដងទៀតទៅលើសារសំខាន់របស់សាលាក្ដីសម្រាប់សហគមន៍អន្តរជាតិនិងកម្ពុជា ។ សាលាក្ដីមានសារសំខាន់សម្រាប់ផ្លូវដ៏វែងឆ្ងាយរបស់កម្ពុជាដើម្បីងើបចេញពីសង្គ្រាមស៊ីវិល និងអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងជាច្រើនឆ្នាំ ។ សាលាក្ដីក៏សន្យាថានឹងបញ្ឈប់ករណីនិទ្ទណ្ឌភាពដែលបានកើតឡើងជាងមួយភាគបួននៃសតវត្សរ៍(២៥ឆ្នាំ) ដែរ នោះគឺអំពើដ៏សាហាវឃោរឃៅរបស់ខ្មែរក្រហមពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ដែលបានសម្លាប់ជីវិតមនុស្សជាងពីរលាននាក់ និងផ្លាស់ប្ដូរទីលំនៅរបស់ប្រជាជនស្ទើរតែទាំងអស់ ។

ប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌ដ៏អត់ធ្មត់ ដូច្នេះអ្នកទាំងនេះមិនគួរត្រូវបានគេបដិសេធមិនផ្ដល់យុត្តិធម៌យូរជាងនេះទៀតទេ ។ ដូចដែលសមាជិកអាស៊ានបានដឹងថ្មីៗនេះ សាលាក្ដីកំពុងខ្វះខាតថវិកាសម្រាប់ធ្វើការកាត់សេចក្ដី ។ ការបញ្ចប់ភ្លាមៗរបស់សាលាក្ដីដែលបណ្ដាលមកពីថវិការមិនគ្រប់គ្រាន់នឹងក្លាយទៅជាមហន្តរាយមួយនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ហើយវាក៏ជាភាពអាម៉ាស់មួយសម្រាប់ការប្ដេជ្ញាចិត្តការពារសិទ្ធិមនុស្សរបស់សហគមន៍អន្តរជាតិដែរ ។


អគ្គលេខាធិការអង្គសហប្រជាតិ បាន់ គីមូន

បន្ទាប់ពីមន្ត្រី និងបុគ្គលិកចាប់ផ្ដើមធ្វើការនៅឆ្នាំ២០០៦ សាលាក្ដីបានធ្វើការបញ្ចប់សំណុំរឿងទីមួយដែលមានជាប់ពាក់ព័ន្ធនឹង ឌុច អតីតប្រធានគុកស-២១ នៅខែវិច្ឆិកា ឆ្នាំ២០០៩ (មានការរំពឹងទុកថានឹងមានការប្រកាសសាលក្រមនៅថ្ងៃទី២៦ ខែកក្កដា ខាងមុខនេះ) ហើយបច្ចុប្បន្នសាលាក្ដីកំពុងតែធ្វើការទៅលើសំណុំរឿង០០២ដែលមានជាប់ពាក់ព័ន្ធនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបួននាក់ដែលនៅរស់រានមានជីវិតគឺ : នួន ជា, ខៀវ សំផន, អៀង សារី, និង អៀង ធីរិទ្ធ ។ នៅអំឡុងពេលប្រតិបត្តិការរយៈពេល៣ឆ្នាំ សាលាក្ដីបានដោះស្រាយបញ្ហាធ្ងន់ធ្ងរជាច្រើន ហើយក៏បានបង្កើនការផ្សព្វផ្សាយដល់អ្នកនៅរស់ពីរបបខ្មែរក្រហមដែលបានផ្ដល់ឱកាសដល់ប្រជាជនកម្ពុជាជាច្រើនពាន់នាក់ឲ្យបានចូលរួមក្នុងសវនាការកាត់សេចក្ដី ឌុច ដោយផ្ទាល់ ។ មានការរំពឹងទុកថានឹងមានប្រជាជនកម្ពុជាច្រើនជាងនេះចូលរួមក្នុងសំណុំរឿង ០០២ ដែលមានចុងចោទដ៏សំខាន់ទាំងបួន ។ ជាងនេះទៅទៀត ការកាត់សេចក្ដីអតីតមេដឹកនាំខ្មែរក្រហមបានជំរុញឲ្យមានការពិភាក្សានៅទូទាំងប្រទេសពីអំពើដ៏សាហាវព្រៃផ្សៃនៅក្នុងរបបនោះនិងបន្ទាប់មកធ្វើឲ្យមានការទម្លាយភាពស្ងប់ស្ងាត់ដ៏យូរឈឺចាប់របស់អ្នកនៅរស់ជាច្រើនលាននាក់ ។ ឯកឧត្ដម ចាន់ តានី រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រីបាននិយាយនៅក្នុងសន្និសីទកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ថា នៅកម្រិតសកល សាលាក្ដីអាចដើរតួនាទីជាគំរូដ៏មានប្រសិទ្ធភាពសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតដោយសារតែការចំណាយតិច ប៉ុន្តែដំណើរការទៅមុខលឿននិងការផ្សព្វផ្សាយដល់ជនរងគ្រោះរបស់សាលាក្ដី ។ ដូច្នេះ សាលាក្ដីចាំបាច់ត្រូវតែមានថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការដ៏មានតម្លៃរបស់ខ្លួន ។

អាស្រ័យហេតុនេះ ខ្ញុំ(ឆាំង យុ) សូមធ្វើការសំណូមពរឲ្យរដ្ឋដែលជាសមាជិកអាស៊ានធ្វើការឆ្លើយតបនឹងការប្រកាសសុំជំនួយរបស់លោក បាន់ គីមូន ដល់សាលាក្តីនិងស្នើឲ្យមានការផ្តល់ជំនួយជាមធ្យោបាយផ្សេងៗ ។ ក្នុងនាមជាប្រទេសដែលជាសមាជិកអាស៊ានកម្ពុជាសង្ឃឹមថាប្រទេសផ្សេងទៀតដែលជាសមាជិកនឹងបង្ហាញពីការគាំទ្ររបស់ខ្លួនចំពោះសិទ្ធិមនុស្សនៅក្នុងតំបន់និងពិភពលោកដោយផ្តល់ជាជំនួយដ៏ចាំបាច់ដល់សាលាក្តីខ្មែរក្រហម ។ មកដល់ពេលបច្ចុប្បន្នមិនមានសមាជិកណាធ្លាប់បានផ្តល់បែបនេះឡើយ ។

យោងទៅតាមស្ថានភាពសេដ្ឋកិច្ចដ៏លំបាកដែលប្រទេសជាច្រើនប្រហែលជាកំពុងតែជួបប្រទះនៅពេលបច្ចុប្បន្ន ជំនួយសម្រាប់តុលាការមិនចាំបាច់ត្រូវតែជាថវិកាទេ ។ សមាជិកអាស៊ានអាចជួយដល់តុលាការតាមរយៈ ១) ផ្តល់ជាជំនួយបច្ចេកទេស ២)ផ្តល់ឯកសារដែលទាក់ទងនឹងខ្មែរក្រហម ៣)ផ្តល់ឬបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សាផ្លូវចិត្តកម្ពុជាចំនួន៣០នាក់ ។ ៤) ផ្តល់សម្ភារៈសំខាន់ដូចជា កុំព្យូទ័រ (សម្រាប់បណ្តុះបណ្តាលបុគ្គលិកសាលាក្តី) វិទ្យុ (ដើម្បីជួយផ្សព្វផ្សាយព័ត៌មាន) និង៥) បញ្ជូនអ្នកស្ម័គ្រចិត្តដើម្បីមកបណ្តុះបណ្តាលប្រជាជនកម្ពុជាអំពីការអភិវឌ្ឍនិងដំណើរការនីតិវិធីរបស់តុលាការ ។

ដើម្បីយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ ការផ្សះផ្សាជាតិ ការពង្រឹងចំណងមិត្តភាពរវាងសមាជិកអាស៊ាន និងការគាំទ្រសិទ្ធិមនុស្សអន្តរជាតិ សមាជិកអាស៊ានគួរតែជួយឧបត្ថម្ភដល់ប្រទេសជិតខាងដើម្បីកសាងឡើងវិញនូវសង្គមដ៏មានយុត្តិធម៌និងរឹងមាំជាងមុន ។ **ឆាំង យុ**

# ដំណឹងស្វែងរកគ្រួសារ

នាងខ្ញុំឈ្មោះ អ៊ីង ម៉ីហា អាយុ៣៩ឆ្នាំ មានបងប្អូន៣នាក់ ទី១) បងប្រុស អ៊ីង សេងសាំង «ស្លាប់» ទី២) នាងខ្ញុំ និងទី៣) ប្អូនប្រុសឈ្មោះ អ៊ីង ម៉ីហុង សព្វថ្ងៃមានអាយុប្រហែល៣៧ឆ្នាំ ។ ឪពុកឈ្មោះ អ៊ីង សេង ជាមន្ត្រីសង្គមកិច្ច និងម្តាយមិនចាំឈ្មោះ ។ នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំមានសមាជិក៦នាក់ត្រូវបានជម្លៀសទៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដោយសារតែហូបចុកមិនគ្រប់គ្រាន់ ក្រោយមកឪពុកអ្នកម្តាយនិងយាយរបស់ខ្ញុំក៏បានស្លាប់នៅជំនាន់នោះទៅ ។ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ខ្ញុំនិងប្អូនប្រុសរបស់ខ្ញុំបានភៀសខ្លួនទៅរស់នៅព្រំដែនថៃ រួចក៏វិលត្រឡប់មករស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ នៅឆ្នាំ១៩៨៣ ខ្ញុំបានធ្វើដំណើរទៅក្រុងភ្នំពេញតែម្នាក់ឯង ដោយទុកប្អូនប្រុស អ៊ីង ម៉ីហុង ដែលទើបតែមានអាយុ១០ឆ្នាំឲ្យនៅជាមួយមីងឈ្មោះ ភាព ។ ចាប់ពីពេលនោះមក ខ្ញុំបានបែកពីប្អូនប្រុស អ៊ីង ម៉ីហុង រហូតមកដល់សព្វថ្ងៃ ។ តាមរយៈការស៊ើបសួរដំណឹងពីអ្នកភូមិដែលធ្លាប់រស់នៅជាមួយគ្នាបានប្រាប់ថា ពួកគាត់ក៏មិនដឹងថា អ៊ីង ម៉ីហុង រស់នៅទីណាដែរ ។

ដូច្នេះ បើសិនបងប្អូនបានស្គាល់ឬបានជួបឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំតាមអាសយដ្ឋាននៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌស្ទឹងមានជ័យ ក្រុងស្ទឹងមានជ័យ ឬទូរស័ព្ទលេខ ០៩២ ៤០ ៥៨ ៧៣ ផង ។

# សេចក្តីប្រកាសរកបងប្រុសឈ្មោះ មាស ពន្លក

នាងខ្ញុំឈ្មោះ ស៊ុយ វ៉ាន់ថង រស់នៅស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស៊ុយ សារិន (ស្លាប់) ធ្វើពេទ្យ ម្តាយឈ្មោះ ឌី យ៉ាត (ស្លាប់) ស្រុកកំណើតនៅក្នុងភូមិកំពង់សំណាញ់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សូមស្វែងរកបងប្រុសឈ្មោះ មាស ពន្លក ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ មុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ពន្លក ធ្វើជាទាហានលន់ នល់ ឈរជើងនៅក្នុងខេត្តពោធិ៍សាត់ ។ ប្រសិនបើបងបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមកខ្ញុំតាមរយៈទូរស័ព្ទលេខ ០៩២ ៦៩៩ ០៣៨ ។

# មិនបំភ្លេចនូវពាក្យបណ្ដាំរបស់ឪពុក

លី រម្យមុន្នី អាយុ៤០ឆ្នាំ រស់នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ រម្យមុន្នី មានឪពុកឈ្មោះ ចាប សុខុម ជាប៉ូលិសការពារព្រំដែន និងម្តាយឈ្មោះ ឈៀវ ចាន់ថូ ជាមេផ្ទះ ។ រម្យមុន្នី មានបងប្អូនបីនាក់ ប្រុសពីរនាក់ និងស្រីម្នាក់ (ស្លាប់) ។

រម្យមុន្នី បានរៀបរាប់ថាពេលដែលខ្ញុំកើតគឺជាពេលដែលប្រទេសចាប់ផ្តើមកើតមានចលាចលដោយសារការធ្វើរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ទម្លាក់សម្តេច សីហនុ ចេញពីតំណែង ។ នៅខែមេសាឆ្នាំ១៩៧៥ ទោះបីជាខ្ញុំទើបតែមានអាយុប្រាំឆ្នាំក៏ដោយ ក៏ខ្ញុំនៅចាំថាមានកងទ័ពខ្មែរក្រហមចំនួនបីនាក់បានមកដល់សាលាដែលឪពុកខ្ញុំកំពុងបង្រៀន រួចហើយបញ្ជាឲ្យគាត់ទៅរៀបចំអីវ៉ាន់ចាកចេញពីផ្ទះរយៈពេលបីថ្ងៃសិន ព្រោះអង្គការត្រូវការរៀបចំបោសសម្អាតទីក្រុង ។ ដូច្នេះ ឪពុករបស់ខ្ញុំក៏ប្រញាប់ប្រញាល់ត្រឡប់មកប្រាប់ម្តាយខ្ញុំនៅផ្ទះនិងប្រមូលយកបានតែរបស់របរនិងខោអាវមួយកំផ្លេរដែលជាប់នឹងខ្លួនប៉ុណ្ណោះព្រោះខ្មែរក្រហមឃោសនាថា «នៅទីនោះមានអ្វីៗគ្រប់គ្រាន់អស់ហើយ» ។

ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំជាមួយនឹងគ្រួសារដទៃទៀតឲ្យធ្វើដំណើរទាំងយប់ងងឹតទៅខេត្តកំពង់ធំ ។ នៅតាមផ្លូវខ្ញុំឃើញកងទ័ពជាច្រើនកំពុងតែស្ពាយកាំភ្លើងឈរយាមការពារសន្តិសុខដែលពេលនោះធ្វើឲ្យឪពុកម្តាយខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង ម៉្លោះហើយគាត់ប្រញាប់ប្រញាល់ធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ទើបមកដល់សហករណ៍ភូមិម្សាក្រងស្រុកស្ទោង ។ នៅទីនោះ អង្គការចាត់តាំងឲ្យឪពុកខ្ញុំឲ្យដឹកជញ្ជូនស្រូវនៅសហករណ៍ ម្តាយធ្វើការងារនៅការដ្ឋាន ចំណែកខ្ញុំនិងប្អូនប្រុសពីរនាក់ទៀតត្រូវបានស្នាក់នៅផ្ទះ ។ នៅថ្ងៃមួយវេលាម៉ោង៥ព្រឹក ប្រធានសហករណ៍បានប្រមូលក្មេងៗក្នុងភូមិមកប្រជុំ រួចហើយចាត់តាំងឲ្យរែកអាចម៍គោទៅដាក់វាលស្រែប្រកាប់ទន្រ្ទានខែត្រ ។ ដើម្បីឲ្យក្មេងៗខិតខំធ្វើការ ប្រធានសហករណ៍ក៏បានគំរាមថា «បើនរណាខ្ជិលនិងធ្វើការមិនហើយតាមផែនការ អង្គការនឹងយកទៅសម្លាប់ចោល» ។ ពាក្យសម្តីនេះភ្លាម ទោះបីជាខ្ញុំឈឺនិងហេវហត់អស់កម្លាំងយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែទៅធ្វើការដែរ ។ នៅថ្ងៃមួយពេលខ្ញុំកំពុងរែកដីស្រាប់តែខ្ញុំឮសំឡេងស្រែកយ៉ាងខ្លាំងចេញពីសហករណ៍និងឃើញប្រធានសហករណ៍កំពុងបណ្តើរអ្នកទោសម្នាក់យកទៅសម្លាប់នៅវាលស្រែ ។

រៀងរាល់ថ្ងៃ ក្រោយពីធ្វើការងាររចប់អង្គការបានអនុញ្ញាតឲ្យខ្ញុំត្រឡប់មកដេកនៅផ្ទះជាមួយប្អូនវិញ ។ ប៉ុន្តែ ដោយសារពុំមានទឹកប្រើប្រាស់គ្រប់គ្រាន់ខ្ញុំបាននាំប្អូនទៅដួតទឹកស្ទឹងដែលមានចម្ងាយប្រមាណមួយគីឡូម៉ែត្រពីផ្ទះ ដោយពុំឲ្យឪពុកម្តាយដឹងឡើយ ។ ពេលកំពុងតែដួតទឹក ស្រាប់តែប្អូនស្រីពៅដែលទើបមានអាយុ៣ឆ្នាំរអិលជើងចូលកន្លែងទឹកជ្រៅ ។ ឃើញប្អូនលង់ទឹកដូច្នេះ ខ្ញុំភិតភ័យយ៉ាងខ្លាំងរួចហើយប្រញាប់ប្រញាល់ចាប់ទាញប្អូនមកមាត់ច្រាំងវិញ ។ បន្ទាប់ពីត្រឡប់មកដល់ផ្ទះបានមួយរយៈប្អូនស្រីពៅខ្ញុំចាប់ផ្តើមក្តៅខ្លួននិងខាំអណ្តាតខ្លួនឯងរហូតដល់ស្លាប់ ។



លី រម្យមុន្នី

រយៈពេលមួយខែក្រោយមក ទើបឪពុកខ្ញុំដឹងដំណឹងនេះហើយ គាត់បានស្តីបន្ទោសខ្ញុំយ៉ាងខ្លាំង ព្រមទាំងអប់រំខ្ញុំថា «ថ្ងៃក្រោយសូមកូនកុំទៅលេងទឹកស៊ីងនេះទៀត» ។

នៅក្នុងឆ្នាំ១៩៧៦ ប្រធានកងបានបញ្ជាខ្ញុំនិងប្អូនប្រុសទីពីរវាយគ្នាឲ្យគាត់មើល ហើយបានសន្យាថា «បើអ្នកណាឈ្នះអ្នកនោះនឹងលើកអាចម៍គោតិចជាង» ។ ដោយសារខ្ញុំនៅក្មេងមិនទាន់ចេះគិតឲ្យបានវែងឆ្ងាយទើបវាយគ្នាជាមួយប្អូនប្រុសយ៉ាងខ្លាំងរហូតបណ្តាលឲ្យចេញឈាមតាមច្រមុះនិងរបួសក្បាលរៀងៗខ្លួន ។ ពេលឪពុកខ្ញុំបរទេះដឹកស្រូវត្រឡប់មកពីសហករណ៍វិញ ស្រាប់តែឃើញខ្ញុំនិងប្អូនមានរបួសពេញខ្លួនគាត់ក៏ហៅបងប្អូនខ្ញុំមកសួរនិងអប់រំថា «ថ្ងៃក្រោយកូនត្រូវឈប់វាយគ្នាឲ្យគេមើល» ។ ចាប់តាំងពីពេលនោះមកខ្ញុំនិងប្អូនរបស់ខ្ញុំមិនដែលឲ្យខ្មែរក្រហមបញ្ជាបានទេ ។ លើសពីនេះទៀត ខ្ញុំតែងតែយកចិត្តទុកដាក់ថែទាំប្អូនរបស់ខ្ញុំទៀតផង ។

ឆ្នាំ១៩៧៧ នៅពេលល្ងាចមួយអង្គការបានមកហៅឪពុកខ្ញុំនិងប្រជាជន១០គ្រួសារទៀតទៅប្រជុំ ។ ដោយសារម្ចាស់ផ្ទះឈ្មោះ អ៊ឹ ទិត្យ ដែលឪពុកខ្ញុំស្នាក់នៅពីមុន បានស្តាប់ឮឈ្លបខ្មែរក្រហមជជែកគ្នាពីផែនការប្រមូលមនុស្សយកទៅសម្លាប់នោះគាត់ក៏លួចខ្សឹបប្រាប់ឪពុកខ្ញុំទាំងយប់ថា «បើអង្គការហៅទៅប្រជុំសូមកុំទៅជាមួយព្រោះអង្គការហៅយកទៅសម្លាប់ចោលជាមិនខាន» ។ បន្ទាប់ពីគាត់ប្រាប់ឲ្យឪពុកខ្ញុំទៅរស់នៅការដ្ឋានផ្សេងទើបខ្ញុំដឹងថាប្រជាជនដែលទៅប្រជុំនោះត្រូវបានអង្គការប្រមូលយកទៅសម្លាប់ចោលទាំងអស់ ។ ប៉ុន្តែទោះបីជា ឪពុករបស់ខ្ញុំរួចផុតពីការសម្លាប់នេះក៏ដោយ ប៉ុន្តែគាត់តែងតែព្រួយបារម្ភពីគ្រោះថ្នាក់គ្រប់ពេលព្រោះយប់ឡើង គាត់តែងឃើញកងឈ្លបចូលមកចាប់ចងប្រជាជនបណ្តើរយកចេញទៅដែលក្នុងនោះក៏មានប្អូនជីដូនមួយរបស់ខ្ញុំមួយគ្រួសារដែរ ។ ឪពុកខ្ញុំនៅចាំបានថាពេលនោះឈ្លបខ្មែរក្រហមបានចាប់គ្រួសារមួយបណ្តើរយកទៅវាយទម្លាក់រណ្តៅមួយដែលមានចម្ងាយពីភូមិរបស់ខ្ញុំប្រមាណតែប្រាំមួយគីឡូម៉ែត្រប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ១៩៧៨ អង្គការបានផ្លាស់ឪពុករបស់ខ្ញុំឲ្យទៅរស់នៅសហករណ៍ផ្សេងទៀត ។ នៅទីនោះ អង្គការបានចោទឪពុកខ្ញុំថាបាន «លួចយកឃ្មុំរបស់អង្គការរហូប» រួចហើយក៏ចាប់យកឪពុករបស់ខ្ញុំទៅសួរចម្លើយ ។ ទោះបីជា ឪពុកខ្ញុំបានឆ្លើយបដិសេធយ៉ាងណាក៏ដោយ ក៏អង្គការមិនស្តាប់ការបកស្រាយរបស់គាត់ឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ អង្គការបានបញ្ជាឲ្យកងឈ្លបពីរនាក់វាយធ្វើទារុណកម្មឪពុកខ្ញុំទាំងយប់ទាំងថ្ងៃបណ្តាលឲ្យគាត់របួសយ៉ាងធ្ងន់ធ្ងរ ។ ដោយសារតែឪពុកខ្ញុំមិនអាចទ្រាំទ្រនឹងការធ្វើទារុណកម្មនេះបានគាត់ក៏បានសារភាពកំហុសទោះបីជាគាត់មិនបាន



លី រម្យមុន្នី ចូលរួមវគ្គបណ្តុះបណ្តាលគ្រូថ្នាក់ជាតិក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជា

ប្រព្រឹត្តក៏ដោយ ។ ក្រោយពីស្តាប់ការសារភាពនេះភ្លាមឈ្លបបានទាញយកត្បូងចបមកវាយលើខ្លួនឪពុកខ្ញុំយ៉ាងដំណំរហូតដល់គាត់ដួលសន្លប់នៅនឹងកន្លែង ។ មួយសប្តាហ៍ក្រោយមក ទើបម្តាយរបស់ខ្ញុំបានដឹងដំណឹងនេះ ហើយបានសុំអនុញ្ញាតពីប្រធានកងដើម្បីមកមើលឪពុកខ្ញុំឈឺ ។ ពេលមកដល់មុខផ្ទះ ដោយសារឃើញផ្ទះមានសភាពស្ងប់ស្ងាត់ខុសធម្មតា គាត់ក៏ស្រែកហៅឪពុក

របស់ខ្ញុំតិចៗ ។ ប៉ុន្តែ ទោះបីឪពុកខ្ញុំស្តាប់ឮសំឡេងនេះក៏ដោយ ក៏គាត់មិនអាចចំណាំថាជាសំឡេងរបស់ម្តាយខ្ញុំដែរ ព្រោះគាត់បែកគ្នាយូរហើយ ។ ម្តាយខ្ញុំបានត្រឹមសម្រក់ទឹកភ្នែកប៉ុណ្ណោះនៅពេលដែលឃើញឪពុកខ្ញុំឈឺក្រោកដើរពុំរួច ។ បន្ទាប់មក គាត់ក៏យកក្រណាត់មករុំរបួសឲ្យឪពុកខ្ញុំ ។ ទោះបីដឹងថាឪពុកខ្ញុំមានជំងឺធ្ងន់ធ្ងរក៏ដោយ ក៏អង្គការមិនអនុញ្ញាតឲ្យម្តាយខ្ញុំនៅមើលថែទាំ



ប្រជាធិបតេយ្យ

គាត់ដែរ ។ ដោយហេតុនេះ ម្តាយខ្ញុំក៏ចេញដំណើរទៅកងរបស់គាត់វិញទាំងមិនអស់ចិត្ត ។ ដោយសារតែតាមផ្លូវធ្វើដំណើរពុំមានអាហារហូបគ្រប់គ្រាន់ម្តាយរបស់ខ្ញុំ ក៏កើតជំងឺគ្រុនក្តៅយ៉ាងខ្លាំង ។ ឃើញដូច្នេះ អង្គការបានស្តីបន្ទោសឲ្យគាត់យ៉ាងខ្លាំង ហើយថែមទាំងបង្ខំឲ្យគាត់ធ្វើការទាំងឈឺទៀតផង ។ ប្រាំខែក្រោយមក បងប្អូនជីដូនមួយរបស់ម្តាយខ្ញុំឈ្មោះ ហ៊ី ត្រូវបានអង្គការចោទប្រកាន់ថា «លួចកាម៉ែលរបស់អង្គការ» រួចក៏ចងដៃរបស់គាត់ភ្ជាប់ជាមួយរទេះសេះអូសគាត់តាមភ្លឺស្រែ ។ ទោះបីដឹងថា កាម៉ែលនោះជារបស់ពូ ហ៊ី ក៏ដោយ ក៏ឈ្លបនៅតែធ្វើទារុណកម្មលើគាត់រហូតសន្លប់ស្មារតីដែរ ។ ដោយសារតែដឹងថាគាត់គ្មានកំហុស អ្នកភូមិជាច្រើននាក់ទៅសុំអង្វរអង្គការឲ្យដោះលែងគាត់ ។ ក្រោយពីដឹងដំណឹងនេះភ្លាម ម្តាយរបស់ខ្ញុំក៏សុំច្បាប់ពីប្រធានកងទៅសួរសុខទុក្ខគាត់ ។ ម្តាយខ្ញុំអាណិត ហ៊ី ជាខ្លាំង ពេលឃើញគាត់មានជំងឺហើមដៃហើមជើងដេកនៅលើកន្ទេលរហែកមួយដែលស្ទើរតែមើលពុំស្គាល់បែបនេះ ។ បន្ទាប់មក ហ៊ី បាននិយាយរៀបរាប់អំពីដំណើររឿងនេះទាំងអស់កម្លាំង ។

នៅពេលដែលកងទ័ពវៀតណាមចូលមកនៅក្នុងឆ្នាំ ១៩៧៩ ឪពុកម្តាយខ្ញុំនិងប្រជាជនជាច្រើនគ្រួសារទៀតបានធ្វើដំណើររយៈពេលប្រាំយប់ទើបមកដល់ភូមិអូរឫស្សីវិញ ។ ប៉ុន្តែ ពេលមកដល់ផ្ទះ ឪពុកម្តាយខ្ញុំគ្មានផ្ទះរស់នៅទេ ព្រោះខ្មែរក្រហមបំផ្លាញគ្មានសល់អ្វីឡើយ ។ ឃើញដូច្នេះ ឪពុកខ្ញុំក៏ត្រឡប់មករស់នៅស្រុកខាងម្តាយ នៅឃុំពាមជីកង ស្រុកកងមាសវិញ ។ នៅទីនោះ ឪពុកម្តាយរបស់ខ្ញុំបានសង់ផ្ទះមួយខ្នងនិងប្រកបមុខរបរដាំបន្លែ និង នេសាទត្រី ។ នៅឆ្នាំ១៩៨១ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាឃុំឫស្សីស្រុក ក្រោយមក ខ្ញុំក៏បានផ្លាស់ទៅរៀននៅវិទ្យាល័យព្រះសីហនុខេត្តកំពង់ចាមវិញ ។ នៅឆ្នាំ ១៩៨៩ ខ្ញុំបានប្រឡងជាប់សញ្ញាបត្រ័បាក់ឌុប ហើយក៏ប្រឡងចូលរៀនផ្នែកប្រវត្តិវិទ្យា ។ នៅឆ្នាំ១៩៩៧ ខ្ញុំចេញធ្វើជាគ្រូបង្រៀនខាងផ្នែកប្រវត្តិវិទ្យានៅវិទ្យាល័យព្រះសីហនុ រហូតដល់ឆ្នាំ២០០៧ ទើបខ្ញុំផ្លាស់មកធ្វើគ្រូនៅនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការទីក្រុងភ្នំពេញ ។

ឥឡូវពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា និង ក្រសួងអប់រំយុវជន និង កីឡា ជ្រើសរើសខ្ញុំជាគ្រូបង្គោលថ្នាក់ជាតិ ខ្ញុំយល់ថា ការបង្រៀនប្រវត្តសាស្ត្រកម្ពុជាប្រជាធិបតេយ្យពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះនឹងធ្វើក្មេងជំនាន់ក្រោយបានដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ជាពិសេសផងដែរនោះ ដើម្បីជំរុញឲ្យមានការផ្សះផ្សាបង្រួបបង្រួមនិងអភិវឌ្ឍជាតិ ។

**ស៊ិន សុធីតា**

# ពិធីចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជា
# ខេត្តឧត្តរមានជ័យ ថ្ងៃទី



អ្នកភូមិនៅខេត្តឧត្តរមានជ័យកំពុងអាន សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ



សិស្សវិទ្យាល័យអន្លង់វែងទទួលសៀវភ



សហព្រះរាជអាជ្ញាអន្តរជាតិ អែនឌ្រូ ខេឡេ ចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សវិទ្យាល័យអន្លង់វែង

# ប្រជាធិបតេយ្យ" នៅវិទ្យាល័យអន្លង់វែង
# ២១ ខែមិថុនា ឆ្នាំ២០១០



ភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ



អ្នកស្រី អ៊ឹម ចែម ឡើងអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ





លោកជំទាវ ទន់ សាអ៊ឹម សំណេះសំណាលជាមួយ
គ្រូបង្រៀននៅវិទ្យាល័យអន្លង់វែង



អ្នកស្រី អ៊ឹម ចែម នៅក្នុងពិធីចែកសៀវភៅ

# អតីតអ្នកយាមនៅមន្ទីរស-២១ បានធូរស្បើយក្រោយពីនិយាយរឿងពិត

ចៀម សឿ តែងតែទទួលនូវការមាក់ងាយនិងស្អប់ខ្ពើមយ៉ាងខ្លាំងពីសំណាក់ប្រជាជនរស់នៅក្នុងភូមិបន្ទាប់ពីដឹងថាគាត់ជាអតីតអ្នកយាមនៅមន្ទីរស-២១ ដែលមានអ្នកទោសស្លូតត្រង់ប្រមាណជាងមួយម៉ឺននាក់ស្លាប់ ។ អ្នកខ្លះធ្លាប់បានស្រែកដេរ សឿ ថា «អាឃាតករ» ទៀតផង នៅពេលឃើញគាត់រែកទឹកឆ្លាតកាត់តាមមុខផ្ទះ ។ សឿ ពិបាកចិត្តយ៉ាងខ្លាំងពេលឮការប្រមាថនិងរើសអើងបែបនេះ ។ ប៉ុន្តែបន្ទាប់ពី សឿ ឡើងនិយាយរឿងរ៉ាវពិតនៅតុលាការខ្មែរក្រហមបានធ្វើឲ្យគាត់មានអារម្មណ៍ធូរស្បើយ ហើយអ្នកភូមិជាច្រើនបានរាប់អានគាត់ឡើងវិញ ក្រោយពីដឹងថាគាត់មិនមានពាក់ព័ន្ធនឹងការសម្លាប់អ្នកទោស ។

សឿ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ (ខ្មែរក្រហម) ចាប់តាំងពីអាយុ១៧ឆ្នាំដោយសារគាត់ឃើញទាហានកងទ័ព លន់ នល់ ចូលមកធ្វើបាបប្រជាជនក្នុងភូមិនិងទម្លាក់គ្រាប់បែកបណ្តាលឲ្យឆេះផ្ទះសម្បែងនិងសម្លាប់ជីវិតប្រជាជនស្លូតត្រង់អស់ជាច្រើននាក់ ។



ចៀម សឿ

នៅពេលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សឿ រីករាយយ៉ាងខ្លាំងដោយសង្ឃឹមថាប្រទេសនឹងមានសន្តិភាពហើយគាត់នឹងបានវិលត្រឡប់ទៅរស់នៅស្រុកកំណើតវិញ ។ ប៉ុន្តែ ក្តីស្រមៃនេះត្រូវរលាយទៅវិញព្រោះអង្គការហាមឃាត់ ។ នៅឆ្នាំ១៩៧៦ អង្គការចាត់តាំងឲ្យ សឿ មកធ្វើជាកងការពារអ្នកទោសនៅមន្ទីរស-២១ រហូតដល់ឆ្នាំ១៩៧៩ ពេលរបបខ្មែរក្រហមដួលរលំ ទើបគាត់អាចត្រឡប់ទៅជួបជុំជាមួយបងប្អូននិងរស់នៅស្រុកកំណើតវិញ ។

រយៈពេលជិត៣០ឆ្នាំ សឿ រស់នៅក្នុងភាពលាក់លៀម ដែលសូម្បីតែប្រពន្ធនិងកូនដែលរស់នៅក្នុងផ្ទះជាមួយគ្នាក៏មិនដឹងពីប្រវត្តិការងាររបស់គាត់ដែរ ។ ប៉ុន្តែក្រោយមក ទើបគ្រួសាររបស់គាត់បានដឹងថាគាត់ធ្លាប់ធ្វើជាកម្មាភិបាលខ្មែរក្រហម បន្ទាប់ពីអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញប្រវត្តិរូបរបស់គាត់ថាធ្លាប់ធ្វើជាកងការពារអ្នកទោសក្នុងមន្ទីរស-២១ ឬ (គុកទួលស្លែង) ។ ពេលដែលយកឯកសារទាំងនេះទៅបង្ហាញ សឿ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះកាលពីជំនាន់ខ្មែរក្រហមអង្គការបានឲ្យគាត់ធ្វើប្រវត្តិរូបជាច្រើនដងហើយមិននឹកស្មានថានៅសល់ដល់ពេលនេះទេ ។ សឿ មិនបានបដិសេធឯកសារប្រវត្តិរូបនេះទេ ប៉ុន្តែ គាត់ហាក់ដូចជាឆ្លើយលាក់លៀមនូវរឿងរ៉ាវមួយចំនួនដែលគាត់បានដឹង ។

បន្ទាប់ពីបានដឹងរឿងពិតរបស់ សឿ ទើបមានអ្នកយកព័ត៌មានជាតិនិងអន្តរជាតិនិងក្រុមថតខ្សែភាពយន្តឯកសាររបស់លោក រិទ្ធី ប៉ាន់ បានសុំការអនុញ្ញាតពីគាត់ឲ្យមកសម្តែងសកម្មភាពជាអ្នកយាមការពារអ្នកទោសនៅក្នុងមន្ទីរស-២១ ឬ (គុកទួលស្លែង) ឡើងវិញ ។ ពេលមកដល់គុកទួលស្លែងដំបូង សឿ ចាប់ផ្តើមមានអារម្មណ៍ភ័យខ្លាចនិងសោកស្តាយយ៉ាងខ្លាំង ហើយមានបំណងចង់វិលត្រឡប់ទៅផ្ទះវិញ ។ ក្រោយមក សឿ ក៏បានបោះបង់គំនិតនេះចោលនៅពេលដែលឃើញអតីតកងការពារនៅគុកទួលស្លែងផ្សេងទៀតបានមកទីនោះដែរ ។ ក្រោយពីត្រឡប់មកដល់ផ្ទះ

វិញ ប្រពន្ធរបស់ សឿ បានសួរគាត់ថាតើអ្នកទៅភ្នំពេញធ្វើអ្វី? ពេលនោះ សឿ បានឆ្លើយទាំងមានអារម្មណ៍ខ្មាសអៀនប្រាប់ប្រពន្ធថាទៅថតភាពយន្តឯកសារជំនាន់ ប៉ុល ពត ព្រោះខ្ញុំជាអ្នកយាមនៅគុកទួលស្លែង ។

មិនយូរប៉ុន្មាន រឿងនេះបានលេចឮដល់ប្រជាជនក្នុងភូមិ នៅពេលដែលតុលាការខ្មែរក្រហម ឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកោះហៅ សឿ ឲ្យធ្វើជាសាក្សីក្នុងសវនាការកាត់ទោស ឌុច អតីតប្រធានមន្ទីរស-២១ ឬ (គុកទួលស្លែង) និងជាមេរបស់គាត់ដែរ ។ សឿ មានក្តីបារម្ភយ៉ាងខ្លាំងពីវាសនារបស់គាត់និងក្រុមគ្រួសារព្រោះជនរងគ្រោះដែលមានសាច់ញាតិបងប្អូនស្លាប់នៅគុកទួលស្លែងនិងប្រជាជនក្នុងភូមិតែងមើលបំណាំពីសកម្មភាពរបស់គាត់និងស្អប់ខ្ពើមគាត់យ៉ាងខ្លាំង ។

ថ្ងៃមួយពេល សឿ ត្រឡប់មកយកពីទឹកត្នោតវិញ អ្នកភូមិមួយក្រុមបានស្រែកជេរគាត់ទាំងកំហឹងថា «អាឃាតករ» អ្វែងជិតដល់ថ្ងៃឡើងតុលាការហើយ ។ សឿ មិនបានតបតទៅវិញទេ គាត់គ្រាន់តែឆ្លើយប្រាប់ទៅគេវិញថា «ខ្ញុំមិនបានសម្លាប់មនុស្សទេ ហើយខ្ញុំនឹងឡើងនិយាយការពិតនៅចំពោះមុខតុលាការ» ។ សឿ បានត្រឡប់មកផ្ទះវិញទាំងអារម្មណ៍សោកស្តាយនិងពិបាកចិត្តយ៉ាងខ្លាំង ។

រហូតដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៩ តុលាការខ្មែរក្រហម ឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកោះហៅ សឿ ឲ្យមកផ្តល់សក្ខីកម្មក្នុងសវនាការ ឌុច ដោយមានចៅក្រមនិងមេធាវីពន្យល់គាត់យ៉ាងច្បាស់លាស់ពីសិទ្ធិក្នុងការឆ្លើយសំណួរ ។ បន្ទាប់ពីស្តាប់សក្ខីកម្មចប់ ឌុច បានបដិសេធថា សឿ មិនមែនជាបុគ្គលិកនៅមន្ទីរស-២១ទេ ។ នៅពេលត្រឡប់មកផ្ទះវិញ សឿ ត្រូវមន្ត្រីតុលាការយកចិត្តទុកដាក់និងបានការពារសិទ្ធិរបស់គាត់ក្នុងនាមជាសាក្សី ។ នៅពេលនោះ មានអ្នកភូមិនិងអ្នកជិតខាងជាច្រើនបានមកសួរ សឿ ថាតើរឿងនេះកើតឡើងដូចម្តេចខ្លះ? សឿ បានឆ្លើយតបវិញថា «រឿងរ៉ាវពិតខ្ញុំបាននិយាយអស់ហើយនៅមុខតុលាការនិងចាក់បញ្ចាំងតាមទូរទស្សន៍ទៀតផង ខ្ញុំមិនបានធ្វើអ្វីលើសពីនេះទេ» ។

សព្វថ្ងៃនេះ សឿ បានធូរស្បើយអារម្មណ៍និងរស់នៅមានសុភមង្គលជាមួយប្រពន្ធកូន ព្រោះគាត់បាននិយាយរឿងរ៉ាវផ្ទាល់ខ្លួនដែលបានលាក់ទុកជាង៣០មកហើយឲ្យប្រជាជនបានដឹងឮជាសាធារណៈ ហើយរឿងនេះត្រូវបានដោះស្រាយដោយតុលាការខ្មែរក្រហម ។ សឿ មិនមានអារម្មណ៍ខ្មាសអៀនដូចពីមុនទេ ហើយគាត់តែងទៅចូលរួមក្នុងពិធីបុណ្យផ្សេងនៅក្នុងភូមិជានិច្ច ចំណែកអ្នកជិតខាងបានមករាប់អាន សឿ ឡើងវិញដែរ ។

សឿ រស់នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ សព្វថ្ងៃ សឿ ប្រកបមុខរបរជាអ្នកឡើងត្នោត ចំណែកកូនរបស់ សឿ ទាំងអស់មិនបានចូលរៀនទេដោយសារគ្រួសារគាត់មានជីវភាពខ្វះខាត ។ សឿ មានប្រសាសន៍ថា «ទោះបីខ្ញុំមានជីវភាពលំបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចធ្វើការនិងរកស៊ីដោយពុំមានការហាមឃាត់ដូចក្នុងរបបខ្មែរក្រហមឡើយ» ។

ចៀម សឿ បញ្ជាក់ថាទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជួយរកយុត្តិធម៌ជូនជនរងគ្រោះដែលបាត់បង់ជីវិតយ៉ាងអយុត្តិធម៌នៅក្នុងរបបខ្មែរក្រហមមិនបានគ្រប់គ្រាន់ក៏ដោយ ក៏តុលាការនេះបានធ្វើឲ្យជនរងគ្រោះបានធូរស្បើយអារម្មណ៍ដែរ ។ តុលាការនេះជាគំរូមួយសម្រាប់មេដឹកនាំប្រទេសនានាលើពិភពលោក និងអ្នកដឹកនាំក្រោយៗទៀតកុំឲ្យប្រព្រឹត្តិអំពើឃោរឃៅបែបនេះទៀត ហើយច្បាប់នឹងធ្វើការកាត់ទោសទោះបីអ្នកប្រព្រឹត្តនោះមានវ័យចាស់ជរាហើយក៏ដោយ ។ **សុខ ខណ្ណះ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឲ្យមានកម្មវិធីអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ម៉ម អឿន អាយុ៦០ឆ្នាំ រស់នៅឃុំរំចង់ ស្រុកសំរោង ខេត្តតាកែវ ។ នៅឆ្នាំ១៩៧២ ក្រោយពីកងទ័ពខ្មែរក្រហមចូលដល់ភូមិកំណើតរបស់គាត់ អឿន បានឈប់រៀនត្រឹមថ្នាក់ទី៣ ។ ដោយសារតែឪពុកម្ដាយរបស់ អឿន ចង់ឲ្យកូនរៀនឲ្យបានខ្ពស់ គាត់ទាំងពីរនាក់ក៏សម្រេចចិត្តបញ្ជូន អឿន មករៀនបន្តនៅសាលាឥន្ទ្រទេវីក្នុងទីក្រុងភ្នំពេញទៀត ដោយស្នាក់នៅក្នុងផ្ទះជាមួយពូរបស់គាត់ ។ ក្រោយពីចាកចេញពីផ្ទះបានប្រហែលមួយឆ្នាំ គ្រួសាររបស់ អឿន បានផ្លាស់មករស់នៅភ្នំពេញដែរតាមរយៈអង្គការជួយជនភៀសខ្លួន ។ នៅទីនេះ គ្រួសាររបស់ អឿនជួបការលំបាកជាច្រើនព្រោះពូរបស់គាត់ត្រូវរកលុយដើម្បីចិញ្ចឹមគ្រួសារទាំងមូល ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ អឿន នៅតែខិតខំរៀនសូត្ររហូតដល់ចប់ថ្នាក់អនុវិទ្យាល័យដែរ ។ នៅដើមឆ្នាំ១៩៧៥ អឿន បានចូលធ្វើជាប៉ូលិសដោយទទួលបានប្រាក់ខែបន្តិចបន្តួចសម្រាប់ជួយផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែម ។ ប៉ុន្តែពេលមានគ្រួសារលំនឹងបន្តិចស្រាប់តែនៅខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកដល់ក្រុងភ្នំពេញហើយបានជម្លៀសប្រជាជនទាំងអស់ឲ្យចាកចេញពីក្រុង ។

ពេលគ្រួសាររបស់ អឿន ធ្វើដំណើរត្រឡប់មករស់នៅខេត្តតាកែវវិញ ខ្មែរក្រហមបានចាត់ទុកគ្រួសាររបស់ អឿន ជាប្រជាជន១៧មេសាដែរ ដោយមិនអនុញ្ញាតឲ្យគាត់មានសិទ្ធិដូចប្រជាជនមូលដ្ឋានទេ ។ ប៉ុន្តែ ដោយសារតែគ្រួសាររបស់ អឿន ធ្លាប់រស់នៅខេត្តតាកែវពីមុន និងទទួលការស្រឡាញ់រាប់អានពីប្រជាជននៅក្នុងភូមិ អ្នកទាំងនេះតែងតែខ្សឹបប្រាប់ថា «ត្រូវចេះ ប្រយ័ត្នប្រយែង កុំឲ្យនិយាយអ្វី ប្រាប់គេថារៀនបានច្រើនឲ្យសោះ» ។ មិនយូរប៉ុន្មាន អង្គការបានដើរមកកត់ឈ្មោះប្រជាជននៅក្នុងភូមិទាំងអស់ដើម្បីធ្វើប្រវត្តិរូប ។ ពេលនោះ អឿន ភ័យខ្លាចជាខ្លាំងព្រោះឃើញប្រជាជនបាត់ខ្លួនជាបណ្ដើរៗក្រោយពីប្រាប់ការពិតទៅអង្គការ ។ ឃើញដូច្នេះហើយ អឿន ក៏លាក់បាំងប្រវត្តិរូបរបស់ខ្លួនរួចប្រាប់ថាជាសិស្សរៀនបានត្រឹមថ្នាក់ទី៣ប៉ុណ្ណោះ ។ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំង អឿន ឲ្យទៅធ្វើការនៅក្នុងក្រុមសាមគ្គីតាមភូមិឃុំ ។ ធ្វើការបានប្រហែលបីខែ អឿន ត្រូវផ្លាស់ទៅធ្វើការនៅកងចល័ត ខាងដកស្ទូងនិងលើកទំនប់វិញ ។ នៅទីនោះ ប្រជាជនទាំងអស់ខិតខំធ្វើការស្ទើរគ្មានពេលឈប់សម្រាក ប៉ុន្តែការហូបចុកវិញគឺមានតែបបរពីរវែកប៉ុណ្ណោះហើយថែមទាំងមិនអនុញ្ញាតឲ្យមកសួរសុខទុក្ខឪពុកម្ដាយទៀតផង ។ ដោយសារការខិតខំប្រឹងប្រែងខ្លាំងពេក ប្រជាជនមួយចំនួនបានធ្លាក់ខ្លួនឈឺរហូតត្រូវបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ ជាក់ស្ដែង ឪពុករបស់ អឿន បានស្លាប់នៅឆ្នាំ១៩៧៦ ដោយសារជំងឺហើមនិងគ្មានថ្នាំពេទ្យសម្រាប់ព្យាបាល ។ ចំណែកម្ដាយវិញកើតជំងឺខាន់លឿងក្រោយមកដោយសារតែបានទឹកត្នោតយកមកលាយជាមួយអង្ករលីងដំណើបខ្មៅយកមកឲ្យគាត់ហូប ទើបគាត់ជាសះស្បើយអាចរស់បានរហូតមកដល់សព្វថ្ងៃនេះ ។



ម៉ម អឿន

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្ដើមរឹតបន្តឹងវិន័យយ៉ាងខ្លាំងដោយបង្ខំឲ្យប្រជាជនធ្វើការឲ្យហើយតាមផែនការកំណត់បើមិនអីចឹងទេនឹងមានទោសជាមិនខាន ។ ពេលនោះ ខ្មែរក្រហមបានចាត់តាំងឲ្យ អឿន កាប់ដីបីម៉ែត្រគូបឲ្យហើយក្នុងមួយថ្ងៃ ។ ដោយសារតែមេឃភ្លៀងខ្លាំងពេក ប្រជាជនទាំងអស់នាំគ្នាមកឈប់ធ្វើការរួចបែរជានាំគ្នាទៅគាស់មើមប្លុងយកមកហូបហើយស្រែកថា «ដូចៗតែគ្នា» ។ បន្តិចក្រោយមក ស្រាប់តែមេកងមកទាន់ហើយប្រកាសហៅ អឿន និងប្រជាជនផ្សេងទៀតទៅប្រជុំដោយដំបូងប្រធានកង ឈ្មោះ ចាប យុន បានសួរ អឿន ថាឪពុកម្ដាយធ្វើអីពីមុននិងរៀនដល់ថ្នាក់ទីប៉ុន្មានហេតុអ្វីបានជានិយាយថា «ដូចគ្នា»? អឿន តក់ស្លុតជាខ្លាំង ដោយគ្រាន់តែប្រាប់ថារើសបាន

មើមបុងទើបនាំគ្នានិយាយលេងបែបនេះគឺអត់មានមើលងាយងាយដល់អង្គការទេ ។ ដោយសារតែមិនជឿពាក្យទាំងនេះ តា យុន បានបង្ខំឲ្យ អឿន ស្បថជូនអង្គការទៀតថា «ត្រូវដើរតាមអង្គការ មិនត្រូវក្បត់អង្គការទេ» ទើបដោះលែងឲ្យមានសេរីភាពវិញ ។

ទោះបីយ៉ាងណាក៏ដោយ ក៏ការរស់នៅរបស់ អឿន ស្ថិតនៅក្នុងភាពភ័យខ្លាចរហូត ព្រោះគាត់តែងតែឃើញខ្មែរក្រហមយកបណ្តើរមនុស្សទៅសម្លាប់ជាញឹកញាប់ ។ ជាក់ស្តែង ថ្ងៃមួយមានកងនារីម្នាក់មកពីអង្គព្រៃបានចូលទៅលួចបេះដូងនៅក្នុងអង្គភាពរបស់គាត់ ។ ពេលនោះ ដោយសារតែ អឿន លួចទៅបត់ជើងនៅក្បែរគុម្ពគ្រប់ហើយមានបំណងចង់ចុះទៅលាងជើងនិងលុបមុខនៅក្នុងទឹកស្រះក្បែរនោះដែលអង្គការហាមឃាត់ ឈ្លបខ្មែរក្រហមក៏ហៅគាត់ទៅសួរ ។ ក្រោយពីដឹងថាឈ្លបទាំងនោះសួររកឈ្មោះខ្យង ដែលតែងតែលួចហូបដូងរបស់អង្គការដែរ អឿន សប្បាយចិត្តជាខ្លាំងព្រោះមិនមែនហៅគាត់ទៅកសាងទេ ។ នៅពេលនោះគ្រាន់តែនិយាយបានបន្តិច អឿន ឃើញឈ្លបទៅដល់ផ្ទះរបស់ខ្យង រួចបណ្តើរនាងយកទៅបាញ់សម្លាប់នៅខាងជើងវត្តព្រហ្ម ។ ចំណែក ពេលទៅលើកទំនប់នៅគោកពោធិវិញនៅវេលាម៉ោងប្រហែលបីរសៀល អឿន បានឃើញខ្មែរក្រហមចាប់បានក្មេងប្រុសម្នាក់ដែលមានអាយុប្រហែល១៨ឆ្នាំបណ្តើរកាត់កន្លែងធ្វើការរបស់គាត់រួចប្រកាសប្រាប់ប្រជាជនថាកុំឲ្យយកតម្រាប់តាមក្មេងម្នាក់នេះព្រោះកសាងជាច្រើនលើកហើយនៅតែមិនធ្វើតាម ។ មួយសន្ទុះក្រោយមក ពេលដែលដើរទៅដល់ទួលមួយចម្ងាយប្រហែល៥គីឡូម៉ែត្រ អឿន ឮស្នូរសំឡេងកាំភ្លើងផ្ទុះឡើង ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានបង្ខំឲ្យ អឿន បានរៀបការជាមួយបុរសម្នាក់គាត់មិនដែលស្គាល់ពីមុន ។ ដោយសារតែមិនស្រឡាញ់បុរសនោះទាល់តែសោះ អឿន បាននិយាយប្រាប់មេកងកងនោះថា «ខ្ញុំប្តេជ្ញាថាមិនរៀបការជាដាច់ខាត» ។ ក្រោយពីដឹងថាមិនអាចបង្ខំ អឿន រៀបការបាន ប្រធានកងនោះស្រាប់តែប្តូរចិត្តរួចប្រាប់គាត់ឲ្យនិយាយប្រាប់ថាឈឺទៅបានហើយ ។ ទោះបីជាជាប្រធានកងមិនធ្វើបាបគាត់ក៏ដោយ ក៏ អឿន តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់ជានិច្ចព្រោះឃើញតែខ្មែរក្រហមយកមនុស្សទៅសម្លាប់ជារៀងរាល់ថ្ងៃ ។ អឿន បានរៀបរាប់ដោយទឹកមុខស្រងូតស្រងាត់ថា នៅដើមឆ្នាំ១៩៧៨ពេលដែលខ្មែរក្រហមផ្លាស់អ្នកកំពង់ស្ពឺមកនៅទីនេះ ខ្មែរក្រហមបានយកអ្នកទាំងនោះទៅសម្លាប់ជាបន្តបន្ទាប់ ។

ក្រោយរបបខ្មែរក្រហមដួលរលំទៅគ្រួសាររបស់ អឿន បានបាត់បង់បងប្រុសម្នាក់ធ្វើដែលជាប៉ូលិសយោធា ។ នៅឆ្នាំ១៩៨០ អឿន បានចូលធ្វើជាគ្រូបង្រៀននៅសាលាវត្តបឹងតាលាប់បន្ទាប់មកក៏ផ្លាស់មកបង្រៀននៅសាលាបឋមសិក្សាបត់រកាវិញ ។ ក្រោយពីបានទៅរៀនវគ្គបណ្តុះបណ្តាលនៅសាលាគរុកោសល្យភូមិភាគខេត្តតាកែវរយៈពេលបីខែ នៅឆ្នាំ១៩៨៣ អឿន បានចេញទៅបង្រៀននៅអនុវិទ្យាល័យអង្គព្រៃជំនាញភូមិវិទ្យា ។ ក្រោយមក ដោយសារតែនៅសាលាខ្វះគ្រូប្រវត្តិវិទ្យានាយកសាលាក៏ចាត់តាំងឲ្យ អឿន បង្រៀនមុខវិជ្ជានេះទៀត ។ ចាប់តាំងពីពេលនោះមក អឿន ក៏បានបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានេះរហូតមក ។ ក្រៅពីការងារជាគ្រូបង្រៀន អឿន តែងតែឆ្លៀតពេលទំនេរធ្វើស្រែចម្ការបន្ថែម ។

**ឆាយ ឈុនលី**

# ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធិភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវើស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational Center* ។ មុននិងផ្សព្វផ្សាយគេហទំព័រនេះ ត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា ។

# អំពើល្អរបស់ខ្មែរក្រហម

*ប៉ែន សូភី សព្វថ្ងៃរស់នៅស្រុកសំរោង ខេត្តតាកែវ បាន រៀបរាប់ថា «ខ្មែរក្រហមបានសម្លាប់មនុស្សអស់យ៉ាងច្រើន ប៉ុន្តែ ក៏មានខ្មែរក្រហមមួយចំនួនបានជួយប្រជាជនផងដែរ»។ ហេតុអ្វី បានជា សូភី យល់បែបនេះ?*

## រត់ចេញពីការគ្រប់គ្រងរបស់ខ្មែរក្រហម

ក្រោយពីកងទ័ពខ្មែរក្រហមបានចូលមកដល់ភូមិទន្លាប់ឆ្នាំ ១៩៧៤ប្រជាជនទាំងអស់ដែលរស់នៅក្នុងភូមិនេះត្រូវបានជម្លៀស ឲ្យទៅរស់នៅស្រុកព្រៃកប្បាស។ ពេលនោះ ប្រជាជនទាំងអស់ មានការភ័យខ្លាចជាខ្លាំងដោយឃើញខ្មែរក្រហមចងមនុស្សទាំងខ្សែ យកទៅសម្លាប់ដោយចោទថាជាឈ្លើយសឹកដែលក្នុងចំណោមនោះ ក៏មានបងថ្លៃរបស់គាត់ផងដែរ។ ដោយសារតែស្អប់ខ្ពើមអំពើដ៏ សាហាវឃោរឃៅបែបនេះ សូភី និងមិត្តភក្តិរបស់គាត់ម្នាក់ឈ្មោះ


ប៉ែន សូភី

ឆែម ក៏បបួលគ្នារត់។ ក្រោយពីពិភាក្សាគ្នារួច គាត់ទាំងពីរនាក់ក៏ នាំគ្នាធ្វើដំណើរចាកចេញពីភូមិទាំងគ្មានអាហារសម្រាប់ទុកបម្រុង ហូបតាមផ្លូវ។ ទោះបីជាការធ្វើដំណើរមិនមានគោលដៅច្បាស់ លាស់ក៏ដោយ ប៉ុន្តែ សូភី និង ឆែម មិនដែលភ័យខ្លាចខ្មែរ ក្រហមចាប់ខ្លួនយកគាត់ទៅសម្លាប់ទេ ព្រោះគាត់តែងតែយកកាំបិត ដាក់តាមខ្លួនរហូតដើម្បីទុកការពារខ្លួន។ សូភី បានរៀបរាប់ថា «នៅអំឡុងពេលនោះ ខ្ញុំមិនដែលខ្លាចស្លាប់ទេ ព្រោះខ្ញុំប្តេជ្ញាចិត្តថា ឲ្យតែដើររកចាប់ខ្ញុំនឹងកាប់តែម្តង»។ ថ្ងៃមួយ គ្រាន់តែដើរហួសអូរ មួយរួចឆ្លងចូលដល់អូរមួយទៀត ស្រាប់តែទាហាន លន់ នល់ បាញ់រះមកលើគាត់ទាំងពីរនាក់យ៉ាងខ្លាំង។ ដើម្បីឃាត់កុំឲ្យទាហាន លន់ នល់ បាញ់ គាត់បានស្រែកប្រាប់ថា «កុំបាញ់ខ្ញុំ!ខ្ញុំមិនមែន ខ្លាំងទេ»។ ក្រោយស្តាប់ឮ សូភី ស្រែកបែបនេះ ទាហានទាំងនោះ ក៏ឈប់បាញ់ ហើយនិយាយថា «លីកាំបិតសោះ ស្មានតែលីកាំ ភ្លើង»។ គ្រាន់តែឮពាក្យនេះភ្លាម សូភី បានស្តីបន្ទោសឲ្យទាហាន ទាំងនោះថា «ប្រសិនបើខ្ញុំខ្លាំង! ខ្ញុំតដៃហើយមិនមែននៅស្ងៀម ទេ។ ពួកថ្ងៃក្រោយធ្វើទ័ពឲ្យដឹងផង»។ ភាពក្លាហានមិនខ្លាច ស្លាប់នេះបានធ្វើឲ្យទាហាន លន់ នល់ មានការភ្ញាក់ផ្អើលជាខ្លាំង រហូតដល់ទាហានទាំងនោះនាំគាត់ទៅស្នាក់នៅផ្ទះរបស់លោកស័ក្តិ ៥ ទៀត។ ប៉ុន្តែដោយព្រួយបារម្ភខ្លាចអ្នកទាំងពីរមានគ្រោះថ្នាក់ មួយរយៈ ក្រោយមកពូរបស់ ឆែម បាននាំគាត់ និង ឆែម ទៅរស់ នៅកន្លែងថ្មីមួយទៀត។ នៅទីនោះ ប្រធានអភិវឌ្ឍសហគមន៍មាន ចិត្តអាណិត សូភី ជាខ្លាំងរួចសួរថាតើគាត់ចង់រៀនទៀត ឬយ៉ាង ម៉េច? សូភី ត្រេកអរជាខ្លាំងរួចក៏ឆ្លើយតបថា «ខ្ញុំនៅជាមួយម៉ែ នៅតែរកប្រាក់មិនបានរៀន ចុះទម្រាំនៅតែម្នាក់ឯងទៀត។ ឥឡូវខ្ញុំសុំចូលធ្វើការខាងអភិវឌ្ឍសហគមន៍ផងដើម្បីឲ្យខ្ញុំអាចមាន លុយរៀនបន្តទៀត»។ ក្រោយពីធ្វើការបានមួយរយៈ សូភី បាន រៀបការជាមួយបុរសម្នាក់ធ្វើដែលជាទាហាន លន់ នល់។ ប៉ុន្តែក្រោយពីរៀបការរួច សូភី ត្រូវបែកពីប្តីរបស់គាត់រហូត ដោយសារតែគាត់ត្រូវបានបញ្ជូនឲ្យរៀនបន្ថែម។ ក្រោយមក សូភី ទទួលដំណឹងថាកងទ័ពខ្មែរក្រហមបានយកប្តីរបស់គាត់រួមទាំង អ្នកដែលធ្វើការជាមួយគាត់យកទៅសម្លាប់ហើយ។

## ការរស់នៅភូមិទន្លាប់

ក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅក្នុង ឆ្នាំ១៩៧៥ សូភី ដែលទើបតែឆ្លងទន្លេបានប្រហែលជាបីខែត្រូវ បានបញ្ជូនឲ្យទៅរស់នៅវត្តចំប៉ាស្រុកត្រាំកក់វិញ។ នៅទីនោះ ខ្មែរក្រហមបានសម្លាប់អ្នកចេះដឹង មន្ត្រីរាជការអស់ជាច្រើននាក់ ដោយសារតែអ្នកទាំងនោះជឿការឃោសនាថាឲ្យតែនិយាយការពិត

ប្រាប់អង្គការ នោះអង្គការនឹងឲ្យធ្វើការដូចមុនវិញ ។ ដោយសារតែដឹងសភាពការណ៍មិនស្រួល សូភី មិនបាននិយាយការពិតប្រាប់ទេ ។ ពេលធ្វើដំណើរមកដល់ភូមិទន្លាប់ ខ្មែរក្រហមបានចាត់តាំងឲ្យ សូភី រស់នៅដាច់ដោយឡែកពីឪពុកម្តាយរបស់គាត់ដោយឲ្យស្នាក់នៅក្នុងខ្ទមមួយដែលជាព្រៃគ្មានមនុស្សរស់នៅ ។ បន្ទាប់មកខ្មែរក្រហមបានចាត់តាំងឲ្យ សូភី ធាក់រហាត់ទឹកធ្វើជី (យកឆ្អឹងមនុស្សបុកឲ្យម៉ត់រួចយកលាយជាមួយអាចម៍និងទឹក) និងជីកព្រែក ។ ដោយសារការខិតខំប្រឹងប្រែងធ្វើការខ្លាំងពេក សូភី ក៏មានជំងឺទាស់មិនអាចទៅធ្វើការបណ្តាលឲ្យខ្មែរក្រហមស្តីបន្ទោឲ្យគាត់ថាខ្ជិល ។ ដូច្នេះនៅពេលឈឺម្តងៗ សូភី តែងតែព្រួយបារម្ភពីកូនរបស់គាត់ជានិច្ចរហូតដល់ផ្តាំផ្ញើអឺរបស់គាត់ថា «ប្រសិនបើខ្ញុំស្លាប់ទៅសូមជួយមើលកូនរបស់ខ្ញុំផង» ។ សូភី នៅចាំបានថាថ្ងៃមួយដោយសារតែគ្រុនក្តៅខ្លាំងពេកធ្វើឲ្យវង្វេងវង្វាន់ពេលដែលភ្ញាក់ដឹងខ្លួនស្មានតែម៉ោងមួយរសៀល គាត់ក៏នាំកូនដើរទៅសហករណ៍ដើម្បីសុំបាយហូប ។ ពេលនោះឈ្លបខ្មែរក្រហមបានវាយធ្វើបាបកូនរបស់គាត់យ៉ាងខ្លាំងរួចនិយាយថា «អ្ហែងស៊ីហើយមកដណ្តើមអញទៀត» ។ ទោះបីជាខ្មែរក្រហមទាំងនេះធ្វើអាក្រក់ចំពោះគាត់យ៉ាងណាក៏ដោយ ក៏ប៉ុន្តែនៅតែមានខ្មែរក្រហមមួយចំនួនមានចិត្តល្អដែរដូចជាយាយ ភិន តែងតែលួចដួសបាយឲ្យប្រជាជនថែមទៀតពេលដែលកំពុងហូបបាយប្រសិនបើគាត់ឃើញថាហូបមិនទាន់ឆ្អែត ។ ចំណែក តាអាត់ ដែលជាប្រធានកងរែកដីរបស់គាត់ក៏អ៊ីចឹងដែរ ព្រោះពេលដែលសមាជិកងរបស់គាត់ស្តីឲ្យគាត់ថា «ស៊ីបាយមួយកាដូចគ្នាតែរែកដីមិនរួច» តាអាត់ ក៏និយាយប្រាប់ថា «កូនចៅកុំឈ្លោះគ្នាអី ចាំឪកាប់ដី កូនឯងរែកបានហើយ» ។

## ភូមិក្រាំងត្រែង

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូន សូភី ទៅរស់នៅភូមិក្រាំងត្រែងក្រោមការគ្រប់គ្រងរបស់ប្រធានភូមិឈ្មោះ ឡៃ ។ ការរស់នៅទីនេះមានលក្ខណៈធូរជាងកន្លែងមុនដោយសារតែប្រធានភូមិចិត្តល្អចំពោះប្រជាជន ។ នៅពេលប្រមូលផលស្រូវបានប្រធានភូមិបានយកស្រូវទាំងនោះទុកខ្លះសម្រាប់ឲ្យប្រជាជនហូបពេលខ្វះស្បៀង ។ ដូច្នេះ សូភី អាចលួចយកបន្លែខ្លះយកទៅស្ងោរហូបនិងអាចសុំអង្ករពីសហករណ៍ហូបបាន ។ ទោះបីជាធ្វើការមិនសូវធ្ងន់និងហូបចុកគ្រប់គ្រាន់ក៏ដោយ ក៏ សូភី ចាប់ផ្តើមព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនផងដែរពីព្រោះខ្មែរក្រហមបានប្រមូលជនជាតិចិនយកទៅសម្លាប់ជាច្រើនគ្រួសារ ក្រោយមកក៏យកប្រជាជននៅក្នុងភូមិទៅសម្លាប់ទៀតដោយចោទថាក្បាលយួនខ្លួនខ្មែរ ។

ក្រោយពីកងទ័ពវៀតណាមចូលមករំដោះ សូភី ធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។ សូភី ត្រេកអរជាខ្លាំងដែលគាត់អាចមានជីវិតត្រឡប់មកជួបឪពុកម្តាយនិងបងប្អូន ។ ប៉ុន្តែ សូភី នៅតែមានការសោកស្តាយជាអតិបរមាពីព្រោះប្អូនៗរបស់គាត់ពីរនាក់បានស្លាប់ដោយសារអត់បាយនិងម្នាក់ទៀតបាត់ខ្លួនចំណែកប្តីរបស់គាត់ក៏ស្លាប់ទៀត ។ ដោយសារតែស្រឡាញ់ជំនាញផ្នែកអប់រំនិងយល់ឃើញថា ក្រោយពីរបបនេះដួលរលំទៅអ្នកចេះដឹងត្រូវបានសម្លាប់ស្ទើរតែអស់ទៅហើយ នៅឆ្នាំ១៩៨០ សូភី ដាក់ពាក្យធ្វើជាគ្រូបង្រៀនផ្នែកប្រវត្តិ-ភូមិវិទ្យា ដើម្បីអប់រំក្មេងជំនាន់ក្រោយឲ្យដឹងពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ជាពិសេសផងដែរនោះបណ្តុះគំនិតឲ្យស្រឡាញ់ជាតិមាតុភូមិខ្លួនដើម្បីស្តារប្រទេសដែលទើបតែបែកបាក់ឡើងវិញ ។ **គាត លក្ខិណា**

## សេចក្តីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហោង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្តាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៨ឬ១៥ឆ្នាំប៉ុណ្ណោះ រួចបានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។

ប្រសិនបើប្អូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ**

# ការពិតដែលលាក់ទុកអស់រយៈពេល៣១ឆ្នាំ

យ៉ុន ផល សព្វថ្ងៃរស់នៅស្រុកពាមរក៍ ខេត្តព្រៃវែង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ផល ត្រូវបានកងទ័ពខ្មែរក្រហមរកលេសដើម្បីធ្វើបាបគាត់រហូត ។ ដូច្នេះបទពិសោធន៍ដែល ផល បានឆ្លងកាត់ធ្វើឲ្យគាត់មានការឈឺចាប់យ៉ាងខ្លាំងរហូតដល់គាត់មិនដែលរំពុករឿងនេះប្រាប់កូនៗឬក៏អ្នកដទៃឲ្យបានដឹងឡើយ ។ ប៉ុន្តែឥឡូវនេះទើប ផល ហ៊ាននិយាយរឿងក្នុងចិត្តរបស់គាត់ចេញមកដែលធ្វើឲ្យគាត់មានអារម្មណ៍ធូរស្រាលជាងមុន ថែមទាំងបានគេងលក់ស្រួលទៀត ។

ផល មានបងប្អូនចំនួន១០នាក់ ដែលក្នុងចំណោមនោះ ផល គឺជាកូនរៀនបានខ្ពស់ជាងគេនៅក្នុងគ្រួសារ ព្រោះគាត់បានផ្លាស់មករៀននៅភ្នំពេញរហូតដល់ថ្នាក់ទី១ (បច្ចុប្បន្នថ្នាក់ទី១១) ។ ក្រោយពីកងទ័ពខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ឲ្យចាកចេញពីក្រុងដោយប្រកាសថាទៅតែរយៈពេលបីថ្ងៃប៉ុណ្ណោះនឹងបានត្រឡប់មកវិញ ។ ដោយសារតែស្ថានភាពប្រទេសច្របូលច្របល់បែបនេះ ផល ក៏ឈប់រៀនរួចធ្វើដំណើរត្រឡប់ទៅស្រុកកំណើតដើម្បីជួបជុំគ្រួសារនៅខេត្តព្រៃវែងវិញ ។ ប៉ុន្តែពេលធ្វើដំណើរមកដល់ភូមិទង់នាគ ឃុំស្ដៅកោង ស្រុកបាភ្នំ គាត់ក៏បានជួបឪពុកម្ដាយរបស់គាត់នៅទីនោះ ។ គ្រាន់តែឃើញ ផល ភ្លាមម្ដាយរបស់គាត់នឹកព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់ជាខ្លាំងរួចបានខ្សឹបប្រាប់គាត់ថា «គេសួរអីក៏ដោយកូនគ្រាន់តែឆ្លើយថាកូនជាសិស្សបានហើយ បើកូនឆ្លើយខុសពីហ្នឹងប្រយ័ត្នគេយកទៅសម្លាប់ចោល» ។ ក្រោយពីប្រាប់បានរយៈពេលបីថ្ងៃ ប្រធានសហករណ៍ឈ្មោះ មិត្តគង់ ក៏មកដល់ផ្ទះរបស់ ផល រួចសួរថា មិត្តឯងធ្វើការអីពីមុនមក? ពេលឮភ្លាម ផល នឹកឃើញដល់សម្ដីរបស់ម្ដាយគាត់រួចក៏ឆ្លើយថា «ខ្ញុំជាសិស្សសាលា» ។ មួយសប្ដាហ៍ក្រោយមកមិត្ត គង់ បានដើរមកសួរ ផល ម្ដងទៀតដោយប្រើពាក្យលួងលោមថា «មិត្តឯងប្រាប់ឲ្យត្រង់មក មិត្តឯងធ្វើអីពីមុន ខ្ញុំមិនធ្វើអីមិត្តឯងទេ?» ទោះបីជាបញ្ចុះបញ្ចូលយ៉ាងណាក៏ដោយ ក៏ ផល មិន ជឿពាក្យទាំងនេះដែរដោយគាត់នៅតែឆ្លើយចម្លើយដដែល ។ ដោយនៅតែមិនអស់ចិត្ត មួយរយៈក្រោយមក មិត្តចាប ដែលជាប្រធានសហករណ៍បានមកសួរ ផល ទៀត ។ លើកនេះ ផល នៅតែឆ្លើយចម្លើយដដែលថាគាត់ជាកូនសិស្ស ទើបប្រធានសហករណ៍ជឿ ហើយឈប់តាមដានគាត់តទៅទៀត ។



យ៉ុន ផល

បន្ទាប់មក ខ្មែរក្រហមបានចាត់តាំង ផល ឲ្យចូលកងចល័តស្ថិតនៅឃុំស្ដៅកោងមានតួនាទី វែកដី ជីកប្រឡាយ និងលើកភ្លឺស្រែ ។ ចំណែកម្ដាយធ្វើជីលេខ១ (ជីលាមកមនុស្ស) ។ ដោយសារតែធ្វើការហត់អស់កម្លាំងនិងគ្មានពេលមើលថែទាំកូនឲ្យបានដិតដល់ មួយរយៈក្រោយមកប្អូនទាំងបីនាក់របស់ ផល ដែលនៅតូចៗនៅឡើយបានស្លាប់ជាបន្តបន្ទាប់ ។

នៅទីនេះ ទោះបីជា ផល ខិតខំធ្វើការមិនដែលឲ្យអង្គការស្ដីបន្ទោសក៏ដោយប៉ុន្តែប្រធានកងឈ្មោះ គី តែងតែរកលេសដើម្បីធ្វើបាបគាត់ជានិច្ច ។ ផល បានរំពុកថា ថ្ងៃមួយស្រាប់តែ គី បានទៅសួរមិត្តនារីឈ្មោះ ស ថា ផល ស្នើមិត្តនារីឯងរៀបការតើមិត្ត

នារីឯងព្រមទទួល ផល ទេ? ដោយសារឃើញមិត្ត ផល ជាមនុស្សល្អនិងខស្សាហ៍ព្យាយាមនៅក្នុងការងារ មិត្តស បានឆ្លើយយល់ព្រមភ្លាម ។ បន្ទាប់មក គឺ បានមកប្រាប់ ផល ឲ្យទៅរកសម្លៀកបំពាក់ថ្មី និងក្រមាក្រហម ដើម្បីត្រៀមខ្លួនរៀបការជាមួយមិត្តនារីស ។ ពេលនោះ ផល មានការភ្ញាក់ផ្អើលជាខ្លាំងព្រោះគាត់មិនដែលបាននិយាយពាក្យទាំងនេះទាល់តែសោះ ។ ដោយសារតែពិបាកចិត្តខ្លាំងពេកនិងមិនដឹងថាដោះស្រាយយ៉ាងណា ផល ក៏ លួចរត់មកជួបម្តាយដើម្បីពិភាក្សាអំពីរឿងនេះ ។ ទោះបីជាដឹងថាមិនអាចប្រឆាំងនឹងបញ្ហានេះក៏ដោយ ប៉ុន្តែ ផល បាននិយាយយ៉ាងម៉ឺងម៉ាត់ថា «ខ្ញុំសុខចិត្តស្លាប់ ក៏ខ្ញុំមិនរៀបការដែរ» ។ ពីរថ្ងៃក្រោយមក ផល នៅតែប្រកែកមិនព្រមរៀបការដដែល ។ ដោយសារតែខឹងនឹង ផល មិនព្រមធ្វើតាមបញ្ជារបស់ខ្លួន គឺ មានបំណងចង់យក ផល ទៅសម្លាប់ចោល ។ ប៉ុន្តែដោយមានការធានាអះអាងពីសមាជិកកងរបស់គាត់ថា ផល ខស្សាហ៍ធ្វើការងារណាស់ទើបគាត់ផ្លាស់ប្តូរគំនិតនេះវិញ ។

ទោះបីជា ផល រួចផុតពីការស្លាប់ក៏ដោយ តែ គឺ នៅតែតាមធ្វើបាបគាត់ជានិច្ច ហើយបានបញ្ជូនគាត់ឲ្យទៅធ្វើការនៅខាងត្បូងភ្នំឈើកាច់ ។ នៅទីនេះ ការរស់នៅកាន់តែមានការលំបាកជាងមុនទៅទៀត ព្រោះខ្មែរក្រហមបានចាត់តាំងឲ្យ ផល ធ្វើការធ្ងន់ៗ ដូចជារែកដីមួយអម្រែកមានទម្ងន់ប្រហែលជា៤០ គីឡូក្រាម និងឲ្យហូបតែបបររាវពីរវែកក្នុងមួយថ្ងៃប៉ុណ្ណោះ ។ ដោយសារតែដឹងថានេះជាលេសដើម្បីដាក់ទណ្ឌកម្មគាត់ ដូច្នេះទោះបីជាឈឺធ្ងន់យ៉ាងណាក៏ដោយ ក៏ គាត់មិនដែលហ៊ានសុំច្បាប់ឈប់សម្រាកឡើយ ។

ធ្វើការបានមួយរយៈ ប្រធានសហករណ៍ឈ្មោះ ចាប បានបង្ខំឲ្យ ផល រៀបការជាមួយមិត្តនារីម្នាក់ទៀត ឈ្មោះ រស់ ។ លើកនេះ ដោយសារគិតឃើញថាមិនអាចទ្រាំទ្រនឹងទណ្ឌកម្មនេះបាន និងខ្លាចខ្មែរក្រហមយកទៅសម្លាប់ផង ផល ក៏បង្ខំចិត្តរៀបការជាមួយនារី រស់ ។ ក្រោយពីរៀបការជាមួយគ្នាបានមួយយប់ស្អែកឡើងខ្មែរក្រហមក៏បំបែកឲ្យទៅធ្វើការនៅតាមកងរៀងៗខ្លួនរយៈពេល១០ថ្ងៃក្រោយមកទើបឲ្យជួបគ្នាម្តង ។ ទោះបីជា ផល មិនបានស្រឡាញ់ប្រពន្ធរបស់គាត់ក៏ដោយ ប៉ុន្តែដោយទឹកចិត្តអាណិតជាងស្រឡាញ់ រស់, ផល ក៏ព្រមរស់នៅជាមួយប្រពន្ធរបស់គាត់រហូតមកដល់សព្វថ្ងៃ ។

នៅដើមឆ្នាំ១៩៧៨ ដោយសារតែការមិនទុកចិត្តគ្នា និងសង្ស័យថាក្បត់ ខ្មែរក្រហមចាប់ផ្តើមចាប់ប្រជាជនយកទៅសម្លាប់ជារៀងរាល់ថ្ងៃ ដែលក្នុងចំណោមនោះក៏មានប្រធានសហករណ៍និងប្រធានកងផងដែរ ។ ពេលនោះ ប្រជាជននៅក្នុងភូមិមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះមិនដឹងថាពេលណាដល់វេនរបស់ខ្លួន ។ មិនយូរប៉ុន្មាន រឿងនេះក៏កើតលើខ្លួន ផល ដោយខ្មែរក្រហមបានចោទប្រកាន់គាត់ថាជាខ្សែសេអ៊ីអា ។ ក្រោយពីឃើញសភាពការណ៍មិនស្រួល ផល បានរត់ចោលប្រពន្ធមកលាក់ខ្លួននៅភូមិកំណើតវិញ ។

ក្រោយពីកងទ័ពវៀតណាមវាយរំដោះប្រទេសបាន នៅឆ្នាំ១៩៧៩ ផល និងប្រពន្ធ ព្រមទាំងឪពុកម្តាយរបស់គាត់បាននាំគ្នាធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។ នៅឆ្នាំ១៩៨១ ផល បានធ្វើជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា ។ ទោះបីជារបបខ្មែរក្រហមបានដួលរលំអស់រយៈពេល៣០ឆ្នាំហើយក៏ដោយ ប៉ុន្តែ ផល មិនដែលយករឿងនេះមកនិយាយប្រាប់កូនៗរបស់គាត់ឡើយ ផល បានរៀបរាប់ទាំងទឹកមុខស្រងូតស្រងាត់ថា «ខ្ញុំបានលាក់ទុករឿងដែលខ្ញុំបានឆ្លងកាត់ពីកាលពីសម័យ ប៉ុល ពត ដោយសារតែខ្ញុំមិនចង់គាស់កកាយសាឡើងវិញ ។ ម្យ៉ាងទៀត នៅពេលដែលខ្ញុំតែនឹកឃើញពីអតីតកាលដ៏ខ្មៅងងឹតនេះម្តងៗ តែងតែធ្វើឲ្យខ្ញុំគិតច្រើនរហូតដល់ដេកមិនលក់ស្ទើររាល់យប់ ។ ឥឡូវនេះ ពេលដែលបាននិយាយរឿងទាំងនេះចេញមក ខ្ញុំមានអារម្មណ៍ធូរស្រាលក្នុងចិត្តច្រើនណាស់» ។

ផល ស្ទើរតែមិនជឿថា ទើបតែពេលចូលរៀនវគ្គបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះទេដែលធ្វើឲ្យគាត់ក្លាហាននិយាយរឿងនេះ ។ ចុងក្រោយ ផល បានរៀបរាប់ថា កម្មវិធីនេះពិតជាមានសារសំខាន់ជាខ្លាំង សម្រាប់អប់រំក្មេងជំនាន់ក្រោយឲ្យបានដឹងអំពីប្រវត្តិសាស្ត្រដ៏សាហាវឃោរឃៅរបស់ខ្មែរក្រហម ជាពិសេសអាចទប់ស្កាត់និងបញ្ចៀសមិនឲ្យកើតឡើងវាជាលើកទីពីរទៀត ។

**ស សេងគា**

# ពិព័រណ៌សំណុំរឿង០០២

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ខាងមុខ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការខ្មែរក្រហមនឹងប្រកាសសាលក្រមសំណុំរឿង០០១ ឌុច អតីតប្រធានមន្ទីរស-២១ ឬគុកទួលស្លែង ដែលធ្វើឲ្យអ្នកទោសប្រមាណ១៨.០០០នាក់ស្លាប់ ។ នៅមុនពេលសាលក្រមប្រកាសជាផ្លូវការ មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំពិធីតាំងពិព័រណ៌រយៈពេលប្រាំមួយខែចាប់តាំងពីខែដើមមិថុនា នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងអំពីសំណុំរឿង០០២ទាក់ទងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបួនរូប គឺ នួន ជា អតីតប្រធានសភាជាតិ, ខៀវ សំផន គណៈប្រធានរដ្ឋ, អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស និង អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដែលទទួលខុសត្រូវក្នុងការស្លាប់ប្រជាជនស្លូតត្រង់ប្រមាណជិតពីរលាននាក់ ហើយរំពឹងថាតុលាការនឹងធ្វើការកាត់ទោសនៅចុងឆ្នាំ២០១០ឬដើមឆ្នាំ២០១១ ។ ពិព័រណ៌នេះនឹង ផ្សព្វផ្សាយដល់ប្រជាជនកម្ពុជា និងអន្តរជាតិឲ្យយល់ដឹងនិងតាមដានកាន់តែច្រើនពីដំណើរការរបស់តុលាការដែលកំពុងរកយុត្តិធម៌ជូនជនរងគ្រោះ ។

ដឹនីហ៊័រ ជនជាតិអាមេរិកបានរៀបរាប់ថា «ខ្ញុំអានសៀវភៅជាច្រើនដែលនិយាយពីប្រទេសនៅអាស៊ីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំង ។ ខ្ញុំបានដឹងពីរបបខ្មែរក្រហម ប៉ុន្តែមិនបានដឹងច្រើនដូចពេលនេះទេ ។ ខ្ញុំបានដឹងរឿងរ៉ាវដែលកើតឡើងក្នុងគុកទួលស្លែង ។ ខ្ញុំគិតថាវាជាការប្រសើរដែលប្រជាជនបានដឹងរឿងនេះ ហើយក៏គួរតែប្រាប់ប្រជាជននៅក្នុងសហគមន៍របស់គាត់ដែរ ។ មេដឹកនាំខ្មែរក្រហមបានចំណាយពេលយ៉ាងច្រើនដើម្បីរំដោះនិងគ្រប់គ្រងប្រទេស ដោយដំបូងហាក់ដូចជាធ្វើត្រឹមត្រូវសម្រាប់ប្រជាជន ប៉ុន្តែជាផលអវិជ្ជមានដែលបានសម្លាប់ប្រជាជន ។ របបខ្មែរក្រហមគំរាមកំហែងដល់ពិភពលោក ដូច្នេះប្រជាជនត្រូវ


អ្នកទស្សនាការតាំងពិព័រណ៌ករណី០០២ នៅទួលស្លែង

ទទួលការអប់រំពីរឿងរ៉ាវនេះ ដើម្បីឲ្យដឹងថាតើមានអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយនឹងដឹងថាអ្វីដែលគួរធ្វើ និងមិនគួរធ្វើ ។ ខ្ញុំមានការភ្ញាក់ផ្អើលថា មេដឹកនាំទាំងនេះមិនត្រូវបានសម្លាប់ពេលដែលធ្លាក់ពីអំណាច ។ មេដឹកនាំទាំងនេះត្រូវបង្ហាញភ័ស្តុតាងនិងទទួលខុសត្រូវនូវអ្វីដែលបានធ្វើ ។ ខ្ញុំសង្ឃឹមថាតុលាការនឹងធ្វើការងារនេះ» ។

ចំណែកនិស្សិតខ្មែរម្នាក់ឈ្មោះ លីដា ក៏បានរៀបរាប់ថា នេះជាលើកទីមួយដែលខ្ញុំបានចូលមកទស្សនាសារមន្ទីរទួលស្លែងនេះ ។ លីដា មានអារម្មណ៍តក់ស្លុតជាខ្លាំង នៅពេលដែលបានឃើញរូបថតរបស់អ្នកទោស ឧបករណ៍ធ្វើទារុណកម្ម ព្រមទាំងលលាដ៍ក្បាលដែលតាំងនៅខាងក្នុងនោះ ។ លីដា យល់ថា របបនេះបានសម្លាប់មនុស្សយ៉ាងសាហាវឃោរឃៅ ដូច្នេះហើយមេដឹកនាំទាំងអស់នេះត្រូវតែទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនិងត្រូវតែកាត់ទោសឲ្យបានធ្ងន់ធ្ងរជាទីបំផុតដើម្បីឲ្យអ្នកដែលស្លាប់ទៅបានអស់ចិត្តនិងអ្នកដែលរស់រានមានជីវិតបានរសាយពីកំហឹងផងដែរ ។ លីដា បន្តថា «ឥឡូវនៅពេលដែលមានការតាំងពិព័រណ៍អំពីសំណុំរឿង០០២នេះកាន់តែធ្វើឲ្យខ្ញុំចង់ដឹងថែមទៀតអំពីដំណើរការរបស់តុលាការនេះ ជាពិសេសថាតើមេដឹកនាំទាំងនេះទទួលស្គាល់ការប្រព្រឹត្តរបស់ខ្លួនចំពោះមុខអង្គជំនុំជម្រះ និងសាធារណជនដែរឬទេ?» ចុងក្រោយ លីដា បានបន្ថែមថា «ទោះបីជាខ្ញុំកើតមិនទាន់របបខ្មែរក្រហមក៏ដោយ ប៉ុន្តែក្រោយពីបានឃើញការតាំងពិព័រណ៍នេះ ធ្វើឲ្យខ្ញុំក៏ដូចជាប្រជាជនផ្សេងទៀតបានដឹងនិងចង់តាមដានពីដំណើរការតុលាការនេះជាខ្លាំង ព្រោះជាគំរូកុំឲ្យក្មេងជំនាន់ក្រោយប្រព្រឹត្តអំពើបែបនេះទៀត» ។

នៅអង្គសវនាការសាលាដំបូង មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបួនរូបតែងតែបដិសេធចំពោះរាល់បទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាក់ទងនឹងការធ្វើឲ្យប្រជាជនស្លូតត្រង់ស្លាប់ និងបទឧក្រិដ្ឋផ្សេងទៀត ដោយបានអះអាងថា មិនបានដឹងពីការកាប់សម្លាប់ទាំងនេះ ។ សព្វថ្ងៃនេះ ប្រជាជនកម្ពុជានៅតែមានការព្រួយបារម្ភពីដំណើរការយុត្តិធម៌នឹងត្រូវពន្យារពេល ហើយមេដឹកនាំខ្មែរក្រហមដែលមានវ័យកាន់តែច្រើនអាចស្លាប់នៅមុនពេលកាត់ទោសថែមទៀត ។ **សោម ប៊ុនថន គាត លក្ខិណា និង ជា ផល្លា**



អ្នកទស្សនាការតាំងពិព័រណ៍ករណី០០២ នៅទួលស្លែង

# កែវ សុខា : រួចរស់ជីវិតដោយសារលាក់បាំងប្រវត្តិរូប

កែវ សុខា សព្វថ្ងៃរស់នៅស្រុកបាទី ខេត្តតាកែវ ។ ក្រោយពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ សុខា ព្យាយាមលាក់បាំងអត្តសញ្ញាណរបស់ខ្លួនដោយមិនឲ្យកងទ័ពខ្មែរក្រហមដឹងឡើយ ។ លើសពីនេះទៅទៀត សុខា ខិតខំធ្វើការតាមបញ្ជារបស់អង្គការដោយមិនឲ្យខ្មែរក្រហមយកទោសពៃរ៍ទេ ។

## ចូលធ្វើទាហាន លន់ នល់

សុខា មានបងប្អូនប្រុសពីរនាក់ ។ សុខា ជាកូនច្បងនៅក្នុងគ្រួសារ ដូច្នេះហើយនៅពេលដែលមានអាយុ១៨ឆ្នាំ ឪពុកម្តាយរបស់គាត់បានបញ្ជូនគាត់ឲ្យទៅបួសនៅវត្តដីក្រហម ។ សុខា គោរពវិន័យបានល្អណាស់ដោយខិតខំរៀនធម៌បាលីសំស្ក្រឹតតាមបង្គាប់របស់ចៅអធិការវត្ត ព្រមទាំងរៀនចំណេះវិជ្ជាទូទៅនិងជួយធ្វើការងារផ្សេងៗទៀត ។ ដោយសារ សុខា ជាសិស្សដែលឆ្លាតនិងរៀនពូកែនៅក្នុងថ្នាក់ ឪពុកម្តាយរបស់គាត់បានបញ្ជូនគាត់មករៀននៅក្រុងភ្នំពេញទៀត ដោយឲ្យស្នាក់នៅក្នុងវត្តកោះ ។ ក្រោយពីប្រឡងជាប់សញ្ញាបត្រទុតិយភូមិ សុខា បានស្ម័គ្រចិត្តចូលធ្វើទាហាន លន់ នល់ ។ សុខា រួមទាំងទាហានផ្សេងទៀតត្រូវបានបញ្ជូនឲ្យហាត់ហ្វឹកហ្វឺននៅអំពែភ្នំ ស្ថិតក្នុងកងពលលេខ៧ វរសេនាតូចលេខ៨៩ ក្រោមការគ្រប់គ្រងរបស់ឧត្តមសេនីយ៍ អ៊ុន កុវ ។ នៅទីនោះកងទ័ពទាំងអស់ត្រូវរៀនពីរបៀបក្រាបលូននិងបាញ់កាំភ្លើង ។ រយៈពេល៦ខែក្រោយមកពីហាត់រៀនស្ទាត់ហើយ កងទ័ពទាំងអស់ត្រូវបានបញ្ជូនឲ្យទៅប្រយុទ្ធនៅសមរភូមិក្រោមបញ្ជារបស់ឧត្តមសេនីយ៍ ថាច់ រ៉េន ។ សុខា បានចេញទៅប្រយុទ្ធជាច្រើនកន្លែង ដូចជា នៅកំពង់ទួល (ផ្លូវជាតិលេខ៣) ព្រែកតាម៉ាក់ ត្រពាំងព្រាយ ជាដើម ។ ប៉ុន្តែ ក្នុងចំណោមទីតាំងប្រយុទ្ធទាំងអស់មានតែត្រពាំងព្រាយទេដែលជាទីតាំងក្តៅជាងគេដោយខ្មែរក្រហមបានមកព័ទ្ធកងទ័ពទាហាន លន់ នល់ រយៈពេលមួយសប្តាហ៍រហូតដល់មានកងមានទ័ពជំនួយមកដល់ទើបកងទ័ព លន់ នល់ អាចដកខ្លួនបាន ។ ប៉ុន្តែ ទោះបីជាមានការខំប្រឹងប្រយុទ្ធយ៉ាងខ្លាំងក្លាជាមួយកងទ័ពខ្មែរក្រហមក៏ដោយ ក៏នៅទីបំផុតខ្មែរក្រហមនៅតែទទួលជោគជ័យនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ដដែល ។ ដោយសារឃើញសភាពការណ៍មិនស្រួលបែបនេះ សុខា ក៏ធ្វើដំណើរត្រឡប់មករកឪពុកម្តាយនៅស្រុកកំណើតវិញ ។ ប៉ុន្តែនៅតាមផ្លូវមានមនុស្សកកកុញច្រើនពេក ដូច្នេះ សុខា បានសម្រេចចិត្តមកនៅស្នាក់នៅព្រែកតូចរយៈពេលបីខែសិន ទើបធ្វើដំណើរមកដល់ភូមិកំណើត ។

## ព្រឹត្តិការណ៍នៅក្នុងភូមិ

ពេលធ្វើដំណើរមកដល់ក្នុងភូមិទើប សុខា ដឹងថាខ្មែរក្រហមបានចូលមកកាន់កាប់ភូមិនេះតាំងពីឆ្នាំ១៩៧១ម្ល៉េះ ។ បន្ទាប់មកខ្មែរក្រហមបានកៀរប្រជាជនទាំងអស់ឲ្យទៅរស់នៅភូមិអង្គស្វាយ



កែវ សុខា

ចេកដែលមានចម្ងាយប្រហែលជា៣០គីឡូម៉ែត្រពីភូមិកំណើតរបស់គាត់ ។ ពេលនោះ ដោយសារតែមានប្រជាជនមួយចំនួនមិនព្រមចាកចេញ ខ្មែរក្រហមបានដុតផ្ទះដែលមាននៅក្នុងភូមិចោលទាំងអស់ ។ លើសពីនេះទៅទៀត ខ្មែរក្រហមបានបាញ់សម្លាប់អ្នកភូមិម្នាក់ឈ្មោះ មឿន នៅចំពោះមុខប្រជាជនដើម្បីគំរាមប្រជាជនផ្សេងទៀតឲ្យប្រញាប់ចាកចេញ ។ ក្រោយពីឃើញព្រឹត្តិការណ៍នេះ គ្រួសាររបស់ សុខា ព្រមទាំងគ្រួសារដទៃទៀតនាំគ្នារៀបចំរបស់របរមួយចំនួនដូចជា អង្ករ សម្លៀកបំពាក់ ជាដើម និងរបស់មានតម្លៃបន្តិចបន្តួចដាក់លើរទេះគោធ្វើដំណើរទៅភូមិអង្គស្វាយចេក ។ ទៅដល់ទីនោះ ខ្មែរក្រហមបានជ្រើសរើសក្មេងប្រុសៗដែលមានអាយុចាប់ពី១៨ឆ្នាំឡើងឲ្យចូលបម្រើកងទ័ពដែលសរុបមានប្រហែលជាង៤០នាក់ (សព្វថ្ងៃនេះនៅរស់ប្រហែល២៨នាក់) និងក្មេងស្រីៗខ្លះចាត់តាំងឲ្យធ្វើពេទ្យ និងខ្លះទៀតទៅធ្វើស្រែអំបិល ។ ចំណែកការរស់នៅវិញ ប្រជាជនទាំងអស់ត្រូវធ្វើស្រែប្រវាស់ដៃ ក្រៅពីនេះលើកទំនប់និងកាប់ផ្លូវដើម្បីកុំឲ្យទាហាន លន់ នល់ ចូលមកដល់ដោយស្រួលពេក ។

## ការរស់នៅក្នុងភូមិត្រពាំងលើ

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញទៅភូមិត្រពាំងលើ ។ នៅទីនោះ ខ្មែរក្រហមបានបំបែកក្រុមគ្រួសាររបស់ សុខា ឲ្យទៅធ្វើការតាមកងផ្សេងៗ ។ សុខា ត្រូវបានចាត់តាំងឲ្យចូលកងចល័តដែលមានគ្នាចំនួន៣០នាក់មានតួនាទីធ្វើស្រែ ជីកព្រែក និង លើកទំនប់ ក្រោមការគ្រប់គ្រងរបស់គណៈកម្មការភូមិឈ្មោះ អឿន, ខន និង សឿន ។ ដោយសារតែការហូបចុកមិនបានគ្រប់គ្រាន់ មួយរយៈក្រោយមកមានប្រជាជនមួយចំនួនបានធ្លាក់ខ្លួនឈឺនិងធ្វើការមិនគ្រប់តាមផែនការកំណត់ ។ ដូច្នេះ ខ្មែរក្រហមបានហៅអ្នកទាំងនេះយកទៅកសាងជាច្រើនលើក ហើយបើនៅតែធ្វើមិនបានទៀត អ្នកទាំងនោះនឹងត្រូវបាត់ខ្លួន ឬចាប់យកទៅដាក់គុកនៅវត្តកកោះមានឈ្មោះថា (សូភី) ជាមិនខាន ។ សុខា បានរំឭកពីគុកសូភីយ៉ាងក្តុកក្តួលក្នុងចិត្តថា នៅវេលាយប់ឡើងគាត់តែងតែឮសំឡេងស្រែកថ្ងូររបស់អ្នកទោសជាមួយនឹងសំឡេងចាក់មីក្រូបន្ទំចេញពីគុកនេះដែលធ្វើឲ្យគាត់ភ័យខ្លាចជាខ្លាំង ។ លើសពីនេះទៅទៀត ខណៈពេលកំពុងធ្វើការ សុខា បានឃើញខ្មែរក្រហមសម្លាប់មនុស្សជាញឹកញាប់នៅចំពោះមុខដោយភាគច្រើនអ្នកទាំងនោះសុទ្ធតែគ្មានកំហុស ។ សុខា នៅចាំបានថាថ្ងៃមួយពេលដែលកំពុងតែលើកទំនប់ ស្រាប់តែឃើញឈ្លបខ្មែរក្រហមដើរមក រួចចោទសមាជិកកងចល័តរបស់គាត់ម្នាក់ឈ្មោះ រី ថាក្បត់អង្គការ ។ ដោយសារតែដឹងថាមិនអាចមានជីវិតត្រឡប់មកវិញ រី បានតដៃជាមួយនឹងឈ្លបនោះ ។ មួយសន្ទុះក្រោយមកឈ្លបនោះក៏បាញ់សម្លាប់ រី នៅចំពោះមុខប្រជាជនទាំងអស់តែម្តង ។ សុខា បានបន្តថា «គ្រាន់តែឃើញ រី ស្លាប់ភ្លាមខ្ញុំនិងប្រជាជនឯទៀតមានការតក់ស្លុតជាខ្លាំងដោយម្នាក់ៗខិតខំធ្វើការយ៉ាងរហ័សរហួនទោះបីជាហេវហត់អស់កម្លាំងយ៉ាងណាក៏ដោយ» ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់ផ្តើមប្រកាសប្រាប់ប្រជាជនឲ្យនិយាយការពិតទៅអង្គការអំពីតួនាទី ឬតំណែងដែលបានធ្វើពីមុនព្រមទាំងការរៀនសូត្រដល់ថ្នាក់ណា ។ ដោយសារតែឪពុកមារបស់ សុខា ប្រាប់ថា «ប្រសិនបើអង្គការហៅសួរថាបានរៀនដល់ថ្នាក់ណាត្រូវតែប្រយ័ត្នប្រយែង បើមិនអ៊ីចឹងទេ អ្ហែងនឹងស្លាប់ហើយ» ដូច្នេះពេលដែលហៅទៅសួរម្តងៗ សុខា តែងតែឆ្លើយថា គាត់រៀនបានត្រឹមថ្នាក់ទីមួយប៉ុណ្ណោះ ។ ចំណែកអ្នកដែលប្រាប់ការពិតទៅអង្គការ ភាគច្រើនសុទ្ធតែត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងអស់ដែលក្នុងនោះក៏មានពូរបស់គាត់ម្នាក់ឈ្មោះ អែម ផងដែរ ។ ក្រោយពីស៊ើបសួរជាច្រើនលើកហើយ សុខា នៅតែឆ្លើយដដែលៗអង្គការក៏ជឿ ហើយលែងតាមដានគាត់រហូត ។

## ឡើងប្តេជ្ញាចិត្ត

នៅខែតុលា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានប្រមូលយុវជននិងយុវនារីដែលនៅលីវទាំងអស់ឲ្យរៀបការជាមួយគ្នា ។ នៅពេលនោះ ទោះបីជាមិនបានស្គាល់គ្នាពីមុនក៏ដោយ ក៏ត្រូវតែរៀបការតាមបញ្ជារបស់អង្គការដែរ ។ ប៉ុន្តែ សុខា សំណាងជាងអ្នកដទៃដោយគាត់មិនត្រូវបានចាប់បង្ខំនោះទេ ព្រោះភាគីទាំងសងខាងបានស្ម័គ្រចិត្តរួចក៏ស្នើទៅអង្គការ ។ ថ្ងៃនោះ ពេលដល់គូរបស់គាត់ទី៤០ គាត់និងប្រពន្ធរបស់គាត់ឈ្មោះ ជុំ ទូច បានឲ្យឡើងប្តេជ្ញាចិត្តនៅចំពោះមុខអង្គការថាគាត់នឹងស្រឡាញ់មិត្ត ទូច អស់មួយជីវិត ។ គាត់នឹងស្មោះត្រង់ចំពោះអង្គការមួយជីវិត ។ ក្រោយពីពិធីរៀប

ការបានបញ្ចប់ ខ្មែរក្រហមបានចុះមកតាមដាននៅតាមផ្ទះអ្នកដែលទើបរៀបការថ្មីៗទាំងអស់ព្រោះប្រសិនបើមិនចុះសម្រុងនឹងគ្នា ស្អែកឡើងអង្គការនឹងយកទៅសម្លាប់ហើយ ។ ក្រោយពីរស់នៅជាមួយគ្នាបានរយៈពេលមួយខែ ខ្មែរក្រហមបានបញ្ជូនអ្នកដែលរៀបការថ្មីៗនេះទៅធ្វើការនៅកន្លែងថ្មីមួយទៀត ។ ពេលនោះ គ្រួសាររបស់ សុខា និង១០គ្រួសារទៀតត្រូវបបញ្ជូនឲ្យធ្វើការនៅចម្ការនៅតាខ្មៅ ។ នៅទីនោះ ការរស់នៅស្រួលជាងកន្លែងមុនបន្តិចដោយសារតែមិនសូវធ្វើការធ្ងន់ថែមទាំងទទួលរបបអាហារបានច្រើនជាងមុនបន្តិច ។

នៅឆ្នាំ១៩៧៩ ក្រោយពីដឹងថាវៀតណាមបានចូលមកភ្លាម សុខា ក៏នាំប្រពន្ធត្រឡប់មកស្រុកកំណើតវិញ ។ ដោយសារ សុខា រៀនបានច្រើនជាងគេនៅក្នុងភូមិគាត់ ក៏ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានភូមិបន្ទាប់មកធ្វើប្រធានឃុំ ។ ប៉ុន្តែការងារនេះមានការមមាញឹកខ្លាំងពេក សុខា ក៏សម្រេចចិត្តផ្លាស់មកធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាបន្ទាយត្រាវវិញ ។ ដោយសារតែចង់ស្វែងយល់ឲ្យបានច្បាស់ពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនក៏ដូចជាប្រទេសដទៃ នៅឆ្នាំ១៩៨៤ សុខា បានរៀនមកបន្តយកជំនាញប្រវត្តិនិងភូមិ នៅសាលាគរុកោសល្យភូមិភាគបន្ថែមទៀត ។ ឥឡូវនេះ ពេលដែល សុខា ត្រូវបានជ្រើសរើសឲ្យមកចូលរៀននៅវគ្គបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគាត់យល់ថា «កម្មវិធីនេះពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះអាចបង្រៀនឲ្យក្មេងៗដឹងពីអំពើប្រល័យពូជសាសន៍ដែលកើតនៅក្នុងរបបនោះ ជាពិសេសអាចបញ្ចៀសកុំឲ្យកើតឡើងជាលើកទីពីរទៀតនិងឲ្យលោកគ្រូអ្នកគ្រូអាចយកសៀវភៅនេះទុកជាឯកសារដើម្បីបង្រៀនកូនសិស្សជាជាងលោកគ្រូអ្នកគ្រូបង្រៀនទៅតាមអ្វីដែលខ្លួនបានដឹង ។ លើសពីនេះទៅទៀត ការបង្រៀននេះកាន់តែធ្វើឲ្យលោកគ្រូអ្នកគ្រូព្រមទាំងកូនសិស្សផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនជាងមុនទៅទៀតខណៈពេលដែលតុលាការកំពុងតែកាត់ទោសមេដឹកនាំខ្មែរក្រហមសព្វថ្ងៃនេះ» ។

**គាត លក្ខិណា**



គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកំពុងមើលខ្សែភាពយន្តខ្មែរក្រហម

# យុត្តិធម៌សម្រាប់ខ្មែរកម្ពុជាក្រោម

បន្ទាប់ពីជាង៣សាមសិបឆ្នាំនៃនិទ្ទណ្ឌភាព នៅទីបញ្ចប់មេដឹកនាំសំខាន់ៗនៃរបបខ្មែរក្រហមដ៏ព្រៃផ្សៃត្រូវបាននាំមកកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ សវនាការកាត់សេចក្ដីរួមទៅលើ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន នៅពេលខាងមុខនេះនឹងអនុវត្តការសន្យារបស់ខ្លួនចំពោះអ្នកនៅរស់ដែលបានរង់ចាំយុត្តិធម៌ជាយូរណាស់មកហើយ ។

ជាអកុសល ប្រភេទនៃឧក្រិដ្ឋកម្មដ៏សំខាន់មួយនឹងមិនត្រូវបានតុលាការរួមបញ្ចូលទេ ។ នៅខែមករា សហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចចោទប្រកាន់ជនសង្ស័យពីបទអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងជនជាតិភាគតិចវៀតណាម និងប្រជាជនចាមមូស្លីមនៅកម្ពុជា ប៉ុន្តែមិនមានខ្មែរក្រោមដែលជាជនជាតិភាគតិចខ្មែរដែលមានប្រភពនៅវៀតណាមខាងត្បូងទេ ។ សវនាការអង្គបុរេរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានធ្វើសេចក្ដីសម្រេចនៅពេលថ្មីៗនេះ ។

អង្គបុរេជំនុំជម្រះធ្វើសេចក្ដីសម្រេចនេះដោយសម្អាងដោយផ្អែកទៅលើបច្ចេកទេស ។ ប៉ុន្មានខែមុន សហព្រះរាជអាជ្ញាបានផ្ញើសេចក្ដីកំណត់ចំណាំមួយដល់សហចៅក្រមស៊ើបអង្កេតអំពីបទឧក្រិដ្ឋដែលអាចចោទប្រកាន់ថាជាអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងខ្មែរក្រោមនៅខេត្តពោធិ៍សាត់ ។ សហព្រះរាជអាជ្ញាបានដាក់ចំណងជើងសេចក្ដីកំណត់ចំណាំនោះថាជា «សេចក្ដីស្នើឲ្យធ្វើការស៊ើបអង្កេត» មិនមែន «ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម» ទេ ។ ចំណងជើងទីពីរអាចធ្វើឲ្យមានការស៊ើបអង្កេតបន្ថែម ។ រីឯចំណងជើងទីមួយអាចនឹងធ្វើឲ្យជនជាតិខ្មែរក្រោមដែលនៅរស់ត្រូវរង់ចាំនៅតុលាការទៀត ។ ប៉ុន្តែ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនបានទុកចន្លោះប្រហោងណាមួយសម្រាប់ធ្វើការពិចារណាបន្ថែមនោះទេ ។ សេចក្ដីសម្រេចនេះមិនបានទុកលទ្ធភាពដល់សហព្រះរាជអាជ្ញាឲ្យលុបចំណងជើងចាស់ រួចប្ដូរចំណងថ្មី ហើយផ្ញើទៅសហចៅក្រមស៊ើបអង្កេតម្ដងទៀតដោយដាក់ថាជា «ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម» ទេ ។ សហព្រះរាជអាជ្ញាគួរតែធ្វើបែបនេះ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចពិចារណាទៅលើបទល្មើសយ៉ាងច្រើនរបស់របបកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែតុលាការគួរតែស្ដាប់ប្រជាជនខ្មែរក្រោមដែលតែងតែអះអាងថាសហគមន៍របស់ខ្លួនធ្លាប់ទទួលរងនូវអំពើប្រល័យពូជ


ប្រជាជនខ្មែរក្រោមនៅខេត្តពោធិ៍សាត់


លោកសហព្រះរាជអាជ្ញា អែនដ្រូ ខេឡេ និយាយទៅកាន់អ្នកភូមិ

សាសន៍ ហើយធ្លាប់ជាគោលដៅសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផង។ ជាងនេះទៅទៀត ឯកសារនិងរឿងរ៉ាវរបស់អ្នកនៅរស់ជាច្រើនអាចបង្ហាញថាពេលខ្លះរបបកម្ពុជាប្រជាធិបតេយ្យបានដាក់គោលដៅសម្រាប់ធ្វើការរំលោភបំពានទៅលើខ្មែរក្រោម។ យ៉ាងហោចណាស់ក៏មានឯកសារសំណុំរឿងដែលបានចងក្រងយ៉ាងល្អបញ្ជាក់ថា ខ្មែរក្រោមត្រូវបានសម្លាប់ទាំងអស់។ នៅឆ្នាំ១៩៧៧ ខ្មែរក្រោមរាប់រយនាក់ត្រូវបានប្រមូលឲ្យនៅម្តុំ រួចសម្លាប់ទាំងអស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់។ ការសម្លាប់រង្គាលដ៏សាហាវនេះស្រដៀងគ្នាទៅនឹងការសម្លាប់រង្គាលនៅ *Srebrenica* នៅឆ្នាំ១៩៩៥ ដែរ។ បទល្មើសបែបនេះតម្រូវឲ្យមានការស៊ើបអង្កេតដើម្បីយុត្តិធម៌។

ហេតុផលដែលបណ្តាលឲ្យមានអំពើសាហាវឃោរឃៅកើតមាននៅតែជាប្រធានបទមួយសម្រាប់ពិភាក្សា។ ខ្មែរក្រោមនិយាយភាសាវៀតណាម ហើយបាននាំយកការប្រណិប័តន៍វប្បធម៌ពីដែនដីសណ្តទន្លេមេគង្គ។ ការមើលងាយទៅលើវប្បធម៌ប្រហែលជាអាចធ្វើឲ្យប្រជាជនខ្មែរក្រោមធ្លាក់ទៅក្នុងស្ថានភាពអាក្រក់បែបនោះ។ នៅក្នុងរបប ប៉ុល ពត ប្រជាជនដែលមានចរិតលក្ខណៈដូចជាវប្បធម៌បរទេសគឺជាជនសង្ស័យ។ យោងទៅតាមភ័ស្តុតាង អ.វ.ត.ក អាចរកឃើញថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដោយគោរពទៅតាមការបោសសម្អាតជាតិពន្ធុបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយព្យាយាមកម្ទេចខ្មែរក្រោមចោល។

ករណីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានលក្ខណៈងាយស្រួលក្នុងការបកស្រាយពន្យល់ ពីព្រោះវាបានរួមបញ្ចូលការរំលោភបំពានដោយផ្អែកទៅលើហេតុផលនយោបាយ។ នយោបាយដែលសំដៅទៅលើខ្មែរក្រោមពិតជាធ្លាប់កើតមានមែន។ របបកុម្មុយនីស្តខ្មែរក្រហមមិនពេញចិត្តនឹងតួនាទីដ៏សំខាន់របស់ខ្មែរក្រោមដែលធ្លាប់មាននៅក្នុងរបបសាធារណរដ្ឋខ្មែរដែលគ្រប់គ្រងដោយ លន់ នល់ និងកងកម្លាំងចល័តពិសេសរបស់ សេអ៊ីអា ក្នុងអំឡុងសង្គ្រាមវៀតណាមទេ។ ខ្មែរក្រហមក៏បានចាត់ទុកវៀតណាមថាជនសង្ស័យដែរបន្ទាប់ពីឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យងាកមកក្រុងរកហាណូយវិញ។ ឯកសារបង្ហាញថា ខ្មែរក្រោមដែលនិយាយវៀតណាមតែងតែត្រូវបានចាត់ទុកថាជាឈ្លបយកការណ៍ ហើយបន្ទាប់មកត្រូវបោសសម្អាតដោយហេតុផលនោះ។

ករណីដ៏ស្មុគស្មាញរបស់ខ្មែរក្រោមនៅតែជាសំណួរដែលមិនមានចម្លើយទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ បីទសវត្សរ៍មកហើយ អ្នកនៅរស់និងបញ្ញាវន្តបានព្យាយាមសិក្សាពីមូលហេតុនៃអំពើដ៏សាហាវឃោរឃៅរបស់ខ្មែរក្រហម។ តើការសម្លាប់កើតឡើងដោយលទ្ធិកុម្មុយនីស្តជ្រុលនិយមឬ? តើអំពើហិង្សាកើតចេញពីការស្នេហាជាតិ ផ្ទុយនឹងការប្រកាន់ពូជសាសន៍ឬ?

ពេលខ្លះភាពខុសគ្នាតាមផ្លូវច្បាប់រវាងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរផ្សេងទៀតមិនអាចជួយអ្វីបានទេ។ នៅប្រទេសកម្ពុជា នៅពេលដែលជនរងគ្រោះសុទ្ធតែទទួលការធ្វើបាបដ៏ព្រៃផ្សៃដូចគ្នា ជនរងគ្រោះមួយចំនួនបានទទួលរងនូវការឈឺចាប់ជាងជនរងគ្រោះដទៃទៀត។ ប៉ុន្តែ ភាពខុសគ្នានេះអាចយកមកប្រើបាននៅពេលដែលយើងចង់ព្យាយាមសិក្សាស្វែងយល់ឲ្យត្រឹមត្រូវអំពីរបបដ៏ឃោរឃៅខ្មែរក្រហមតែប៉ុណ្ណោះ។ ដោយធ្វើការពិនិត្យទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រហម អ.វ.ត.ក អាចជួយផ្តល់ជាពន្លឺដល់ការស្វែងយល់ពីរបបកម្ពុជាប្រជាធិបតេយ្យ។

អ.វ.ត.ក មិនមានធនធានច្រើនទេ ប៉ុន្តែ អ.វ.ត.ក គួរតែចាប់ផ្តើមត្រួតពិនិត្យទៅលើថវិការបស់ខ្លួនហើយពន្លឿនសវនាការឲ្យលឿនជាងមុន។ ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីរបស់ អ.វ.ត.ក គួរតែមានភាពឆ្លាតវៃក្នុងការសម្រេចថាតើត្រូវធ្វើការកាត់បន្ថយថវិកានៅចំណុចណានិងដោយរបៀបណា។ ការពិចារណាទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមនៅពោធិ៍សាត់នឹងថ្តែមទម្ងន់តែបន្តិចទៅលើពេលវេលានិងថវិកាដែលកំពុងចំណាយសម្រាប់ការកាត់សេចក្តី។ តាមការពិត ព្រះរាជអាជ្ញា និង អ្នកស៊ើបអង្កេតបានបញ្ចប់ការស៊ើបអង្កេតដ៏សំខាន់របស់ខ្លួនក្នុងការស្វែងរកភ័ស្តុតាងមកបញ្ជាក់ពីឧក្រិដ្ឋកម្មទាំងនេះ។ ការមិនពិចារណាទៅលើករណីខ្មែរក្រោមអាចធ្វើឲ្យសហគមន៍ដ៏ក្លាហាននិងសំខាន់នេះបាត់បង់អារម្មណ៍យុត្តិធម៌។ អ.វ.ត.ក ក៏អាចទទួលបរាជ័យក្នុងការបង្ហាញការពិតអំពីរបបខ្មែរក្រហមដែរ។ **ចន ឆរតីអារី**

# ចំណោទរវាង ចៅហ្វាយ-កូនចៅ :
# ភាពចាំបាច់មួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

***សេចក្តីសង្ខេបៈ***

*អត្ថបទស្រាវជ្រាវនេះនឹងធ្វើការវិភាគនូវភាពខុសគ្នាអំពីទម្រង់នៃចំណងទាក់ទងរវាងចៅហ្វាយ-កូនចៅ ដោយជាដំបូងនឹងធ្វើការរះគន់អត្ថបទរបស់លោក ជេម ស្កុត ដែលនិយាយអំពីចំណងទាក់ទងរវាងចៅហ្វាយ-កូនចៅ ហើយបន្ទាប់មកនឹងបន្តភ្ជាប់ទំនាក់ទំនងនេះទៅនឹងការកាន់កាប់របស់របបកម្ពុជាប្រជាធិបតេយ្យ ដោយធ្វើការពិនិត្យទៅលើឯកសារស៊ុយជីវប្រវត្តិ ឯកសារផ្សេងៗ សៀវភៅ និងអត្ថបទរបស់អ្នកសិក្សាស្រាវជ្រាវផ្សេងៗទៀតដែលសង្កត់ធ្ងន់ទៅលើមន្ទីរស-២១ ។ អត្ថបទនេះនឹងពិនិត្យផងដែរទៅលើរបៀបដែលរបបខ្មែរក្រហមមានបំណងធ្វើការផ្លាស់ប្តូរប្រវត្តិសាស្ត្រប្រទេសកម្ពុជាទាំងស្រុង ហើយថាតើបំណងនេះបានសម្រេចឬទេ ឬមួយក៏ទម្លាប់នៃចំណងរវាងចៅហ្វាយ-កូនចៅនៅតែរក្សាទុកដដែលដោយគ្រាន់តែស្ថិតក្នុងទម្រង់និងកម្រិតមួយផ្សេងគ្នាឬយ៉ាងណា ។ អត្ថបទនេះនឹងពិនិត្យយ៉ាងល្អិតល្អន់ទៅលើទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងអ្នកជាប់គុក អ្នកយាម និងមេគុក ហើយបន្ទាប់មកនឹងពិភាក្សាពីភាពដឹកនាំនិងការកាន់កាប់ទាក់ទងនឹងការសម្លាប់រង្គាល ។ វត្ថុបំណងនៃអត្ថបទស្រាវជ្រាវនេះគឺធ្វើការពិនិត្យមើលថាតើការប៉ុនប៉ងដែលមានលក្ខណៈកុម្មុយនីស្តផ្តាច់ការបែបនេះអាចទទួលជោគជ័យក្នុងការចៀសវាងប្រើប្រាស់ទំនាក់ទំនងរវាងចៅហ្វាយនិងកូនចៅ ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើអតីតរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាបានដែរឬទេ ។*

*អរជូន និងកូនរបស់គាត់ គឺគ្មានសេចក្តីអាណិតអាសូរដល់ ទុំ បន្តិចសោះ ដោយបានសម្លាប់ ទុំ យ៉ាងព្រៃផ្សៃ ។ ទង្វើរបស់ អរជូន បានសម្តែងនូវការមិនគោរពដល់សិទ្ធិអំណាចចំពោះស្តេចរាមា ដូច្នេះទើបស្តេចរាមាបានបញ្ជូនទ័ពទៅកាន់ស្រុកត្បូងឃ្មុំ ទោះបីជា អរជូន បានថ្វាយអំណោយជាច្រើនដើម្បីសុំអភ័យទោសក៏ដោយ ក៏វាគ្មានប្រយោជន៍ដែរ ។ ស្តេចរាមាបានបញ្ជាឲ្យគ្រួសាររបស់ អរជូន និងញាតិសន្តានទាំងប្រាំពីរជំនាន់ត្រូវយកទៅកប់នៅក្នុងដីសល់ត្រឹមកហើយយករនាស់មករាស់ពីលើក្បាលពួកគេទាំងរស់ ។ ចំណែកឯអ្នកក្រោមបង្គាប់របស់ អរជូន វិញត្រូវបានយកទៅស្ងោរទាំងរស់ ។ សកម្មភាពដ៏ព្រៃផ្សៃនៅក្នុងរឿងទុំទាវនេះទាក់ទងទៅនឹងភាពគានតឹងរវាងភាពមានសណ្តាប់ធ្នាប់ និងឥតសណ្តាប់ធ្នាប់ដែលបានលើកឡើងនៅក្នុងអត្ថបទរបស់លោកសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន ក្នុងសៀវភៅ ដែលមានចំណងជើងថា «Songs at the Edge of Democratic Kampuchea» ។*


បន្ទប់តូចៗ នៅក្នុងទួលស្លែង

ប្រតិកម្មរបស់ស្តេចរាមាចំពោះសកម្មភាពមិនគោរពច្បាប់របស់ អរជូន ជាបំណងមួយដែលស្តេចរាមាធ្វើឡើងដើម្បីស្តារនូវភាពមានសណ្តាប់ធ្នាប់ដែលទ្រង់បានបញ្ជាក់នៅក្នុងប្រព័ន្ធឋានានុក្រមរបស់ប្រទេសកម្ពុជា ។ ស្តេចរាមាគឺជាចៅហ្វាយ ចំណែក អរជូន ជាកូនចៅ ។ យ៉ាងណាមិញ ការមិនបង្គាប់របស់ អរជូន បានធ្វើឲ្យស្តេចរាមាសងសឹកដោយគ្មានក្តីសន្តោសមេត្តា ។ ការសម្តែងចេញនូវអំណាចនៅក្នុងកំណាព្យមនោសញ្ចេតនារបស់ប្រទេសកម្ពុជាអំឡុងសតវត្សរ៍ទី១៦គឺមានលក្ខណៈប្រហាក់ប្រហែលទៅនឹងពេលវេលាដ៏ច្របូកច្របល់មួយនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ ដែរ ។ ការកម្ចាត់គ្រួសារ អរជូន ទាំងពូជ ហើយនិងដៃជើងរបស់ អរជូន ផងគឺទាក់ទងទៅនឹងរបៀបដែលខ្មែរក្រហមដោះស្រាយជាមួយនឹងភាពឥតសណ្តាប់ធ្នាប់អ៊ីចឹង ។ នៅពេលដែលឪពុកម្តាយរួមជាមួយនឹងកូនៗរបស់ពួកគេត្រូវបានបញ្ជូនមកដល់មន្ទីរស-២១ កូនៗទាំងនោះនឹងត្រូវសម្លាប់ចោលភ្លាមក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីការចាប់ខ្លួនឪពុកម្តាយរបស់ពួកគេ ។ ការកម្ទេចចោលនូវខ្សែខ្មាំងជាគន្លឹះនៃយុទ្ធសាស្ត្ររបស់ខ្មែរក្រហមក្នុងការការពារកុំឲ្យមាន «ខ្មាំងបង្កប់» ជាពាក្យមួយដែលគណៈអចិន្ត្រៃយ៍តែងតែលើកយកមកនិយាយជាញឹកញាប់ ។

ខ្មែរក្រហមមានគោលបំណងបង្កើតនូវសង្គមនិយមទាំងស្រុងមួយដោយពឹងផ្អែកទៅលើកសិកម្មផលិតស្រូវជាធំ ។ យ៉ាងណាមិញ ខ្មែរក្រហមហាក់ដូចជាមិនសម្រេចបាននូវទម្រង់នៃរដ្ឋបែបនេះទេ ដោយសារតែពួកគេនៅតែបន្តប្រកាន់ខ្ជាប់នូវរចនាសម្ព័ន្ធជាទម្រង់ចៅហ្វាយ-កូនចៅ ដែលធ្លាប់ប្រើប្រាស់តាំងពីអតីតកាលមកម្ល៉េះ ។ ជាទូទៅ ទំនាក់ទំនងរវាងចៅហ្វាយ-កូនចៅអាចឲ្យនិយមន័យបានថាជាការផ្លាស់ប្តូររវាងបុគ្គលពីរនាក់ដែលម្នាក់មានឋានៈខ្ពស់ជាងនៅក្នុងសង្គម (ចៅហ្វាយ) ហើយប្រើប្រាស់ឥទ្ធិពល ធនធាន និងទំនាក់ទំនងរបស់ខ្លួនដើម្បីផ្តល់ការការពារ ឬផលប្រយោជន៍ ឬក៏ទាំងពីរតែម្តងទៅដល់បុគ្គលម្នាក់ទៀតដែលមានឋានៈទាបជាង (កូនចៅ) ហើយកូនចៅនោះត្រូវផ្តល់ទៅវិញនូវការគាំទ្រជាទូទៅនិងការជួយផ្សេងៗរួមទាំងការបម្រើដោយផ្ទាល់ចំពោះចៅហ្វាយផង ។ បើយោងទៅតាមអត្ថបទរបស់លោក ជេម ស្កុត «គោលនយោបាយរវាងចៅហ្វាយ-កូនចៅ និងការផ្លាស់ប្តូរគោលនយោបាយនៅអាស៊ីអាគ្នេយ៍» យើងឃើញថាភាពខុសគ្នានៃទំនាក់ទំនងរវាងការប្រើអំណាចនិងចំណងរវាងចៅហ្វាយ-កូនចៅស្ថិតនៅត្រង់ថាចំណងរវាងចៅហ្វាយ-កូនចៅគឺចាំបាច់ត្រូវមានការផ្តល់ឲ្យគ្នាទៅវិញទៅមក ។

ស្កុត ក៏បានបញ្ជាក់ផងដែរថា ចៅហ្វាយអាចមានការគ្រប់គ្រងទាំងស្រុងទៅលើកូនចៅ ដោយលើកឡើងថា «ក្នុងនាមជាម្ចាស់ផ្តាច់មុខ ចៅហ្វាយស្ថិតនៅក្នុងតំណែងមួយដែលអាចទាមទារយកការយល់ព្រមពីសំណាក់អ្នកដែលមានបំណងចែករំលែកយករបស់ដែលកម្រនេះ» ។ ប្រភេទនៃរបស់ដែលចៅហ្វាយអាចធ្វើជាម្ចាស់ផ្តាច់មុខបាននោះ រួមមាន ការការពារ សន្តិសុខ ការងារ ការអប់រំ អាហារ និងទ្រព្យសម្បត្តិ ។ ទំនាក់ទំនងរវាងចៅហ្វាយ-កូនចៅស្ថិតនៅលើភាពមិនស្មើគ្នារវាងបុគ្គលពីរនាក់ដែលពាក់ព័ន្ធ ។ យ៉ាងណាមិញ ស្កុត មិនបានបញ្ជាក់ឲ្យច្បាស់លាស់ពីភាពខុសគ្នារវាងការប្រើប្រាស់អំណាច ការបញ្ជា និងចំណងរវាងចៅហ្វាយ-កូនចៅទេ ។ ស្កុត ក៏សរសេរផងដែរថា «ប្រសិនបើការប្រើប្រាស់អំណាច ឬបញ្ជារបស់ចៅហ្វាយនោះគ្រប់គ្រាន់នឹងធានាបាននូវការយល់ព្រមធ្វើតាមរបស់មនុស្សម្នាក់ទៀត (កូនចៅ) នោះចៅហ្វាយមិនចាំបាច់ប្រើប្រាស់នូវចំណងរវាងចៅហ្វាយ-កូនចៅដែលទាមទារឲ្យមានការផ្តល់ឲ្យគ្នាទៅវិញទៅមកនោះទេ» ។ ត្រង់ចំណុចនេះ «ការផ្តល់ឲ្យគ្នាទៅវិញទៅមក» ចាំបាច់ត្រូវតែកំណត់ឲ្យច្បាស់ពីព្រោះក្នុងការយល់ព្រមជាមួយនឹងចៅហ្វាយ បុគ្គលម្នាក់អាចផ្តល់ជារបស់របរដើម្បីធ្វើជាការផ្តល់សងទៅវិញទៅមក ឬក៏ការគាំទ្រផ្នែកនយោបាយតែសំបកក្រៅ ។ នៅក្នុងករណីមន្ទីរស-២១ មានអ្នកទោសជាច្រើនយល់ព្រមធ្វើតាមការប្រើប្រាស់អំណាចរបស់មនុស្សម្នាក់ទៀតក្នុងគោលបំណងដើម្បីចង់រស់ដោយផ្តល់ឲ្យចៅហ្វាយនូវរបស់របរដើម្បីធ្វើជាការផ្តល់សងវិញ ។

តើនេះជាការផ្តល់ឲ្យគ្នាទៅវិញទៅមក ឬក៏ការយល់ព្រមធ្វើតាមដែលនេះពិបាកនឹងយល់ប្រសិនបើយើងយោងទៅតាមអត្ថបទរបស់ ស្កុត ដោយសារតែបន្ទាប់មកទៀតគាត់សរសេរថា «នៅពេលចុងក្រោយបំផុត កូនចៅដោយសារតែគ្មានជម្រើសទាល់តែសោះក្រៅពីធ្វើតាមបញ្ជារបស់ចៅហ្វាយដែលគ្រប់គ្រងដោយផ្ទាល់ទៅលើមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេ...នៅក្នុង

សង្គមមួយដែលក្រដីរស់នៅតែពោរពេញទៅដោយអសន្តិសុខ» ។ ស្ថានភាពនៅក្នុងមន្ទីរស-២១ គឺមានករណីបែបនេះកើតឡើង ដោយសារតែវាមានតែមធ្យោបាយមួយគត់ក្នុងការចិញ្ចឹមជីវិត និងសន្តិសុខ ទោះបីជានៅខាងក្នុងនិងខាងក្រៅជញ្ជាំងគុកក៏ដោយ ។ បុគ្គលម្នាក់មានបំណងចង់រត់គេច ប៉ុន្តែនៅក្រៅគុក ឱកាសដែលអាចរស់រានមានជីវិតបាន គឺតិចតួចខ្លាំងណាស់ ។ ស្តុត មិនបានបដិសេធនូវឋានៈរបស់ចៅហ្វាយដែលអាចធ្វើការគ្រប់គ្រងលើប្រភពធនធានចាំបាច់ផ្សេងៗរបស់កូនចៅនោះទេ ប៉ុន្តែគាត់គ្រាន់តែលើកឡើងអំពីភាពខុសគ្នារវាងចៅហ្វាយនិងអ្នកដែលមានអំណាចទន់ខ្សោយប៉ុណ្ណោះ ។ ភាពខុសគ្នាចម្បងបំផុតគឺថា ចៅហ្វាយដែលមានអំណាចបញ្ជាខ្លាំងក្លាអាចប្រើប្រាស់ការដាក់ទណ្ឌកម្ម ការគំរាមកំហែងដើម្បីដាក់ទោសកូនចៅរបស់ខ្លួនចំពោះការមិនស្តាប់បង្គាប់ ។ ខណៈពេលចៅហ្វាយដែលមានអំណាចបញ្ជាពុំសូវខ្លាំងវិញ ការលើកទឹកចិត្តផ្សេងៗទៅដល់កូនចៅរបស់ខ្លួនចំពោះការស្តាប់បង្គាប់របស់ពួកគេ ។

បើតាមទ្រឹស្តី កូនចៅគឺមានជម្រើសបួនយ៉ាង ៖ តបស្នងសងគុណទៅឲ្យចៅហ្វាយវិញ ស្វែងរកចៅហ្វាយថ្មី បង្ខំចៅហ្វាយឲ្យផ្តល់ថ្លៃសេវាកម្ម ឬក៏ធ្វើដោយមិនចាំបាច់មានថ្លៃសេវាកម្មពីចៅហ្វាយនាយឡើយ ។ នៅក្នុងករណីមន្ទីរស-២១ មានជម្រើសតែមួយគត់គឺការធ្វើដោយមិនចាំបាច់មានថ្លៃសេវាកម្មពីចៅហ្វាយឡើយ ទោះបីជាការធ្វើកិច្ចការនោះអាចនាំទៅរកការស្លាប់ក៏ដោយ ។ ដោយសារតែភាពមិនច្បាស់លាស់នៃការញែកឲ្យដាច់ពីភាពខុសគ្នារវាងការបញ្ជាដាច់ខាតនិងទំនាក់ទំនងរវាងចៅហ្វាយ-កូនចៅនេះយើងអាចធ្វើការសន្និដ្ឋានបានថាកូនចៅអាចមានជម្រើសមួយនៅក្នុងគ្រប់ស្ថានភាពទាំងអស់នេះ ។ ទោះបីជាការរ៉ឹងទទឹងមិនធ្វើតាមអំណាចរបស់គេអាចនឹងនាំទៅរកការស្លាប់ក៏ដោយ ក៏កូនចៅនោះនៅតែមានជម្រើសមួយក្នុងការធ្វើតាមឬក៏មិនធ្វើតាម ។ ជាមួយនឹងការប្រកាន់ខ្ជាប់គោលជំហរនេះនៅក្នុងចិត្ត យើងនឹងធ្វើការវិភាគទំនាក់ទំនងចៅហ្វាយ-កូនចៅរវាង វ៉ាន់ ណាត សមមិត្ត ឌុច និង គណៈមជ្ឈិមបក្ស ។ ឆ្លងកាត់ការវិភាគនេះ យើងនឹងអាចមើលឃើញពីទំនាក់ទំនងចៅហ្វាយ-កូនចៅដែលបន្តរីករាលដាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាមានការអះអាងថាវាត្រូវបានបញ្ចប់នៅក្នុងប្រវត្តិសាស្ត្រតាំងពី ២០០០ឆ្នាំមុនក៏ដោយ ។

វ៉ាន់ ណាត ដែលជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសបីនាក់ដែលអាចរស់រានមានជីវិតពីមន្ទីរស-២១ បានបង្កើតនូវទំនាក់ទំនងចៅហ្វាយ-កូនចៅ ជាមួយអ្នកយាមគុក និងមេគុក (ឌុច) ។ នៅក្នុងស្វ័យជីវប្រវត្តិរបស់ ណាត គាត់បាននិយាយថាៈ

«គំនូរមួយផ្ទាំងនេះស្អាតជាងគំនូរលើកមុន ហើយ ឌុច ឥឡូវរាក់ទាក់ជាមួយខ្ញុំណាស់ ។ រង្វាន់ដែលពួកគេសន្យាថានឹងឲ្យខ្ញុំនោះគឺបារីប្រាំកញ្ចប់ ។ អ្នកយាមគុកឥឡូវចាប់ផ្តើមរាក់ទាក់ជាមួយខ្ញុំ ចំណែកអ្នកយាមគុកក្មេងៗវិញបានលួចចូលមកមើលខ្ញុំនៅពេលយប់ ។ ពួកវាឲ្យខ្ញុំគូរគំនូរពណ៌មានដូចជារូបមនុស្សកំពុងតែស្ទូងស្រូវ ច្រូតស្រូវនិងរូបអ្នកភូមិ ។ នៅពេលដែលខ្ញុំមានពេលទំនេរ ខ្ញុំគូរគំនូរឲ្យពួកវាដោយមានការអនុញ្ញាតពីអ្នកយាមបន្ទប់នោះ» ។



វ៉ាន់ ណាត

ឥឡូវនេះ បន្ទាប់ពី វ៉ាន់ ណាត បានបង្ហាញពីសមត្ថភាពគ្រប់គ្រាន់របស់គាត់ក្នុងការគូររូប អ្វីដែល ឌុច និងគណៈមជ្ឈិមចង់បាន ហើយគាត់ក៏ត្រូវបានគេផ្តល់ជារង្វាន់ ។ វ៉ាន់ ណាត មិនត្រឹមតែត្រូវបានទុកជីវិតឲ្យទេ ថែមទាំងទទួលបានបារីទៀតផង ។ វាមានការផ្តល់ឲ្យគ្នាទៅវិញទៅមកនៅក្នុងទំនាក់ទំនងនេះដែលដូចជាទំនាក់ទំនងរវាងដែលទុកថាមាននៅក្នុងចំណងរវាងចៅហ្វាយកូនចៅដូច្នោះ

ដែរ ។ នេះមិនមែនជាការបង្ខិតបង្ខំទាំងស្រុងទេ ពីព្រោះថា វ៉ាន់ ណាត ទទួលបានច្រើនជាងការទុកជីវិតឲ្យគាត់ទៅទៀត ។ ទំនាក់ទំនងរបស់គាត់ជាមួយនឹងអ្នកយាមគុក ក៏ដូចជា ឌុច ពឹងផ្អែកទៅលើសេវាកម្មមួយដែលគាត់អាចផ្តល់ឲ្យបាននោះគឺការគូររូប ។ ចំពោះចៅហ្វាយវិញ នៅទីនេះដំបូងគឺគណៈមជ្ឈិមដែលជាអ្នកចង់បានរូបគំនូររបស់មេដឹកនាំអង្គការ ប៉ុល ពត ។ វ៉ាន់ ណាត បានក្លាយទៅជាកូនចៅពីព្រោះគាត់ជាអ្នកគូររូបដើម្បីយកចិត្តនិងតម្រូវតាមការចង់បានរបស់គណៈមជ្ឈិម និង ឌុច ។ បន្ទាប់មកអ្នកយាមគុកបានក្លាយទៅជាចៅហ្វាយរបស់ វ៉ាន់ ណាត ដោយសារតែពួកគេបានឲ្យ វ៉ាន់ ណាត គូររូបឲ្យពួកគេ មានដូចជា រូបអ្នកភូមិ និងជីវិតតាមប្រពៃណីផ្សេងៗ ។ មុខងាររបស់ វ៉ាន់ ណាត គ្រាន់តែជាកូនចៅម្នាក់ប៉ុណ្ណោះ ហើយបន្ទាប់មកក៏ក្លាយទៅជាកូនចៅដែលចាំតែគូររូបដែលជីវិតរបស់គាត់ចាប់ផ្តើមត្រូវបានគំរាមកំហែង ។


ប៉ូ ម៉េង

ឌុច មានបំណងចៀសវាងពី ប៉ូ ម៉េង ដែលជាមនុស្ស ឌុច គិតថាកំពុងតែរំលោភលើបុព្វសិទ្ធរបស់គាត់ដោយបញ្ជាឲ្យ វ៉ាន់ ណាត ធ្វើតាមអ្វីដែលគាត់បញ្ជា ។ វ៉ាន់ ណាត អង្វរ ឌុច ឲ្យទុកឱកាសឲ្យគាត់ម្តងទៀត ។ គួរឲ្យភ្ញាក់ផ្អើលផងដែរ ឌុច បានយល់ព្រមដោយមានលក្ខខណ្ឌបីយ៉ាង : ប៉ូ ម៉េង មិនអាចដក់បារីបាន ហើយត្រូវបានអនុញ្ញាតឲ្យដើរត្រឹមតែប្រាំម៉ែត្រការ៉េពីកន្លែងដែលគាត់គូររូប ហើយកជើងរបស់គាត់ត្រូវតែដាក់ច្រវាក់ដដែល ។ ឌុច បានឲ្យ វ៉ាន់ ណាត មើលការខុសត្រូវលើ ប៉ូ ម៉េង ដើម្បីធានាឲ្យបានថា ប៉ូ ម៉េង អនុវត្តទៅតាមលក្ខខណ្ឌទាំងអស់នេះប្រសិនបើ ប៉ូ ម៉េង មិនអាចធ្វើបាននោះ វ៉ាន់ ណាត នឹងត្រូវផ្តន្ទាទោស ។ នៅទីនេះការទទួលរ៉ាប់រងនិងអំណាចត្រូវបានបែងចែកទៅឲ្យជាងគំនូរ (អ្នកទោស) ។ នេះបានបង្ហាញយ៉ាងច្បាស់លាស់ពីរបៀបដែល ឌុច កំពុងតែផ្តល់ឲ្យគាត់មិនត្រឹមតែការស្នាក់នៅ និងការរស់នៅគ្រប់គ្រាន់នោះទេ ឌុច ថែមទាំងកំពុងតែពឹងផ្អែកលើគាត់ទៀតផង ។ នេះជាចំណងយ៉ាងជិតស្និទ្ធមួយដែលផ្ទុយពីការដែលគ្រាន់តែគូររូប ហើយចូលទៅក្នុងគុកវិញរួចគេងនោះទេ ។ ការប្រថុយប្រថានក្នុងអំឡុងពេលដែល វ៉ាន់ ណាត ធ្វើជាចៅហ្វាយមកលើ ប៉ូ ម៉េង នោះក៏ត្រូវបានចាប់អារម្មណ៍ផងដែរ ។

ទោះបីជាត្រូវបានហាមប្រាមយ៉ាងណាក្តី វ៉ាន់ ណាត នៅតែលួចយកបារីឲ្យ ប៉ូ ម៉េង ជក់ដែរ នៅពេលដែលអ្នកយាមគុកចេញទៅក្រៅអស់ ។ វ៉ាន់ ណាត បញ្ជាក់ពីបញ្ហានេះដោយនិយាយថា «.... ប៉ូ ម៉េង ជាមនុស្សទីមួយដែលខ្ញុំបានជួបនៅពេលដែលខ្ញុំមកដល់ទីនេះ ។ ទោះបីជាមានការតឹងរ៉ឹងឬការគំរាមកំហែងដល់អាយុជីវិតយ៉ាងណាក្តី ខ្ញុំចាំបាច់ត្រូវតែប្រថុយព្រោះខ្ញុំពិតជាមានអារម្មណ៍អាណិតគាត់ណាស់» ។ បើនិយាយតាមសភាពការណ៍ នេះគឺជាទំនាក់ទំនងចៅហ្វាយ-កូនចៅមួយយ៉ាងរ៉ឹងមាំពីព្រោះ វ៉ាន់ ណាត ដឹងអំពីលទ្ធផលចុងក្រោយថាស្លាប់ ប្រសិនបើគាត់ត្រូវបានគេចាប់បាន ។ ទោះបីជាយ៉ាងនេះក្តី នេះមិនមែនជាបញ្ហាសម្រាប់គាត់នោះទេ ព្រោះចំណងរវាងគាត់ និង ប៉ូ ម៉េង ពិតជារ៉ឹងមាំខ្លាំងណាស់ ។ ទំនាក់ទំនងនេះបានបង្ហាញយ៉ាងច្បាស់លាស់ពីការពង្រឹងចំណងរវាងចៅហ្វាយ-កូនចៅនៅពេលដែលវាមានលក្ខណៈជិតស្និទ្ធជាជាងគ្រាន់តែទាក់ទងទៅនឹងឧបករណ៍ ។ ប៉ូ ម៉េង បានផ្តល់ការណែនាំដល់ វ៉ាន់ ណាត នៅពេលដែលគាត់បានមកដល់ទីនេះដំបូងដើម្បីគូររូប ។ នៅត្រង់ចំណុចនេះ វ៉ាន់ ណាត មានអារម្មណ៍ដូចជាជំពាក់ និង គោរព ប៉ូ ម៉េង ខ្លាំងណាស់ ហើយព្យាយាមផ្តល់ឲ្យ ប៉ូ ម៉េង នូវអ្វីដែលគាត់អាចធ្វើទៅបាន ។ វ៉ាន់ ណាត ចាំបាច់ត្រូវតបស្នងដល់ ប៉ូ ម៉េង វិញដោយប្រថុយជីវិតរបស់គាត់ ។

បន្ទាប់មក វ៉ាន់ ណាត កាន់តែទទួលបានបុព្វសិទ្ធច្រើនជាងនេះពីព្រោះអ្នកយាមគុកលែងបង្ខំឲ្យ វ៉ាន់ ណាត ឡើងជាន់លើពេលយប់ដើម្បីចូលដេកជាមួយជាងគំនូរ និងជាងឈើដទៃទៀត ហើយ តែអនុញ្ញាតឲ្យ វ៉ាន់ ណាត ដេកនៅក្នុងរោងជាងហ្នឹងតែម្តង ។ វ៉ាន់ ណាត បានអង្កេតមើលពីបញ្ហានេះដោយប្រយ័ត្នប្រយែងដោយនិយាយថាៈ «ខណៈពេលដែលពួកវាធ្វើបែបនេះដាក់ខ្ញុំ មានន័យថា ពួកវាជឿជាក់លើខ្ញុំ ប៉ុន្តែខ្ញុំដឹងថា ខ្ញុំនៅតែមានការប្រុងប្រយ័ត្នជានិច្ច» ។ ឱកាសដែល វ៉ាន់ ណាត អាចនឹងត្រូវបានគេសម្លាប់ នៅតែមានប្រសិនបើ ឌុច ក៏ដូចជាគណៈមជ្ឈិមមិនពេញចិត្តនឹងការងាររបស់ វ៉ាន់ ណាត ទេនោះ ។ ប៉ុន្តែ ដោយសារតែចៅហ្វាយរបស់គាត់ពេញចិត្តនឹងការងាររបស់គាត់ ហើយក៏បានបង្កើតនូវចំណងមួយយ៉ាងរឹងមាំជាងអ្នកដទៃដែលធ្វើជាងគំនូរនៅពេលនោះជាមួយគាត់នៅក្នុងមន្ទីរស-២១ ។ នេះមិនមែនបានន័យថា វ៉ាន់ ណាត នឹងត្រូវបានគេទុកជីវិតឲ្យទេ ប្រសិនបើអង្គការចង់កម្ទេចគាត់ចោលនោះ ពីព្រោះថានៅចុងបញ្ចប់ភក្តីភាពតែមួយគត់ដែល ឌុច មានឲ្យនោះគឺអង្គការនេះឯង ហើយគ្មាននរណាទៀតនោះទេ ។

បើយើងពិចារណាលើទស្សនៈឲ្យធំទូលាយទាក់ទងនឹងចំណងរវាង វ៉ាន់ ណាត និង ចៅហ្វាយរបស់គាត់ (អ្នកយាមគុក និង ឌុច) យើងអាចមើលឃើញពីមុខងាររបស់គាត់ថាជាផ្នែកមួយនៃប្រព័ន្ធផងដែរ ។ ប្រព័ន្ធនេះមានរួមបញ្ចូលទាំងជាងគំនូរ ជាងចម្លាក់ និងជាងឈើដែលអ្នកទាំងអស់នេះហើយជាអ្នកផ្តល់នូវសេវាកម្មជាក់លាក់មួយជូនដល់ចៅហ្វាយរបស់ខ្លួន ។ កូនចៅទាំងអស់នេះសុទ្ធតែត្រូវទៅដេកបន្ទប់ដូចគ្នា លើកលែងតែ វ៉ាន់ ណាត ម្នាក់ប៉ុណ្ណោះ ។ អ្នកទាំងអស់នេះមានការប្រុងប្រយ័ត្នដាក់គ្នាទៅវិញទៅមក ហើយតែងតែឲ្យដំបូន្មានដល់ វ៉ាន់ ណាត ជាញឹកញាប់ថា «ឲ្យតែ ឌុច នៅពេញចិត្ត នោះ វ៉ាន់ ណាត នឹងអាចរស់នៅបានយូរជាងនេះ» ។ នៅពេលណាដែលមានការប្រែប្រួលកើតឡើងនៅក្នុងគុក ឬក៏នៅពេលដែលមានអ្វីចម្លែកកើតឡើង វ៉ាន់ ណាត នឹងព្យាយាមរកមធ្យោបាយនិយាយជាមួយជាងឈើដើម្បីយកព័ត៌មានបន្ថែម ។ ដូចជានៅពេលជិតចុងបញ្ចប់នៃមន្ទីរស-២១ បន្ទប់របស់ជាងគឺមានដាក់ទ្វារនិងបង្អួចដែក ។ ទោះបីជាពួកគាត់ត្រូវបានគេផ្តល់បុព្វសិទ្ធិឲ្យក៏ដោយ ក៏ពួកគាត់ត្រូវបានដាក់ឲ្យនៅក្នុងការបង្ខាំងនេះដដែល ។

ភ្លាមៗបន្ទាប់ពីនោះ វ៉ាន់ ណាត និងជាងបីរូបទៀតត្រូវបានផ្តល់ការងារឲ្យធ្វើដោយឲ្យធ្វើរូបសំណាក ប៉ុល ពត ឈរជាមួយកសិករកាន់ទង់ជាតិដែលមានកម្ពស់ប្រហែល៨ម៉ែត្រ ។ កូនចៅទាំងនេះត្រូវបានផ្តល់ឲ្យធ្វើកិច្ចការតែមួយដើម្បីយកចិត្តចៅហ្វាយ ។ នេះអាចបង្ហាញបន្ថែមទៀតពីប្រព័ន្ធដែលត្រូវបានបង្កើតក្នុងចំណោមជាងទាំងឡាយនៅក្នុងគុកនេះ ។ នៅពេលដែល វ៉ាន់ ណាត ត្រូវបានដាក់បញ្ចូលឲ្យធ្វើជាជាងគំនូរដំបូង ឌុច បានប្រាប់ ប៊ូ ម៉េង ថាគាត់មាន «មិត្តរួមការងារ» ថ្មីម្នាក់ទៀតហើយនៅក្នុងប្រព័ន្ធរបស់គាត់ ។ យ៉ាងណាមិញ ប្រព័ន្ធចំណងរវាងចៅហ្វាយ-កូនចៅនេះមានរយៈពេលខ្លីតែប៉ុណ្ណោះ ដោយសារតែមន្ទីរស-២១ បានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់វៀតណាម មុនពេលដែលជាងទាំងបួននាក់នេះអាចធ្វើរូបសំណាករបស់ ប៉ុល ពត បានចប់សព្វគ្រប់ទៅទៀត ។ ចំពោះ វ៉ាន់ ណាត វិញ ភក្តីភាពចុងក្រោយបំផុតរបស់គាត់គឺប្រជាជនខ្មែរនិងជាពិសេសអ្នកដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យទាំងគ្មានទោសកំហុស ។

បន្ទាប់ពីការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ វ៉ាន់ ណាត បានជួយក្នុងការប្រែក្លាយមន្ទីរស-២១ នេះឲ្យទៅជាសារមន្ទីរសម្រាប់សាធារណជននិងដោយសារតែធ្វើបែបនេះ ហើយ «គាត់ចាប់ផ្តើមជឿជាក់ថា ព្រលឹងរបស់ប្រជាជនដែលបានស្លាប់នៅទីនោះនឹងអាចបានទៅកាន់សុគតិភព ។ មានពេលខ្លះយើងបាននិមន្តព្រះសង្ឃសូត្រមន្តនិងរៀបចំពិធីបុណ្យនៅក្នុងគុកដើម្បីរំឭកដល់អ្នកដែលបានស្លាប់» ។ វ៉ាន់ ណាត បានធ្វើបុណ្យឧទ្ទិសកុសលដល់ព្រលឹងទាំងអស់នោះដើម្បីធានាឲ្យបានថាពួកគេនឹងអាចចាប់ជាតិឡើងវិញ ។ វ៉ាន់ ណាត ក៏បានធ្វើអំពើល្អជាច្រើនផងដែរដែលនឹងអាចផ្តល់ជាកម្មល្អដល់គាត់នៅក្នុងជាតិនេះក៏ដូចជាទៅជាតិមុខ ។ វ៉ាន់ ណាត ព្យាយាមជួយសង្គ្រោះជីវិតរបស់ ប៊ូ ម៉េង ទោះបីជាវាអាចទៅរួចដែលថាគាត់នឹងអាចស្លាប់ប្រសិនបើគាត់ព្យាយាមសុំឲ្យ ឌុច ពិចារណាឡើងវិញក្នុងការសម្លាប់ ប៊ូ ម៉េង ក៏ដោយ ។

សមមិត្ត ឌុច ត្រូវបានណែនាំឲ្យចូលក្នុងបក្សកុម្មុយនីស្ត

កម្ពុជាដោយសាស្ត្រាចារ្យរបស់គាត់ឈ្មោះ ឆាយ គឹមហ៊ី មុនពេលដែលបក្សកុម្មុយនីស្តកម្ពុជាកកើតជាផ្លូវការម្ល៉េះ ។ ឌុច បានបង្កើតនូវទំនាក់ទំនងមុនគេជាមួយមេដឹកនាំម្នាក់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា នោះគឺ សុន សេន។ សុន សេន ជានាយកនៃវិទ្យាស្ថានគរុកោសល្យ ជាសាលាដែល ឌុច ទទួលបានសញ្ញាប័ត្រគ្រូបង្រៀនរបស់គាត់ ។ ឌុច ត្រូវបានចាត់តាំងឲ្យធ្វើជាមេបញ្ជាការគុកនៅមន្ទីរម-១៣ ដែលនេះហើយជាកាផ្តល់បទពិសោធន៍ដល់គាត់ដើម្បីកាន់កាប់មន្ទីរស-២១ ។ ក្នុងនាមជាមេគុក ឌុច បានរាយការណ៍ដោយផ្ទាល់ទៅកាន់រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបខ្មែរក្រហម (សុន សេន) ។ នៅក្នុងសៀវភៅរបស់ នីក ឌុនឡប *The Lost Executioner* គាត់បានកត់ត្រាពីជីវិតរបស់ ឌុច និងផ្តោតសំខាន់ទៅលើការពាក់ព័ន្ធរបស់ ឌុច ជាមួយនឹងមន្ទីរស-២១ ។

ឌុច បានចំណាយពេលជាច្រើនរបស់គាត់ដើម្បីរាយការណ៍ និងទាក់ទងជាមួយ សុន សេន ដោយអានចម្លើយសារភាព បង្កើតប្រព័ន្ធដើម្បីកម្ចាត់ខ្មាំងនិងចុះហត្ថលេខាលើបញ្ជីសម្លាប់ ។ គណៈមជ្ឈិមចង់ឲ្យ ឌុច រកព័ត៌មានលម្អិតចេញពីចម្លើយសារភាពទាំងនោះ «ប្រសិនបើ ឌុច រកកំហុសអ្នកសួរចម្លើយបាន ឬក៏ពួកគេមិនយល់នូវអ្វីដែល ឌុច ត្រូវការចាំបាច់ពីពួកគេនោះ ឌុច នឹងគោះគុ ឬក៏សង្កៀតធ្មេញជាមិនខាន» ។ មើលទៅមានចំណុចលម្អិតជាច្រើនដែលនឹងអាចដកស្រង់ចេញពីចម្លើយសារភាពបាន ព្រោះបើមិនដូច្នេះទេ ឌុច មិនចាំបាច់ធ្វើខ្លាំងដើម្បីប្រមូលយកចម្លើយសារភាពដ៏ «ត្រឹមត្រូវ» មួយឡើយ ។ គណៈមជ្ឈិមចង់បានចម្លើយសារភាពដើម្បីលាតត្រដាងពីខ្មាំងថាតើជា សេ.អ៊ី.អា, កាហ្សេបេ ឬក៏ជនជាតិវៀតណាម ។ ការស្វែងរកប្រព័ន្ធបក្សពួករបស់អ្នកទោសម្នាក់អាចអនុញ្ញាតឲ្យគណៈមជ្ឈិមរកឃើញខ្មាំងបន្ទាប់ទៀតដើម្បីបញ្ជូនមកចូលគុក ។ ប្រាក់ ខន ដែលជាអ្នកសួរចម្លើយម្នាក់បានអះអាងនៅក្នុងឯកសាររបស់លោក ប៉ាន់ រិទ្ធី «មន្ទីរស-២១ៈ ម៉ាស៊ីនសម្លាប់របស់ខ្មែរក្រហម» ថា គាត់ជាអ្នកជួយសរសេរចម្លើយសារភាពយ៉ាងលម្អិតដល់អ្នកទោសម្នាក់ឈ្មោះ ណៃ ណន ។ ប្រាក់ ខន បានយល់ដឹងយ៉ាងច្បាស់ថាអ្វីដែល ឌុច ក៏ដូចជាគណៈមជ្ឈិមចង់បានខ្លាំងបំផុត ។ ប្រាក់ ខន ចាំបាច់ត្រូវតែយកចិត្ត ឌុច ហើយ ឌុច ក៏ត្រូវទៅយកចិត្តយកថ្នើមគណៈមជ្ឈិមដែរ ទោះបីជាចម្លើយសារភាពនោះជាការប្រឌិតឡើងទាំងស្រុងក៏ដោយ ។



ញ៉ែម អេន

ក្រៅពីចម្លើយសារភាព ឌុច ក៏មានកូនចៅម្នាក់ទៀតជាជាងថតរូបឈ្មោះ ញ៉ែម អេន ផងដែរ ។ ញ៉ែម អេន បានបង្កើតទំនាក់ទំនងមួយយ៉ាងល្អជាមួយ ឌុច ដែលជាអ្នកអនុញ្ញាតឲ្យគាត់មានសេរីភាពច្រើន ។ ជាការតបស្នង ញ៉ែម អេន បានថតរូបក្រុមគ្រួសាររបស់ ឌុច ជាញឹកញាប់ ដែលនេះមិនមែនជាតួនាទីរបស់គាត់ទេ ប៉ុន្តែដើម្បីយកចិត្តចៅហ្វាយ ញ៉ែម អេន ត្រូវតែធ្វើ ។ ញ៉ែម អេន ដូចជាមានគំនិតមួយជាកូនចៅដែលពោរពេញទៅដោយការគោរពតែម្តងដោយសារតែឪពុកគាត់ជាអ្នកបង្រៀនថា «ងើយស្កកឱនដាក់គ្រាប់» ។ នេះជាសម្តីដែលឪពុករបស់ ញ៉ែម អេន បានផ្តាំផ្ញើមុន ពេលដែលគាត់ចេញទៅ ។ ក្រៅពី ញ៉ែម អេន, ឌុច ក៏បានធ្វើឲ្យ វ៉ាន់ ណាត ក្លាយទៅជាកូនចៅម្នាក់ដែលពោរពេញទៅដោយការគោរពផងដែរ ។ ដូចដែល ឌុច បាននិយាយទៅកាន់ វ៉ាន់ ណាត ថា «អញមានតម្រុយមួយឲ្យឯងនៅទីនេះ ឯងចាំបាច់ត្រូវតែដឹងពីរបៀបធ្វើយ៉ាងម៉េចដាក់ខ្លួនឯងឲ្យនៅទាបជាងម្ចាស់ ។ ចំណុចសំខាន់បំផុត ត្រូវចេះដាក់ខ្លួនឲ្យបានរម្យទម» ។ នេះជាការបង្ហាញពីរបៀបដែល ឌុច ពិតជាចង់ឲ្យ វ៉ាន់ ណាត តបស្នងមកវិញមិនត្រឹមតែការគោរពទេ ថែមទាំងការគូររូបដែលបញ្ជាឡើងដោយគណៈមជ្ឈិមទៀតផង ។ ឌុច បាន

ព្យាយាមផ្តល់ឱកាសដល់ វ៉ាន់ ណាត ដើម្បីឲ្យក្លាយទៅជាកូនចៅម្នាក់របស់ខ្លួន ។

នៅក្នុងសៀវភៅរបស់លោក ដេវីដ ឆេនដល័រ «បងធំទី ១: ប្រវត្តិនយោបាយរបស់ ប៉ុល ពត» បានសង្ខេបពីអ្វីដែល ឌុច ធ្វើដើម្បីរួចរស់ជីវិត ។ ដូចដែលគាត់បានសរសេរថា «ធ្វើឲ្យចៅហ្វាយរបស់ខ្លួនសប្បាយរីករាយ និងធ្វើឲ្យអ្នកធ្វើការឲ្យខ្លួនខ្លាចនោះគឺ ឌុច អាចរួចរស់ពីរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងបាន ដែលយ៉ាងហោចណាស់អ្នកធ្វើការឲ្យ ឌុច ជាង៦០នាក់ ត្រូវបានសម្លាប់ដោយបទចោទប្រកាន់ផ្សេងៗ» ។ ការកាន់កាប់ ឬការធ្វើជាចៅហ្វាយដោយប្រើប្រាស់ភាពភ័យខ្លាចជាផ្នែកមួយយ៉ាងធំនៅក្នុងការកាន់កាប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឌុច ប្រើប្រាស់វិធីនេះនៅក្នុងគុកដោយគាត់ព្យាយាមធ្វើយ៉ាងណាដើម្បីឲ្យអ្នកធ្វើការឲ្យគាត់ស្ថិតនៅក្រោមគាត់ និងក្នុងភាពភ័យខ្លាចជានិច្ច ។ វ៉ាន់ ណាត បានរៀបរាប់ពីទំនាក់ទំនងនេះថា «អ្នកយាមពីរនាក់មើលទៅដូចជាលើក ឌុច ដាក់លើកៅអី ហើយគោរពបូជាអីចឹង ...ពាក្យសម្តីរបស់ ឌុច មើលទៅដូចជាមានអំណាចខ្លាំងណាស់ ហើយអ្នកយាមនោះមើលទៅដូចជាកណ្តុរដែលញ័រទទ្រើកនៅចំពោះមុខឆ្មាអីចឹង» ។ ឌុច ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សភាគតិចដែលបង្កើតចំណងរវាងចៅហ្វាយ-កូនចៅដែលមានបន្តរហូតដល់ក្រោយការកាន់កាប់នៃរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត ។

បណ្ណសារដ្ឋាននៅមន្ទីរស-២១ត្រូវបានរំពឹងទុកថានឹងត្រូវកម្ទេចចោលតាំងពីពេលនោះម៉្លេះ ប៉ុន្តែ ឌុច មិនធ្វើតាមបញ្ជានោះទេ ។ ជាលទ្ធផល វាបានជះឥទ្ធិពលយ៉ាងអាក្រក់ដល់ នួន ជា ដែលជាបងធំទី២ ។ ក្រៅពីមិនបានធ្វើតាមបញ្ជា ឌុច ត្រូវបានរាយការណ៍ថាពុំមានទំនាក់ទំនងល្អរួចទៅហើយជាមួយ នួន ជា នៅពេលដែល នួន ជា គ្រប់គ្រងលើ សុន សេន ។ ទោះបីជា នួន ជា មានឋានៈខ្ពស់ជាង សុន សេន ក៏ដោយ ក៏ចំណងរបស់ ឌុច រវាងចៅហ្វាយ-កូនចៅមានភាពរឹងមាំគ្រប់គ្រាន់ក្នុងការជួយសង្គ្រោះជីវិតរបស់គាត់បាន ។ ឌុច បង្រៀនកូនរបស់ សុន សេន នៅក្នុងជំរំមួយ ហើយបានក្លាយទៅជាមិត្តជិតស្និទ្ធជាមួយសមាជិករបស់គណៈមជ្ឈិមម្នាក់ គឺប្រពន្ធរបស់ ខៀវ សំផន ។ នេះប្រហែលមកពីទំនាក់ទំនងបុគ្គលយ៉ាងស្អិតរមួតរបស់ ឌុច ជាមួយនឹង សុន សេន ហើយមើលទៅ ទើបធ្វើឲ្យប្រពន្ធរបស់គាត់អាចរួចរស់ជីវិតបាន ។ ចំណងរវាងចៅហ្វាយ-កូនចៅនេះមានទំនាក់ទំនងស្និទ្ធស្នាលជាជាងគ្រាន់តែទាក់ទងនឹងការប្រើប្រាស់កូនចៅជាឧបករណ៍ប៉ុណ្ណោះ ដូចជាទំនាក់ទំនងរវាង វ៉ាន់ ណាត និង ឌុច និងអ្នកយាមគុកផ្សេងៗទៀតផងដែរ ។ យ៉ាងណាមិញ ចៅហ្វាយចុងក្រោយនិងសំខាន់បំផុតនៅក្នុងពេលដែលមន្ទីរស-២១មានរូបរាងជាគុកនោះគឺអង្គការ ។

អង្គការសំដៅទៅលើមេដឹកនាំរបស់ខ្មែរក្រហម ។ វាគ្មានអ្វីខ្ពស់ជាងអង្គការទេ គឺមានតែមនុស្សដែលនៅពីក្រោមអង្គការប៉ុណ្ណោះ ។ អំណាចរបស់អង្គការមិនអាចប្រៀបផ្ទឹមនឹងនរណាម្នាក់បានទេ ព្រោះថាអំណាចនេះដូចជាអំណាចរបស់ទេវរាជអីចឹង ដូចដែលអ្នកយាមម្នាក់បានលើកឡើងថា: «អង្គការមានភ្នែកគ្រប់ទីកន្លែង ។ អង្គការគ្មានកំហុស ហើយអង្គការមានសិទ្ធិចាប់មនុស្សពេញទីតែម្តង» ។ នៅក្នុងឯកសារ អតីតអ្នកយាមម្នាក់ឈ្មោះ ខន បានប្រាប់ពីទំនាក់ទំនងរបស់គាត់ជាមួយអង្គការ ។ «ដើម្បីបង្ហាញពីតួនាទី ក៏ដូចជាភាពស្មោះត្រង់របស់ខ្ញុំជាមួយអង្គការ ខ្ញុំក៏សម្លាប់មនុស្សដើម្បីបញ្ជាក់ប្រាប់ថាខ្ញុំជាកូនរបស់អង្គការ» ។ ខន និយាយយ៉ាងស្មោះត្រង់ពីអំណាចដ៏សម្បើមរបស់ចៅហ្វាយ (អង្គការ) នៅពេលដែលគាត់ប្រើពាក្យ «កូន» ។ គាត់បានទទួលស្គាល់ថាអង្គការបានក្លាយទៅជាឪពុកម្តាយ និងអ្នកមើលថែទាំគាត់ ។ មេដឹកនាំនៃរបបខ្មែរក្រហមបានព្យាយាមអស់ពីសមត្ថភាពដើម្បីពង្រឹងនូវអំណាចរបស់ខ្លួនក្នុងការបំបែកកូនចេញពីឪពុកម្តាយ ធ្វើឲ្យក្រុមគ្រួសារប្រឆាំងគ្នាទៅវិញទៅមកដើម្បីជម្រះឫស «ខ្សែខ្មាំង» នៅក្នុងបក្សចេញឲ្យអស់ហើយ និងព្យាយាមធ្វើឲ្យក្លាយទៅជាអ្នកផ្គត់ផ្គង់ជីវិតដ៏សំខាន់ពុំអាចខ្វះបានសម្រាប់ប្រជាជនកម្ពុជាទាំងអស់គ្នា ។

អង្គការមិនត្រឹមតែក្លាយជាអ្នកផ្គត់ផ្គង់សម្រាប់ការរស់រានតែមួយគត់ប៉ុណ្ណោះ ថែមទាំងផ្តល់នូវការគាំទ្រគ្រប់ប្រភេទទាំងអស់ដូចដែលអង្គការបានកំណត់យកគ្រូពេទ្យ គ្រូបង្រៀន កូនសិស្សវិស្វករ មេធាវី អ្នកធ្វើការនៅធនាគារ អ្នករបាំ និង ពាណិជ្ជករទៅសម្លាប់ស្ទើរគ្មានសល់ ។ ជាលទ្ធផល អង្គការបានក្លាយទៅជា

ប្រភពតែមួយគត់សម្រាប់ការគាំពារផ្នែកផ្សេងៗទាំងអស់រួមមានសង្គមចិត្តសាស្ត្រ និងរូបរាងកាយ ។ បក្សដែលជាពាក្យមួយប្រើប្រាស់សម្រាប់សម្គាល់អង្គការដែរនោះបានកម្ទេចអ្នកជំនាញប្រភេទនេះទាំងអស់ក្នុងគោលបំណងដើម្បីធ្វើឲ្យមនុស្សម្នាក់ៗកាន់តែមានការពឹងផ្អែកមកលើអង្គការទាំងស្រុង ។ នេះបានធ្វើឲ្យអង្គការក្លាយទៅជាដំណោះស្រាយតែមួយគត់សម្រាប់រាល់បញ្ហារបស់បុគ្គលគ្រប់រូប ។ លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ បានលើកឡើងពីជំនាញទូទៅបំផុតនៅក្នុងចំណោមគណៈមជ្ឈិមៈ

នៅក្នុងប្រទេសកម្ពុជាទំនាក់ទំនងរវាងគ្រូ-សិស្ស គឺជាចំណុចដ៏សំខាន់មួយទៀត ព្រោះថាវាជាកន្លែងដែលអំណាច និងការធ្វើតាមបង្គាប់បញ្ជាត្រូវបានអនុវត្តឡើង ។ វាមិនមែនជារឿងចៃដន្យទេកាលដែលមេដឹកនាំខ្មែរក្រហមជាច្រើនមានមុខជំនាញជាគ្រូបង្រៀនដែលពូកែខាងគ្រប់គ្រងថ្នាក់រៀនដែលពោរពេញទៅដោយមនុស្សវ័ងវូសពិបាកប្រដៅ (ត្រង់នេះគឺយើងមិននិយាយពីប្រទេសជាតិនោះទេ) ។

អង្គការមើលឃើញខ្លួនឯងថា ទទួលបាននូវការគាំទ្រជាសមូហភាពពីសំណាក់កូនចៅរបស់ខ្លួន ។ នេះគឺមានសារសំខាន់ខ្លាំងណាស់ក្នុងការទទួលបាននូវការគាំទ្រពីសង្គមនិងជាសមូលភាពនៅក្នុងទំនាក់ទំនងរវាងចៅហ្វាយ-កូនចៅនេះ ។ អង្គការប្រាកដជានិយាយថា ការសម្រេចចិត្តណាមួយរបស់អង្គការជាការសម្រេចចិត្តមួយរបស់សមូហភាព ហើយមិនមែនជារបស់បុគ្គលផ្ទាល់ខ្លួន ឬក្រុមមួយក្តាប់តូចណាមួយនោះទេ (ទោះបីជាការពិតអ៊ីចឹងមែនក៏ដោយ) ។ ចំណែកឯកូនចៅវិញគោរពនិងធ្វើតាមបញ្ជាដែលដាក់មកឲ្យពួកគេជាដរាប ។ អំណាចដ៏លើសលុបរបស់អង្គការនិងតួនាទីជាចៅហ្វាយចុងក្រោយបង្អស់របស់ប្រជាជនកម្ពុជាទាំងមូលអាចក្លាយទៅជាអ្វីដែលនាំទៅរកការធ្លាក់ចុះរបស់របបនេះផងដែរ ។

គំនិតដែលគិតតែពីខ្លួនឯងរបស់អង្គការបានកើនឡើងយ៉ាងខ្លាំងក្លាហួសធ្វើឲ្យគេគិតថា កូនចៅរបស់ខ្លួនលែងមានប្រយោជន៍ទុកប្រើប្រាស់ទៀតហើយ ។ ដូចដែលពាក្យស្លោកមួយរបស់អង្គការនិយាយថា «ទុកមិនចំណេញ ដកចេញមិនខាត» ឬស្រដៀងគ្នាទៅនឹង «សម្លាប់មនុស្សប្រចាំជាជាងទុកខ្លាំងឲ្យនៅរស់» ។ ផ្ទុយទៅនឹងពាក្យស្លោកទាំងនេះ ឌុច ដែលជាកម្មាភិបាលម្នាក់ក៏ដូចជាអង្គការផ្ទាល់ដែលជឿជាក់ថាខ្លួនមិនបានធ្វើអ្វីដោយច្រឡំទេ ។ ហ៊ឹម ហ៊ុយ ដែលជាអ្នកយាមម្នាក់បាននិយាយថា «នៅពេលដែលអង្គការចាប់ខ្លួនមនុស្ស អង្គការចាប់ខ្លួនសត្រូវរបស់បក្សតែប៉ុណ្ណោះ .....បក្ស ក៏ដូចជាមន្ទីរស-២១មិនចាប់ខ្លួនមនុស្សដោយភ័ន្តច្រឡំនោះទេ» ។ ដោយសារតែអង្គការមិនបានធ្វើអ្វីមួយដោយភ័ន្តច្រឡំ ទើបបក្សអង្គការត្រូវតែបង្កើតនូវមូលហេតុមួយឲ្យសមហេតុផលដើម្បីបញ្ជាក់ពីការធ្លាក់ចុះរបស់កម្ពុជាប្រជាធិប-តេយ្យ ។ ពួកគេត្រូវការមូលហេតុដើម្បីដោះស្រាយចំពោះការស្លាប់របស់ប្រជាជនដោយសារការអត់ឃ្លាននិងហេតុអ្វីបានជាទិន្នផលវិស័យកសិកម្មមិនអាចសម្រេចបានដូចបំណង ។ ដូច្នេះហើយទើបធ្វើឲ្យមានការសរសេរចម្លើយសារភាពកើតឡើង ។

អង្គការត្រូវការអ្នករងកំហុសម្នាក់ដើម្បីការពារខ្លួនដោយសារតែអង្គការតែងតែជឿថា ខ្លួនគឺល្អឥតខ្ចោះ ហើយមិនដែលបរាជ័យ ។ ញ៉ែម អេន បានពន្យល់ថា «ទួលស្លែងជាបេះដូងនៃចលនា និងជាបេះដូងនៃប្រទេស ។ ប្រសិនបើប្រព័ន្ធសន្តិសុខមិនត្រូវបានស្ថាបនាឡើង នោះនឹងមានចលាចលកើតឡើង ហើយជាតិទាំងមូលប្រាកដជាជួបបញ្ហា» ។ មន្ទីរស-២១ បានក្លាយទៅជា «បេះដូង» ដោយសារតែមន្ទីរនេះបានជម្រះសមាសធាតុអាក្រក់ចេញពីប្រទេសយ៉ាងនេះហើយទើបធ្វើឲ្យអង្គការមានជីវិតរស់រានជានិច្ច ។ វាក៏ក្លាយទៅជាលេសមួយដែលអ្នកដឹកនាំត្រូវការប្រើប្រាស់ដើម្បីបិទបាំងពីចំណុចអាក្រក់របស់ខ្លួនដែរ ។ នៅមន្ទីរស-២១ ខ្សែខ្លាំងត្រូវបានកម្ទេចដូចគ្នាទៅនឹងអ្វីដែលបានធ្វើឡើងកាលពីអតីតកាលរបស់កម្ពុជាអ៊ីចឹងដែរ ។ នៅពេលដែលអ្នកទោសម្នាក់សារភាព អ្នកទោសនោះនឹងផ្តល់ឈ្មោះមិត្តភក្តិគ្រួសារ និងអ្នកស្គាល់ទាំងប៉ុន្មានរបស់ខ្លួនទៅឲ្យអ្នកសួរចម្លើយ ។ បន្ទាប់មក ខ្សែស្រឡាយនោះនឹងត្រូវដាក់ទោសដូចនៅក្នុងរឿង ទុំទាវ អ៊ីចឹងដែរ ត្រង់កន្លែងដែល អរជូន មិនបានគោរពទៅតាមបញ្ជារបស់ស្តេច ហើយក្រុមគ្រួសារទាំងមូល និងខ្សែស្រឡាយពាក់ព័ន្ធទាំងអស់ត្រូវបាន «...កម្ទេចឲ្យទៅជាផេះម្តងៗ» ។ ការមិនគោរពបញ្ជារបស់កូនចៅចំពោះអង្គការនឹងត្រូវបានដាក់ទោសយ៉ាងធ្ងន់ធ្ងរ និងសាហាវបំផុត ដូចអ្វីដែលស្តេចរាមាបានធ្វើ

ដាក់កូនចៅរបស់ខ្លួនអឺចឹង ។ នេះជាឧទាហរណ៍មួយទៀតដែលបង្ហាញពីរបៀបដែលអតីតកាលនៅបន្តស្ថិតថេរនៅក្នុងការកាន់កាប់របស់ខ្មែរក្រហម ។

អង្គការជាកន្លែងសម្រាប់ការពារមេដឹកនាំដូចដែល នួន ជា បានពន្យល់ថា «យើងពឹងផ្អែកទាំងស្រុងទៅលើការលាក់ការណ៍... យើងបង្កើតនូវវិធីសាស្ត្រក្នុងការលាក់ការ ទីមួយ) ដើម្បីការពារខ្លួនឯងផ្ទាល់ និងទីពីរ) កែនកម្លាំងឲ្យបានកាន់តែច្រើន និងចុងក្រោយបម្រើដល់ការតស៊ូរបស់យើង.....» ពាក្យថា អង្គការជាពាក្យមួយសម្រាប់សម្គាល់មនុស្សមួយក្រុម ហើយវាមិនបានផ្តល់ឈ្មោះបុគ្គលណាមួយជាក់លាក់ ឬក៏សម្គាល់ទៅលើបុគ្គលណាដែលជាមេដឹកនាំនោះទេ ។ ពាក្យនេះធ្វើឲ្យមានគម្លាតឆ្ងាយហើយស្ទើរតែលែងមានទៀត ។ នៅក្នុងការលាក់ការអ្នកក្រោមបង្គាប់មិនបានដឹងថា អ្នកដឹកនាំនៅទីណា ឬក៏ជានរណាទេ ។ ការដឹកនាំដោយមិនចេញមុខបានការពារសមាជិកម្នាក់ៗ ប្រសិនបើរដ្ឋាភិបាលបែកបាក់គ្នាឬក៏មានការបះបោរកើតឡើងនៅអំឡុងពេលការកាន់កាប់ ។

មេដឹកនាំជាកូនចៅរបស់អង្គការ ពួកគេត្រូវតែធ្វើឲ្យអង្គការមើលទៅដូចជាទេវរាជ ដោយសារតែអង្គការមិនដែលមានកំហុស ហើយយ៉ាងហោចណាស់មិនរំពឹងទុកថានឹងធ្វើខុសផងដែរ ។ អង្គការបានក្លាយទៅជាចៅហ្វាយ ចុងក្រោយបំផុតរបស់មនុស្សគ្រប់រូប ជាពិសេសមេដឹកនាំដោយសារតែអង្គការជាកន្លែងដែលផ្តល់ឲ្យពួកគេនូវការការពារ និងសន្តិសុខ ខណៈពេលដែលមេដឹកនាំខិតខំធ្វើយ៉ាងណាដើម្បីជម្រះចេញនូវការបរាជ័យដោយធ្វើការទម្លាក់កំហុសទាំងស្រុងមកលើសត្រូវដែលទទួលឥទ្ធិពលពីបរទេស ។ នួន ជា បានធ្វើការពិពណ៌នាយ៉ាងក្បោះក្បាយអំពីសារសំខាន់ដ៏ចាំបាច់របស់អង្គការ ៖

របៀបរៀបចំអំពីការដឹកនាំត្រូវតែបានការការពារគ្រប់កាលៈទេសៈទាំងអស់ ។ ឲ្យតែការដឹកនាំនៅរស់ បក្សនឹងមិនស្លាប់ទេ ។ វាប្រហែលជាមិនអាចប្រៀបធៀបបានរវាងកម្មាភិបាលផ្តើមពីរទៅបីនាក់និងសមាជិកពីររយទៅបីរយនាក់ ...បើមិនអឺចឹងទេ បក្សនឹងគ្មានក្បាល ហើយមិនអាចដឹកនាំការតស៊ូនេះបានទេ ។

អង្គការចោទប្រកាន់មេដឹកនាំចំពោះការបរាជ័យរបស់ខ្លួន និងដើម្បីការពារខ្លួនឯងកុំឲ្យមានកំហុស ។ អង្គការជាអ្នកផ្គត់ផ្គង់ដ៏សំខាន់និងជាអ្នកបំផ្លាញដ៏ធំមួយរបស់កម្ពុជាប្រជាធិបតេយ្យដែរ ។ មេដឹកនាំប្រហែលជាមិនអាចរស់ ដោយមានអង្គការ ឬក៏គ្មានអង្គការនោះទេ ។

ដូចគ្នានៅក្នុងអតីតកាលរបស់កម្ពុជា និងនៅអំឡុងពេលនៃការកាន់កាប់របស់អង្គការ សារសំខាន់នៃការដឹកនាំនៅក្នុងប្រទេសកម្ពុជាគឺការកេងប្រវ័ញ្ចជាជាងការបម្រើសេវាកម្មជូនដល់ប្រជាពលរដ្ឋ ហើយវាជាការឧបត្ថម្ភដោយចង់បានរបស់តបស្នងមកវិញ ជាជាងការសហការមួយដ៏ពិតប្រាកដ ។ ទំនាក់ទំនងរវាងចៅហ្វាយ-កូនចៅគឺនៅតែបន្តរហូតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទោះបីជារបបនេះមានបំណងចង់ធ្វើការផ្លាស់ប្តូរទាំងស្រុង ក៏ដូចជាធ្វើបដិវត្តន៍ទៅលើរដ្ឋាភិបាលកម្ពុជាក៏ដោយ ។ ទោះបីជារចនាសម្ព័ន្ធរបស់រដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់អំណាចដើម្បីប្រើមនុស្សធ្វើការនៅតែបន្តមានជានិច្ច ។ ការបង្ខំឲ្យធ្វើការនិងអាហារតិចតួចត្រូវបានផ្តល់ឲ្យជារង្វាន់ដើម្បីបន្តនូវរចនាសម្ព័ន្ធដូចគ្នាមួយទៅនឹងអ្វីដែលស្តេច សូរ្យ វរ្ម័ន ទីពីរដែលជាស្តេចត្រូវគេសាងសង់ផ្នូរដ៏ធំជាងគេបង្អស់ទុកឲ្យគាត់ ។ វាជាវិមានសម្រាប់បុគ្គលម្នាក់ដែលប្រើប្រាស់កម្លាំងសមូហភាពដូចគ្នាទៅនឹងការបង្ខំឲ្យធ្វើការរបស់ ប៉ុល ពត ឬក៏អង្គការដើម្បីបង្កើតរដ្ឋកុម្មុយនីស្តផ្តាច់ការទីមួយ ។ នៅចុងបញ្ចប់ ចំណងទាក់ទងគ្នារវាងចៅហ្វាយ-កូនចៅនៅតែបន្តមាននៅក្នុងមន្ទីរស-២១ ហើយបន្តកើនឡើងរហូតទៅដល់ជួរតំណែងជាន់ខ្ពស់បំផុតរបស់អង្គការ ។ **ចន ម៉ាំងហ៊ើ**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**

# ការបង្ហាញអំពីគោលបំណងនៃអំពើប្រល័យពូជសាសន៍ : យុត្តិសាស្ត្រ អន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើសំណុំរឿង០០២

## ១) សេចក្តីផ្តើម : បញ្ហានៃគោលបំណង

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាស ដោយចោទប្រកាន់អំពើប្រល័យពូជសាសន៍នៅក្នុងសំណុំរឿង០០២ ប្រឆាំងនឹងជនជាប់ចោទដែលមានឈ្មោះដូចជា នួន ជា, ខៀវ សំផន, អៀង សារី, និង អៀង ធីរិទ្ធ ដែលត្រូវបានចាត់ទុកជាសមាជិកអ្នកនៅរស់រានមានជីវិតថ្នាក់ខ្ពស់បំផុតរបស់ខ្មែរក្រហម ពីបទធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាមនិងជនជាតិភាគតិចវៀតណាម ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវដាក់បញ្ចូលបទល្មើសអំពើប្រល័យពូជសាសន៍ដោយផ្អែកទៅលើការធ្វើទុក្ខបុកម្នេញពុទ្ធសាសនារបស់ខ្មែរក្រហមមិនទាន់ត្រូវបានសម្រេចនៅឡើយទេ ។

ស្របពេលជាមួយគ្នានេះ អ្នកជំនាញផ្នែកច្បាប់បានទទួលស្គាល់ថា ទោះបីជាលក្ខណៈសម្គាល់របស់អំពើប្រល័យពូជសាសន៍គឺជាការសម្លាប់រង្គាលក៏ដោយ តែបើតាមនិយមន័យផ្លូវច្បាប់ រឿងនេះត្រូវបានកំណត់ត្រឹមតែជាការធ្វើទុក្ខបុកម្នេញមកលើក្រុមសាសនា ជាតិសាសន៍ ក្រុមជាតិពន្ធ និងជនជាតិ តែប៉ុណ្ណោះ ។ ដូច្នេះ ជាទូទៅវាត្រូវទទួលស្គាល់ថា «ឧក្រិដ្ឋកម្មភាគច្រើនត្រូវប្រព្រឹត្តដោយខ្មែរក្រហម» មិនបានស្ថិតនៅក្រោមបទដ្ឋាននៃអំពើប្រល័យពូជសាសន៍ឡើយ «ពីព្រោះខ្មែរក្រហមមានបំណងចង់កម្ទេចសត្រូវផ្នែកនយោបាយ» ដែលខុសពីអ្វីដែលបានចែងក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍ ។

អត្ថបទស្រាវជ្រាវនេះមានបំណងចង់រៀបរាប់ពីយុត្តិសាស្ត្រច្បាប់អន្តរជាតិទាក់ទងទៅនឹងបញ្ហាមួយដែលទំនងជាមានសារ-សំខាន់សម្រាប់ការត្រួតពិនិត្យទៅលើការចោទប្រកាន់នៃអំពើប្រល័យពូជសាសន៍ទាំងនេះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលរួមមាន : ការបង្កើតពីបំណងពិរុទ្ធប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ចុងចោទ ដោយសម្អាងទៅលើកាលៈទេសៈជាក់ស្តែងដែលនៅជុំវិញ ។ ជាពិសេសអត្ថបទស្រាវជ្រាវនេះនឹងព្យាយាមរុករកដើម្បីបង្ហាញពីកត្តាសំខាន់បួនយ៉ាងដែលតុលាការអន្តរជាតិបានរកឃើញទាក់ទងទៅនឹងការបង្ហាញថាការប៉ុនប៉ងក្នុងអំពើប្រល័យពូជសាសន៍ត្រូវបានយកមកពិចារណាដោយត្រឹមត្រូវៈ ១) សេចក្តីថ្លែងការណ៍របស់ចុងចោទ និងការចូលរួមសហការរបស់អ្នកទាំងនោះ ២) ទំហំនៃអំពើឃោរឃៅដែលបានកើតឡើង ៣) ការកំណត់ទិសដៅជាប្រព័ន្ធទៅលើក្រុមជនរងគ្រោះ និង៤) ភ័ស្តុតាងនៃអំពើឃោរឃៅដែលបានគ្រោងទុក ។


អ្នកទស្សនាការតាំងពិព័រណ៍ករណី០០២ នៅទួលស្លែង

អត្ថបទស្រាវជ្រាវនេះក៏ចង់ផ្តល់នូវការអង្កេតលើកដំបូងទាក់ទងនឹងការអនុវត្តយុត្តិសាស្ត្រអន្តរជាតិចំពោះបរិបទកម្ពុជាដែរ ។ វាមានសារសំខាន់ក្នុងការដឹងថាយុត្តិសាស្ត្រទាំងនោះមិនទាន់បាន

ផ្លាស់ប្តូរទេ ហើយថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវតែអនុវត្តវិធីថ្មីដោយចៀសមិនផុត ។

## ២) អំពើប្រល័យពូជសាសន៍ ៖ និយមន័យតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ក) អំពើពិរុទ្ធ

មាត្រា៤ នៅក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា អំពើប្រល័យពូជសាសន៍ជា «ការប្រព្រឹត្តបទល្មើសដោយមានបំណងបំផ្លាញទាំងស្រុងឬដោយផ្នែកនូវក្រុមជនជាតិមួយ ជាតិពន្ធ ជាតិសាសន៍ និងក្រុមសាសនាណាមួយ» ។ តុលាការអន្តរជាតិបានបកស្រាយជាភាសានៅក្នុងលក្ខខណ្ឌស្រដៀងគ្នាដោយបានដាក់ការទាមទារជាពិសេស ឬក៏ «ការប៉ុនប៉ងជាពិសេស» ។ ដូច្នេះ ការបង្ហាញការទទួលខុសត្រូវសម្រាប់គោលការណ៍មួយនៃអំពើប្រល័យពូជសាសន៍របស់ជនដៃដល់ «ទាមទារឲ្យមានការបង្ហាញការប៉ុនប៉ងក្នុងការប្រព្រឹត្តសកម្មភាព» ក៏ដូចជា «ការបង្ហាញនូវការប៉ុនប៉ងក្នុងការបំផ្លាញក្រុមមួយដែលបានកំណត់ទុកជាមុន» ។ ហើយនៅខណៈដែលអំពើប្រល័យពូជសាសន៍គឺជា «ឧក្រិដ្ឋកម្មមួយធំ» ដូច្នេះការប៉ុនប៉ងបំផ្លាញក្រុមដែលត្រូវបានការពារ «ដោយផ្នែក» ត្រូវតែបានដាក់បញ្ចូល «យ៉ាងហោចណាស់ជាមនុស្សមួយក្រុមដែលមានចំនួនច្រើន» ។ ការគណនាទៅលើផ្នែកដែលបានកំណត់មានពាក់ព័ន្ធនឹងការត្រួតពិនិត្យទៅលើទំហំណាមួយ ទាំងពាក្យជាក់លាក់ និង «មានទំនាក់ទំនងទៅដល់ទំហំទាំងអស់នៃក្រុមទាំងមូល» ។ សារសំខាន់នៃផ្នែកដែលបានកំណត់ទុកចំពោះក្រុមទាំងមូល ហើយនិង «តំបន់នៃសកម្មភាពនិងការគ្រប់គ្រងរបស់ជនដៃដល់» ។

### ខ) មូលហេតុ និង គោលបំណង

តុលាការអន្តរជាតិបានសង្កត់ធ្ងន់សាជាថ្មីទៅលើសារសំខាន់ក្នុង «ការញែកឲ្យដាច់រវាងមូលហេតុនិងគោលបំណង» ដូចជា «នៅក្នុងករណីអំពើប្រល័យពូជសាសន៍ មូលហេតុដែលជនជាប់ចោទចង់កម្ទេចក្រុមជនរងគ្រោះដោយគិតថាខ្លួនឯងគ្មានទោសកំហុសទាំងអស់» ។ ដូច្នេះ នៅខណៈដែលជនដៃដល់ម្នាក់ត្រូវបានជំរុញឲ្យប្រព្រឹត្តអ្វីមួយដោយមិនដឹងពីគោលបំណងច្បាស់លាស់ ដូចជាៈ ការបង្កើនផ្នែកសេដ្ឋកិច្ចផ្ទាល់ខ្លួន ផលប្រយោជន៍យោធា ឬចង់បណ្តេញក្រុមមួយឲ្យចេញពីទឹកដីរបស់ក្រុមនោះ ។ ប្រការខាងលើនេះមិនមែនជាគោលបំណងជាក់លាក់ដើម្បីសម្រេចបានតាមមធ្យោបាយអំពើប្រល័យពូជសាសន៍ទេ ។ ស្របពេលជាមួយគ្នានេះដែរ អ្នកជំនាញផ្នែកច្បាប់បានទទួលស្គាល់ថា «ប្រភេទនៃអំពើប្រល័យពូជសាសន៍» គឺជាផ្នែកមួយដែលការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍មានលក្ខណៈស្រដៀងគ្នាទៅនឹងគោលបំណងនៃការ «ស្អប់ចំពោះក្រុមដែលត្រូវបានកំណត់ទិសដៅ» ។

### គ) ការទទួលខុសត្រូវទីពីរ ៖ ការជួយ និង ការជំរុញ

ដើម្បីផ្តល់នូវការទទួលខុសត្រូវសម្រាប់ជួយនិងជំរុញអំពើប្រល័យពូជសាសន៍មុនតុលាការអន្តរជាតិ បុគ្គលម្នាក់មិនចាំបាច់មាន «ការប៉ុនប៉ងជាក់លាក់ក្នុងការបំផ្លាញជាតិសាសន៍មួយ ក្រុមជនជាតិ ជាតិពន្ធ ជាតិសាសន៍និងក្រុមសាសនាណាមួយ» នោះទេ ។ ផ្ទុយទៅវិញ គោលបំណងពិរុទ្ធគឺជា «ការប៉ុនប៉ង... ដែលគេដឹងថាជាការជួយ ឬជំរុញមនុស្សម្នាក់ឬមនុស្សច្រើននាក់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍» ។ ធាតុផ្សំនៃបំណងពិរុទ្ធសម្រាប់ជួយនិងជំរុញអំពើប្រល័យពូជសាសន៍ត្រូវបានបំបែកទៅជាពីរ ៖ ទីមួយ ត្រូវមានការជួយនិងជំរុញឲ្យជនដៃដល់មានប្រតិបត្តិការអំពើប្រល័យពូជសាសន៍នៃអំពើពិរុទ្ធ (ឧទាហរណ៍ៈ ជួយនរណាម្នាក់ឲ្យសម្លាប់សមាជិកនៃក្រុមដែលត្រូវបានការពារណាមួយ) ។ ទីពីរ មនុស្សម្នាក់នោះត្រូវតែធ្វើអ្វីចឹងដោយដឹងច្បាស់ (ឬមានហេតុផលច្បាស់លាស់) នៃគោលការណ៍ប៉ុនប៉ងប្រល័យពូជសាសន៍ជាក់លាក់ណាមួយ ។

គួរកត់សម្គាល់ថា ស្ថិតនៅក្រោមបទដ្ឋាននេះ បុគ្គលម្នាក់ប្រហែលជាទទួលខុសត្រូវសម្រាប់ការជួយនិងជំរុញឲ្យមានអំពើប្រល័យពូជសាសន៍ ទោះបីជាគាត់មិនបានចូលរួមការប៉ុនប៉ងប្រល័យពូជសាសន៍ជាមួយជនដៃដល់ក៏ដោយ ។ ខណៈដែលអត្ថបទស្រាវជ្រាវនេះផ្តោតជាសំខាន់ទៅលើបទដ្ឋានច្បាប់សម្រាប់ការប៉ុនប៉ងប្រល័យពូជសាសន៍ ដូច្នេះ វាមិនមានទម្រង់នៃការទទួលខុសត្រូវខុសៗគ្នានោះទេ ដែលជនជាប់ចោទអាចកាត់ទោសអំពើប្រល័យពូជសាសន៍កំបាំងមុខបាន ។

## ៣) ការទាញទៅដល់ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍

នៅក្នុងករណីរបស់ជនជាប់ចោទ អាកាយីស៊ុ *(Akayesu)*

ការកាត់ទោសពីអំពើប្រល័យពូជសាសន៍លើកទីមួយ នៅក្នុងតុលាការអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានបង្ហាញថា «ការប៉ុនប៉ង គឺជាកត្តាចម្បងមួយដែលពិបាក ហើយថែមទាំងមិនអាចបង្ហាញឲ្យឃើញបាន» ដោយផ្ទាល់ និងគ្មានចម្លើយសារភាពទៀត ។ តុលាការនេះបានបង្ហាញបន្ថែមទៀតថា ទោះបីជា «ការប៉ុនប៉ងប្រល័យពូជសាសន៍ជាប់ទាក់ទងនឹងសកម្មភាពជាក់លាក់ណាមួយក៏ដោយ» ប្រហែលជា «ត្រូវបានទាញពីស្ថានភាពទូទៅ» ដែលសកម្មភាពនោះបានកើតឡើង ។ នៅក្នុងន័យម៉្យាងទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានទទួលស្គាល់ថា ការអវត្តមានកាលៈទេសៈពិសេស ឬក៏ចម្លើយសារភាព ភ័ស្តុតាងផ្ទាល់នៃចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍នឹងកម្រអាចទៅរួច ទោះបីជាបំណងបែបនេះនៅមានក៏ដោយ ។ ដូច្នេះ តុលាការត្រូវតែពឹងផ្អែកទៅលើការទាញដែលបានមកពីកាលៈទេសៈជាក់ស្តែងនៅជុំវិញ ដើម្បីបង្ហាញថាតើជនជាប់ចោទបានសម្តែងនូវការប៉ុនប៉ងប្រល័យពូជសាសន៍ដែរឬអត់ ។

ការស៊ើបអង្កេតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានបង្ហាញនូវអ្វីដែលនឹងកើតឡើងនៅពេលអនាគត ។ វាបានបង្ហាញថា នៅខែមករា ឆ្នាំ២០១០ រាល់ការកាត់ទោសពីអំពើប្រល័យពូជសាសន៍ដែលបានជោគជ័យ នៅក្នុងវេទិកាអន្តរជាតិគឺផ្អែកទៅលើកម្រិតមួយចំនួនដែលយោងទៅលើការប៉ុនប៉ងប្រល័យពូជសាសន៍ចេញពីបរិបទជាក់ស្តែងដែលជនជាប់ចោទបានប្រព្រឹត្ត ។ ការពិនិត្យមើលឡើងវិញអំពីសំណុំរឿងច្បាប់បានបង្ហាញនូវកត្តាសំខាន់បួនយ៉ាងនៅក្នុងការវិភាគបរិបទនេះ ៖ ១) សេចក្តីថ្លែងការណ៍ដែលបង្ហាញអំពីការប៉ុនប៉ងប្រល័យពូជសាសន៍ ២) ទំហំនៃអំពើសាហាវឃោរឃៅដែលបានប្រព្រឹត្ត ៣) ការកំណត់ជាប្រព័ន្ធនៃក្រុមត្រូវបានការពារ និង៤) ភ័ស្តុតាងបញ្ជាក់ថា អំពើពិរុទ្ធត្រូវបានរៀបចំដោយមានគម្រោងច្បាស់លាស់ ។

វាត្រូវបានសង្កត់ធ្ងន់ថា ការទាញទៅដល់ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍មិនមែនជាការស៊ើបសួរតែពីខាងក្រៅទេ ។ ទោះបីជាកត្តាទាំងបួននេះត្រូវបានអះអាងថា មានប្រសិទ្ធភាពទៅលើតុលាការអន្តរជាតិក៏ដោយ ក៏គ្មានអ្វីដែលអាចរារាំងតុលាការនៅពេលអនាគតពីការបង្ហាញនូវកត្តាបន្ថែមទេ ។ ដូច្នេះ គ្មានកត្តារួមផ្សំជាក់លាក់ណាមួយដែលអាចបញ្ជាក់ពីភាពចាំបាច់ឬគ្រប់គ្រាន់ដើម្បីបង្ហាញអំពីចេតនាប្រល័យពូជសាសន៍ឡើយ ។ ហើយកត្តាដែលទាក់ទងគឺជាកម្រិតមួយដែលបានបង្ហាញ ។ (ឧទាហរណ៍ ភាពច្បាស់លាស់ដែលសេចក្តីថ្លែងការណ៍មួយបានបង្ហាញនូវចេតនាប្រល័យពូជសាសន៍ ការពង្រីកនូវការកំណត់ជាប្រព័ន្ធ) ។ ជាងនេះទៅទៀត ការវិនិច្ឆ័យផ្នែកច្បាប់ត្រូវបានបង្កើតឡើងគឺថា ការទាញទៅដល់បំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាក់លាក់ណាមួយទាមទារឲ្យគិតពិចារណាឲ្យបានច្រើនជាងការសម្តែងការស្អប់លើជាតិពន្ធនិងជាតិសាសន៍របស់ជនជាប់ចោទនៃក្រុមដែលបានកំណត់ទុក ។ ដូចដែលបណ្តឹងឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី បានបញ្ជាក់អំពីសំណុំរឿងរបស់ ជេលីសឹក គឺថា ការបង្ហាញការទទួលខុសត្រូវលើបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងគោលដៅនៃការសម្លាប់ក្រុមទទួលបានការការពារមិនចាំបាច់មានភ័ស្តុតាងគ្រប់គ្រាន់ដែលចេញពីគោលបំណងប្រល័យពូជសាសន៍ទេ ។ ផ្ទុយទៅវិញ តុលាការបានដឹកនាំការស៊ើបអង្កេតថាតើបរិបទជាក់ស្តែងទាំងមូលមាន «ការបង្ហាញទាក់ទងនឹងការបំផ្លាញមនុស្សមួយក្រុមនោះមែនឬអត់» ។ ចុងចោទនោះបានប្រព្រឹត្តសកម្មភាពពិរុទ្ធនៃអំពើប្រល័យពូជសាសន៍ នៅពេលដែលមានហេតុផលដោយជាតិសាសន៍ ជាតិពន្ធ ជនជាតិ ឬកំហឹងសាសនាគឺវាមិនគ្រប់គ្រាន់ទេ ។ ទាក់ទងទៅនឹងបំណងពិរុទ្ធគឺ «គោលបំណងបំផ្លាញ» ក្រុមដែលត្រូវបានការពារដោយមិនឲ្យនៅសល់ ។ ចុងក្រោយ យ៉ាងហោចណាស់តុលាការអន្តរជាតិមួយបានផ្តល់យោបល់ថា ដើម្បីបង្វែរគោលបំណងប្រល័យពូជសាសន៍ពីបរិបទដែលនៅជុំវិញ ដូចជាការទាញបែបនេះត្រូវតែជា «ការទាញដែលមានហេតុផល ដោយផ្អែកទៅលើភ័ស្តុតាង» និងការបកស្រាយ ។

### ក) វត្តមានទូទៅនៃអំពើប្រល័យពូជសាសន៍

ជាដំបូងដើម្បីធ្វើការវិនិច្ឆ័យបញ្ហានៃការទទួលខុសជាបុគ្គលរបស់ជនជាប់ចោទ តុលាការព្រហ្មទណ្ឌអន្តរជាតិចង់បង្កើតស្ថានភាពនៅក្នុងបញ្ហាទូទៅទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ។ នៅក្នុងការវិនិច្ឆ័យអំពីធាតុផ្សំនៃបំណងពិរុទ្ធនៅក្នុងជំហានដំបូងនេះ

«ការទាញដែលថា អំពើឃោរឃៅមួយចំនួនត្រូវជំរុញឲ្យមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ថែមទាំងជាកន្លែងដែលគោលបំណងរបស់បុគ្គលម្នាក់បានកំណត់មិនត្រូវបានបង្ហាញ» ។ អាចនិយាយមួយទៀតថា តុលាការមិនបានទាមទារនៅក្នុងការស៊ើបអង្កេតលើកទីមួយនេះថា កាលៈទេសៈជាក់ស្តែងបានចង្អុលទៅកាន់បុគ្គលច្បាស់លាស់ណាមួយទេ ៖ ពួកគេចង់បង្កើតថាតើស្ថានភាពទូលំទូលាយផ្តល់ថា នរណាម្នាក់បានធ្វើសកម្មភាពដោយមានបំណងប្រល័យពូជសាសន៍ ។ ស្រដៀងគ្នានេះដែរ ដើម្បីបង្ហាញពីរយៈពេលទូទៅនៃអំពើប្រល័យពូជសាសន៍អំពើពិរុទ្ធ តុលាការមិនបានអាស្រ័យទៅលើ «ថាតើសកម្មភាពនៅក្នុងសំណួរត្រូវបានប្រព្រឹត្តដោយជនជាប់ចោទឬអ្នកដទៃផ្សេងទៀត» ។

ប្រសិនបើតុលាការធ្វើការស្វែងរកភាពទូទៅនៃអំពើប្រល័យពូជសាសន៍ តុលាការត្រូវតែស៊ើបអង្កេតថាតើបុគ្គលនីមួយៗបានចូលរួមនៅក្នុងអំពើពិរុទ្ធប្រល័យពូជសាសន៍ដោយមានបំណងពិរុទ្ធឬក៏អត់ ។ ខណៈពេលដែលចំណុចនេះមានជាប់ពាក់ព័ន្ធនឹងការស៊ើបសួរលើកទីពីរទៅលើអង្គហេតុជាក់លាក់ទាក់ទងនឹងជនត្រូវចោទ តុលាការត្រូវតែបង្ហាញបន្ថែមទៅលើអ្វីដែលបានស្រាវជ្រាវនិងរកឃើញ ។ «បើទោះជាមិនមានការគាំទ្រការចោទប្រកាន់អំពើប្រល័យពូជសាសន៍ពេញលេញ (ចំណុចនេះអាចធ្វើឲ្យមានការមិនទទួលស្គាល់ទោសកំហុស)» អំពើរបស់បុគ្គល «មានការជាប់ពាក់ព័ន្ធនឹងបទល្មើសដែលនឹងចោទប្រកាន់ទៅលើជនត្រូវចោទ» ។ នេះមានន័យថា ខណៈពេលដែលតុលាការត្រូវតែកំណត់ថាតើជនត្រូវចោទបានមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឬក៏អត់ តុលាការត្រូវតែទាញពីអង្គហេតុដែលថាជនត្រូវចោទមិនមានបានជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងអង្គហេតុដើម្បីបកស្រាយពន្យល់ពីសកម្មភាពរបស់បុគ្គលម្នាក់ៗ ។ ទោះបីជាមានអ្នករិះគន់ពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាថា តែងតែសម្អាងទៅលើភ័ស្តុតាងសម្រាប់បញ្ជាក់ពីអំពើប្រល័យពូជសាសន៍ដើម្បីបង្ហាញពីការទទួលខុសត្រូវរបស់បុគ្គល អ្នកទាំងនេះហាក់ដូចជាមិនអើពើនឹងទំនាក់ទំនងរវាងចំណុចទាំងពីរនេះ ។ អ្នកផ្តល់អនុសាសន៍ម្នាក់បានស្នើថា ការយក «វត្តមាននៃអំពើប្រល័យពូជសាសន៍ដែលបានកើតមាននៅគ្រប់ទីកន្លែងនៅក្នុងប្រទេស» មកសន្និដ្ឋានទៅលើចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺមិនស្របច្បាប់ទេ ពីព្រោះវាអាចធ្វើឲ្យមានការសង្ស័យចំពោះការអះអាងរបស់ចុងចោទដែលថាខ្លួនមិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍» ទេ ។ ការវិភាគនេះមិនបានគិតទៅដល់ថាកត្តាជាក់លាក់មួយចំនួនបានត្រឹមតែបង្ហាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់បុគ្គលដែលស្ថិតនៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ក្នុងសង្គម ។ ជាឧទាហរណ៍ នៅក្នុងករណី កាយីហ្ស៊ីម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញភាពពាក់ព័ន្ធទៅនឹងអ្វីដែលបានរកឃើញទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាដែលមានការសម្លាប់ប្រជាជនហ៊ូទូដោយកាំបិត ។ បន្ទាប់មកមានការរកឃើញថា ក៏មានការធ្វើបែបនេះនៅ គីប៊ុយយេ ដែលជាតំបន់ដែលគ្រប់គ្រងដោយជនត្រូវចោទ ។ ចំណុចនេះអាចធ្វើឲ្យមានការរកឃើញថាមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយបុគ្គលនៅ គីប៊ុយយេ ។ ជាមួយនឹងការសន្និដ្ឋានអំពីបំណងពិរុទ្ធប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់បុគ្គល តុលាការបាននិយាយថា នៅអំឡុងពេល កាយីហ្ស៊ីម៉ា «គ្រប់គ្រងនិងដឹកនាំ» ប្រទេស អ្នកនៅក្រោមបង្គាប់របស់លោកបានសម្លាប់ជនរងគ្រោះដោយកាំបិត ដែលបណ្តាលឲ្យមានការស្លាប់រង្គាលនៃជនជាតិទុតស៊ី ។ ចំពោះករណីនេះ តុលាការបានរកឃើញថាការផ្តល់កាំបិតនៅរ៉្វាន់ដា និងគីប៊ុយយេ ជាសកម្មភាពដែលធ្វើឲ្យមានការទាញទៅរកបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់បុគ្គល ។ ប៉ុន្តែ ការដែលអ្នកនៅក្រោមបង្គាប់របស់ កាយីហ្ស៊ីម៉ា មានកាំបិតមិនអាចបញ្ជាក់ពីបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេពីព្រោះប្រជាជនរ៉្វាន់ដាភាគច្រើនសុទ្ធតែមានកាំបិតផ្ទាល់ខ្លួនស្រាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ មានការបញ្ជាក់ថាមេដឹកនាំរដ្ឋាភិបាលបានចែកចាយកាំបិតដល់ប្រជាជនដើម្បីអនុវត្តន៍ផែនការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

ស្រដៀងគ្នានេះដែរ ដើម្បីយល់ដឹងពី «បរិបទ» នៃសកម្មភាពរបស់ជនត្រូវចោទ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានលើកឡើងពីរបាយការណ៍ជាក់បន្ទុកដែលធ្វើឡើងដោយជនដែលមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយជនត្រូវចោទ ។

ការធ្វើបែបនេះមិនអាចជះឥទ្ធិពលដោយផ្ទាល់ដល់ការបង្ហាញពីបំណងពិរុទ្ធរបស់បុគ្គលទេ ។ ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានលើកឡើងពីសេចក្តីអធិប្បាយដែលផ្សព្វផ្សាយតាមរយៈវិទ្យុ សៀវភៅផ្សព្វផ្សាយព័ត៌មាននិងការប្រជុំដែលធ្វើឡើងដោយ ឡេអន ម៉ៃសេរ៉ា ដែលជាសាស្ត្រាចារ្យនិងអ្នកឃោសនាម្នាក់ដែលថាអ្នកប្រយុទ្ធ «ត្រូវតែកាត់ជើងទារកដែលកំពុងតែជោរដើម្បីកុំឲ្យទារកនោះដើរបាន» ហើយ «យើងមិនត្រូវប្រព្រឹត្តកំហុសដោយអនុញ្ញាតឲ្យក្មេងៗទុតស៊ីរត់រួចបានទេ» ។ ហើយលោកបានជំរុញឲ្យអ្នកស្តាប់ «បោះជនជាតិទុតស៊ីទៅក្នុងទន្លេដើម្បីឲ្យជនជាតិនេះចាកចេញពីប្រទេស» ។ តុលាកាបានរកឃើញសេចក្តីអធិប្បាយដែលមានការជាប់ពាក់ព័ន្ធបែបនេះដើម្បីបញ្ជាក់ថាជនត្រូវចោទក៏មានចេតនាប្រព្រឹត្តអំពីប្រល័យពូជសាសន៍ដែរ ។

លើសពីនេះទៅទៀត ការស្វែងរកដែលថាអំពើប្រល័យពូជសាសន៍តែងតែកើតមាននៅក្នុងស្ថានភាពមួយដែលបានរៀបចំអាចមានការជាប់ពាក់ព័ន្ធនឹងករណីអំពើប្រល័យពូជសាសន៍ទោះបីជាតុលាការស្វែងរកឃើញថាជនត្រូវចោទមិនបានមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក៏ដោយ ។ នេះដោយសារតែវាគឺជាការស្វែងរកមួយសម្រាប់ដាក់ឲ្យមានការទទួលខុសត្រូវមិនផ្ទាល់ទៅលើអំពើប្រល័យពូជសាសន៍ ហើយវាតែងតែមិនត្រូវការភ័ស្តុតាងដើម្បីបង្ហាញពីបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាក់លាក់ណាមួយ ។ ជាឧទារហណ៍ ករណី ក្រាទីក សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីប្រទេសយូហ្គោស្លាវីបានរកឃើញថា អង្គហេតុនៅក្នុងករណីនោះបានធ្វើឲ្យមានការសន្មតថាមានបក្សខ្លះមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ប៉ុន្តែមិនមានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ក្រាទីកមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាបុគ្គលទេ ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានរកឃើញថា ក្រាទីកបានជួយគណៈកម្មការផ្សេងឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដូច្នេះអ្នកទាំងនេះត្រូវទទួលខុសត្រូវដោយមិនផ្ទាល់ទៅលើសកម្មភាពប្រល័យពូជសាសន៍របស់ខ្លួន ។

ខ) របាយការណ៍បញ្ជាក់ពីបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់បុគ្គល

ភ័ស្តុតាងល្អបំផុតដែលអាចធ្វើឲ្យមានការទាញទៅដល់បំណងពិរុទ្ធប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់បុគ្គលគឺរបាយការណ៍ជាលាយលក្ខណ៍អក្សរឬដោយពាក្យសម្តីដែលបង្ហាញពីបំណងចង់បំផ្លាញក្រុមទទួលបានការការពារ ។ អាស្រ័យហេតុនេះនៅក្នុងករណីកំណត់ថាតើបុគ្គលមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានពិនិត្យទៅលើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ជនត្រូវចោទយ៉ាងល្អិតល្អន់ ។ ជាឧទាហរណ៍ នៅក្នុងករណី អាកាយេស៊ូ តុលាការបានរកឃើញថាសក្ខីកម្មរបស់សាក្សីដែលបញ្ជាក់ថាជនត្រូវចោទបានប្រកាសជាផ្លូវការថា «ប្រសិនបើបុរសទុតស៊ីធ្វើឲ្យនារី ហ៊ូទូ មានផ្ទៃពោះ នារី ហ៊ូទូ ត្រូវតែរំលូតកូននោះចេញ» ។ ស្រដៀងគ្នានេះដែរ នៅក្នុងករណី កាយីហ្សុម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថាជនត្រូវចោទ



បាន «ជំរុញឲ្យមានការសម្លាប់ជនជាតិទុតស៊ី» ។ ហើយបើតាមសក្ខីកម្មរបស់សាក្សី ជនត្រូវចោទមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយជំរុញឲ្យអ្នកនៅក្រោមបង្គាប់ធ្វើការជាច្រើនមុនពេលមានការសម្លាប់រង្គាលប្រជាជនទុតស៊ី ។ ឧទាហរណ៍មួយទៀត នៅក្នុងករណី មូហ៊ីម៉ាណា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថាជនត្រូវចោទបានធ្លាប់បានអះអាងថា «ខ្លួនធ្លាប់បានរៀបចំកិច្ចប្រជុំមួយដើម្បីជំរុញឲ្យប្រជាជន ហ៊ូទូសម្លាប់ប្រជាជន ទុតស៊ី» ។ ភ័ស្តុតាងនៃការសម្លាប់រង្គាលដែលកើតឡើងក្រោយពេលប្រជុំនៅផ្ទះរបស់ជនត្រូវចោទអាចបង្ហាញពីបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

ជាងនេះទៅទៀត ដោយសារតែការទាញទៅដល់បំណងប្រល័យពូជសាសន៍មានលក្ខណៈងាយស្រួលពីព្រោះចុងចោទធ្លាប់ធ្វើសេចក្តីថ្លែងការណ៍ដាក់បន្ទុកលើខ្លួនឯង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាតែងតែសម្អាងទៅលើសេចក្តីថ្លែងការណ៍ទាំងនេះដើម្បីបង្ហាញពីបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ពេលខ្លះភ័ស្តុតាងដែលមានជាប់ពាក់ព័ន្ធនឹងសំណុំរឿងសុទ្ធតែមានសារសំខាន់ ។ ជាឧទាហរណ៍ដូចជាករណី កាយីហ្ស៊ីម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានលើកឡើងពី «ចម្រៀងដែលច្រៀងអំពីការសម្លាប់ប្រជាជនទុតស៊ី» ដោយចុងចោទដែលត្រូវទទួលខុសត្រូវ ។ ស្រដៀងគ្នានេះដែរ នៅក្នុងដីកាចាប់ខ្លួន អូម៉ា អាល-បាហ្សៀ ប្រធានាធិបតីនៃប្រទេសស៊ូដង់ ព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងពីសេចក្តីថ្លែងការណ៍ដែលនិយាយដោយអ្នកនៅក្រោមបញ្ជាការរបស់លោក ដែលមានដូចជា «អំណាចរបស់ អាល បាហ្សៀ ជារបស់អារ៉ាប់ ហើយយើងនឹងសម្លាប់អ្នករហូតដល់ទីបញ្ចប់» «យើងនឹងសម្លាប់ពួកស្បែកខ្មៅទាំងអស់» ហើយ «យើងនៅទីនេះដើម្បីកម្ចាត់ពួកស្បែកខ្មៅ» ។



អ្នកទស្សនាការតាំងពិព័រណ៍ករណី០០២ នៅទួលស្លែង

ប៉ុន្តែនៅក្នុងករណីខ្លះ ភ័ស្តុតាងដែលជាប់ពាក់ព័ន្ធមិនអាចបញ្ជាក់ដើម្បីទាញថាជនត្រូវចោទបានគាំទ្រនឹងសេចក្តីថ្លែងការណ៍របស់អ្នកដទៃនោះទេ ។ ជាឧទាហរណ៍ នៅក្នុងករណីស្វែងរកថា ហ្សង់ ប៉ូល អាកាយេស៊ូ មានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានលើកឡើងពីសក្ខីកម្មរបស់សាក្សីពីររូបដែលអះអាងថាជនត្រូវចោទធ្លាប់ «បានដឹកនាំកិច្ចប្រជុំជាសាធារណៈមួយ» ដែលនៅក្នុងកិច្ចប្រជុំនោះមានអ្នកខ្លះបាននិយាយថា «ត្រូវតែសម្លាប់ទុតស៊ីដើម្បីកុំឲ្យក្មេង ហ៊ូទូ ស្គាល់ថា ទុតស៊ី មានរូបរាងដូចម្តេច» ហើយអ្នកទាំងនោះបាននិយាយទៀតថា «យើងនឹងមានសេចក្តីសុខនៅពេលដែលគ្មានទុតស៊ីនៅក្នុងប្រទេសរ៉្វាន់ដា» ។

## ១) សេចក្តីថ្លែងការណ៍ដែលគ្មានប្រសិទ្ធភាព

ខណៈពេលដែលសេចក្តីថ្លែងការណ៍ដែលជំរុញឲ្យអ្នកស្តាប់ចូលរួមនៅក្នុងសកម្មភាពប្រល័យពូជសាសន៍អាចបង្កើតជាអំពើពិរុទ្ធប្រល័យពូជសាសន៍ (ប្រសិនបើវាស្មើនឹង «ការញុះញង់) តុលាការត្រូវតែទាញថាអ្នកទាំងនោះមានបំណងពិរុទ្ធប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ឧទាហរណ៍ យើងមិនអាចសន្និដ្ឋានថាសេចក្តីថ្លែងការណ៍ដែលថា «ខ្ញុំមានបំណងសម្លាប់ទុតស៊ីទាំងអស់» ជាបំណងប្រល័យពូជសាសន៍ដោយមិនស្វែងរកថាអ្នកដែលធ្វើ

សេចក្តីថ្លែងការណ៍នោះពិតជាមានបំណងដូចអ្វីដែលខ្លួនបាននិយាយនោះទេមានន័យថា សេចក្តីថ្លែងការណ៍មិនមែនតែធ្វើឡើងដើម្បីជំរុញឬញុះញង់ឲ្យធ្វើបែបនោះទេ ។ អាស្រ័យហេតុនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីប្រទេសយូហ្គោស្លាវីបានអះអាងនៅក្នុងករណី ក្រាជីសនីក ថា «នៅពេលពិនិត្យទៅលើពាក្យសម្តី និងសេចក្តីថ្លែងការណ៍ដើម្បីស្វែងរកភ័ស្តុតាងបញ្ជាក់ពីបំណងប្រល័យពូជសាសន៍ ពាក្យសម្តីត្រូវតែស្របទៅតាមបរិបទ» ។ ដូច្នេះ នៅក្នុងការកំណត់ទម្ងន់ទៅលើអ្វីដែលបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍ តុលាការញែកឲ្យច្បាស់ពីសាច់រឿងនិងបរិបទ ។ ជាឧទាហរណ៍ នៅក្នុងករណី ណាតាជីរេវ៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានរកឃើញថា សេចក្តីថ្លែងការណ៍របស់អ្នកនយោបាយ ហ៊ូទូ នៅក្នុងកិច្ចប្រជុំសាធារណៈនៅអំឡុងពេលប្រល័យពូជសាសន៍ «ដែលបានសួរទៅប្រជាជនថាតើអ្នកទាំងនោះសុខចិត្តឲ្យសត្វកន្លាតរត់ទៅមកនៅក្នុងប្រទេសដែរឬទេ» និង «ជំរុញឲ្យប្រជាជនកាន់អាវុធដើម្បីបញ្ជូនអ្នកទាំងនោះទៅកន្លែងដើមវិញ» មិនមានភាពច្បាស់លាស់ក្នុងការយកមកបង្ហាញពីបំណងកម្ទេចទុតស៊ីជាក្រុមដែលអាចធ្វើឲ្យយើងទាញទៅដល់បំណងប្រល័យពូជសាសន៍នោះទេ ។ អាស្រ័យហេតុនេះ តុលាការបានកំណត់ថា ការចោទប្រកាន់ «មិនមានសម្អាងច្បាស់លាស់ដើម្បីបញ្ជាក់ថាកិច្ចប្រជុំនោះធ្វើឡើងដើម្បីដឹកនាំ រៀបចំ និងជំរុញឲ្យមានអំពើប្រល័យពូជសាសន៍» ។ មានន័យថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសរ៉្វាន់ដាមិនបានត្រួតពិនិត្យទៅលើសេចក្តីថ្លែងការណ៍តែម្ខាងនោះទេ» ។ នៅពេលជួបប្រទះនឹងសេចក្តីថ្លែងការណ៍ដែលមានន័យមិនច្បាស់លាស់ដែលអាចទាញទៅដល់បំណងពិរុទ្ធប្រល័យពូជសាសន៍ ប៉ុន្តែមិនអាចបង្ហាញពីចំណុចមួយចំនួនដូចជាការស្អប់ពូជសាសន៍ និងបំណងដើម្បីធ្វើឲ្យក្រុមយោធាទទួលបានជ័យជម្នះ តុលាការបានត្រួតពិនិត្យទៅលើស្ថានភាពនៅជុំវិញដើម្បីបង្ហាញពីការពិត ។

### ៧) ការវែកញែកៈ សេចក្តីថ្លែងការណ៍ប្រមាថមើលងាយ

តុលាការអន្តរជាតិមិនបានយល់ស្របនឹង «ការប្រើប្រាស់ភាសាប្រមាថមើលងាយទៅលើក្រុមដែលទទួលបានការពារ» គឺជាបំណងប្រល័យពូជសាសន៍ ។ ឧទាហរណ៍ នៅក្នុងករណី កាយីហ្សីម៉ា ការប្រើប្រាស់ភាសាមិនសមរម្យរបស់ចុងចោទនៅពេលនិយាយពីទុតស៊ីនិងស្ថានភាពជាក់ស្តែងមួយចំនួនដែលតុលាការប្រើប្រាស់ដើម្បីបង្ហាញពីបំណងប្រល័យពូជសាសន៍ បានធ្វើឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដារកឃើញថាជនត្រូវចោទមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ តុលាការបានឲ្យទម្ងន់ទៅលើអង្គហេតុដែលថាជនត្រូវចោទបានហៅ ទុតស៊ីថាជា «សំរាម», «ធូលី», «សត្វស្កែ», «សត្វកន្លាត» ។ ស្រដៀងគ្នានេះដែរ នៅក្នុងដីកាចាប់ខ្លួន អាលបាសៀ ព្រះរាជអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិបានអះអាងថាការប្រើប្រាស់ភាសាមិនប្រមាថមើលងាយទៅលើក្រុមជាក់លាក់អាចធ្វើឲ្យតុលាការទាញបានថាជនត្រូវចោទមានបំណងប្រល័យពូជសាសន៍ ។

ប៉ុន្តែ តុលាការមិនបានពឹងផ្អែកទាំងស្រុងទៅលើភាសាប្រមាថមើលងាយជាទូទៅដើម្បីបង្ហាញពីបំណងប្រល័យពូជសាសន៍ទេ ។ ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងករណី ណាតាជីរេវ៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាមិនបានរកឃើញថាជនត្រូវចោទបានហៅ ទុតស៊ី ជាផ្លូវការថាជា «សត្វកន្លាត» ដើម្បីឲ្យទម្ងន់ខ្លាំងក្នុងការវាយតម្លៃទៅលើបំណងពិរុទ្ធ ។ ផ្ទុយពីចុងចោទនៅក្នុងករណី កាយីហ្សីម៉ា សេចក្តីថ្លែងការណ៍ប្រមាថមើលងាយរបស់ជនត្រូវចោទគឺជាភ័ស្តុតាងមួយសម្រាប់បង្ហាញពីបំណងសម្លាប់ទុតស៊ីជាក្រុម ។ ជាងនេះទៅទៀត នៅក្នុងករណី ក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសម្រេចថា «មិនអាចដាក់ស្ថានទម្ងន់ទៅលើការប្រើប្រាស់ភាសាប្រមាថមើលងាយទៅលើមូស្លីមនៅប៊ូស្នៀទេ ដើម្បីបង្កើតជាបំណងប្រល័យពូជសាសន៍បានទេ ។ តុលាការបានអះអាងថា «នេះគឺជាភាសាធម្មតាដែលប្រើប្រាស់នៅក្នុងជួរយោធានៅអំឡុងសង្គ្រាម» ។ ទោះបីជាយ៉ាងក៏ដោយ វាមិនមានភាពច្បាស់លាស់ថាតើតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនឹងយកហេតុផលនេះចេញពីបរិបទយោធាដើម្បីចោទប្រកាន់ទៅលើមេដឹកនាំប្រជាជនស៊ីវិល និងបុគ្គលទេ ។

***(នៅមានត)***

**វ៉ាវ៉ិអ៊ិន អ៊ុំ.ផាក**

# សេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលៈ ព្រះរាជអាជ្ញា និង ឌុច

## ១) *សេចក្តីផ្តើម*

*បន្ទាប់ពីសវនាការកាត់ទោស ឌុច អស់រយៈពេល៧៣ថ្ងៃមក អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបើកសវនាការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើករណី កាំង ហ្គេកអ៊ាវ ហៅ (ឌុច) ជាអតីតមេគុកទួលស្លែង(ស-២១) ។ សវនាការបានធ្វើឲ្យមានការកន្ត្រាក់អារម្មណ៍ មានឥទ្ធិពល ហើយពេលខ្លះពិបាកនឹងយល់ (ដំណើររឿងលម្អិតរបស់ដំណើរការសវនាការនេះដែលអាចរកបាននៅលើគេហទំព័រ www.cambodiatribunal.org) ។ សាលសវនាការមានសាធារណជនតំណាងអង្គការក្រៅរដ្ឋាភិបាល ស្ថានទូតបរទេសនានា ព្រះសង្ឃគ្រងដោយស្បង់ចីពរពណ៌លឿង និងដូនជីក្នុងសម្លៀកបំពាក់ពណ៌ស និស្សិតក្នុងឯកសណ្ឋានសាលាប្រធានសន្តិសុខនៃតុលាការពិសេសរបស់ប្រទេសលីបង់ និងអ្នកសារព័ត៌មានជាច្រើនទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀតបានបញ្ជូនអ្នកស្រុកជាច្រើនរយនាក់តាមរថយន្តក្រុងមកពីគ្រប់ទិសទីទាំងអស់នូវទាំងប្រទេស ទៅអង្កេតមើលសវនាការនេះ ។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាមានពេលប្រាំម៉ោងក្នុងមួយក្រុមដើម្បីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល ។ ក្រុមមេធាវីការពារក្តីនិងសមាជិករបស់ខ្លួនមានពេលប្រាំពីរម៉ោងកន្លះ ។ រីឯបីម៉ោងទៀតត្រូវបានត្រៀមទុកសម្រាប់ធ្វើការជំទាស់ ។*

*ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលជាសកម្មភាពចុងក្រោយបង្អស់របស់ភាគីនីមួយៗក្នុងការបញ្ចុះបញ្ចូលចៅក្រម ។ ភាគីនីមួយៗមានតួនាទីភ្ជាប់រឿងហេតុជាមួយនឹងច្បាប់តាមមធ្យោបាយមួយដែលនាំតុលាការ (ករណីនេះគឺជាចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ) ទៅដល់ការចេញនូវសាលក្រមមួយនៅទីបញ្ចប់ ។ ការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយក៏ជាវេលាមួយដើម្បីលើកឡើងពីចំណុចខ្សោយរបស់គូបដិបក្ខ បង្ហាញភ័ស្តុតាង ឬការត្រិះរិះរកហេតុផលដើម្បីធ្វើការវាយប្រហារការជឿជាក់របស់សាក្សីនៃគូបដិបក្ខនិងស្វែងរកដំណោះស្រាយពីភាពមិនស៊ីគ្នានៃភ័ស្តុតាង ។ បន្ថែមពីលើការបង្ហាញភ័ស្តុតាងដោយផ្ទាល់ និងមិនផ្ទាល់ សេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលត្រូវតែពញ្ញាក់ស្មារតីរបស់ចៅក្រមដោយផ្អែកទៅលើបទពិសោធន៍ជីវិត សុភវិនិច្ឆ័យ រួមនឹងទស្សនៈសកល ។ ជនជាប់ចោទក៏ត្រូវបញ្ជាក់ថា សហព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវក្នុងការបង្ហាញភ័ស្តុតាង ការលើកឧទាហរណ៍នៅក្នុងកំណត់ហេតុ ដែលសហព្រះរាជអាជ្ញាមិនបានលើកឡើងនូវបញ្ហានេះកន្លងមក ។ វិធីសាស្ត្រនិងការលើកដាក់របស់ភាគីនីមួយនៅពេលសន្និដ្ឋានបញ្ចប់ការដេញដោលនឹងត្រូវពឹងផ្អែកទៅលើទ្រឹស្តីនិងសភាពរបស់សំណុំរឿងនីមួយៗនិងមធ្យោបាយដែលភ័ស្តុតាងត្រូវបានដាក់បង្ហាញនៅក្នុងពេលសវនាការ ។*

## ២) *ដើមបណ្តឹងរដ្ឋប្បវេណី*

*ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩០នាក់ (មួយចំនួនបានផ្លាស់ប្តូរគ្នាអង្គុយនៅលើសាលសវនាការ ឯមួយចំនួនទៀតអង្គុយនៅជួរខាងមុខនៃសាលសម្រាប់សាធារណជន) ត្រូវបានអញ្ជើញឲ្យឡើងធ្វើសេចក្តីសន្និដ្ឋានមុនគេ ។ ជនរងគ្រោះត្រូវបានតំណាងដោយក្រុមមេធាវីចំនួន៤ក្រុម ដែលក្រុមនីមួយៗមានរយៈពេលស្មើគ្នាដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ។ ការីម ខាន់ ជាសហមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣៧នាក់បានចាប់ផ្តើមដោយបញ្ជាក់ពីភាពថ្មីស្រឡាងនៃសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃសវនាការនិងទទួលស្គាល់ពីឧបសគ្គមួយចំនួនដែលបានជួបប្រទះកន្លងមកក្នុងការសម្របសម្រួលការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការសវនាការ ។ បើតាមការប៉ាន់ស្មានទៅលើវិសមភាពនៃការចោទប្រកាន់ ការីម ខាន់ បានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានធ្វើការងារជាន់គ្នាលើការងាររបស់សហព្រះរាជអាជ្ញាទេ ហើយគាត់បាន*

លើកឧទាហរណ៍មួយចំនួនក្នុងអំឡុងនៃសវនាការពេលដែលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីខុសគ្នាពីជំហររបស់សហព្រះរាជអាជ្ញា (ឧទាហរណ៍ដូចជាក្រុមរបស់គាត់បានធ្វើការជំទាស់ទៅនឹងការបញ្ចូលការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មរួម) ។ គាត់បានសង្កត់ធ្ងន់ទៅលើទស្សនៈវិស័យដ៏ប្លែកមួយនិងការផ្តល់ជាវិភាគទានរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីចំពោះដំណើរការសវនាការ ដូចជាការផ្តល់នូវកសិណសាក្សីអំពីផលប៉ះពាល់នៃអំពើរបស់ជនចុងចោទទៅលើជនរងគ្រោះដែលរងគ្រោះដោយផ្ទាល់និងដោយប្រយោលព្រមទាំងបង្ហាញនូវការពិតដ៏ពេញលេញមួយចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅសម័យនោះ ។ លោក ការីម ខាន់ បានបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួនដោយធ្វើការរិះគន់ភាពប៉ិនប្រសព្វរបស់សាលាក្តីចំពោះកង្វះខាតក្នុងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុទៅដល់ក្រុមមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

សហមេធាវីកម្ពុជារបស់គាត់គឺកញ្ញា ទី ស្រ៊ីណា ជាអកុសលប្រើប្រាស់ពេលវេលាដែលនៅសេសសល់ដើម្បីរំឭកឡើងវិញពីប្រវត្តិរូបរបស់កូនក្តីនីមួយៗដែលព័ត៌មានទាំងអស់នេះភាគច្រើនមាននៅក្នុងកំណត់ហេតុរួចអស់ទៅហើយ ។ បន្ទាប់ពីធ្វើការកត់សម្គាល់រួចមក ទី ស្រ៊ីណា បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល ហើយប្រគល់នាទីទៅលោក ការីម ខាន់ ម្តងទៀត ។ ក្រោយពីបានធ្វើការសង្ខេបទៅលើបញ្ហាទាមទារសំណង លោក ការីម ខាន់ (ស្តាប់ទៅដូចនឹងអតីតព្រះរាជអាជ្ញា) បានលើកឡើងថាពាក្យអះអាងថាស្តាយក្រោយរបស់ ឌុច មានសភាពមិនច្បាស់លាស់និងមិនស្មោះត្រង់ ។ លោក ការីម ខាន់ បានធ្វើការជំទាស់ទៅនឹងសម្បថរបស់ ឌុច នៅសវនាការដែលថាគាត់គ្រាន់តែធ្វើទៅតាមបញ្ជារបស់ថ្នាក់លើនៅក្រោមការគាបសង្កត់ប៉ុណ្ណោះ ។ ផ្ទុយទៅវិញ លោក ការីម ខាន់ បានលើកឡើងថា ភ័ស្តុតាងជាច្រើនបានបង្ហាញថា ឌុច មានភាពស្មោះត្រង់ទៅនឹងអង្គការខ្មែរក្រហម ឌុច ខំប្រឹងប្រែងដើម្បីទាញទំនុកចិត្តពីអង្គការថ្នាក់លើហើយគាត់បានប្រើប្រាស់ភាពស្ម័យឯករាជ្យនេះដើម្បីបង្កើនជាងសម្រាលទុក្ខវេទនារបស់អ្នកជាប់ឃុំឃាំង ដោយបញ្ជាក់ថា «នេះមិនមែនដូចករណីស្វ្រាញជ័រ» ទេ ។ លោក ការីម ខាន់ បញ្ជាក់ពីការខ្វះខាតឯកសារពីគណៈអចិន្ត្រៃយ៍ទាក់ទងនឹងប្រភេទនិងភាពធ្ងន់ធ្ងរនៃការធ្វើទារុណកម្មដែលបញ្ជាក់ថា ឌុច បានសម្រេចចិត្តដោយខ្លួនឯងក្នុងការបង្កើតនិងអនុវត្តអំពើទារុណកម្មដ៏សាហាវនៅទួលស្លែង ។ ជាងនេះទៅទៀត លោក ការីម ខាន់ បានច្បិចយកផលប៉ះពាល់ធ្ងន់ធ្ងរពីការងាររបស់ ឌុច ដោយសម្អាងថា ការបកអាក្រាតពីចារកិច្ច សេ.អ៊ី.អា ឬកាហ្សេបេ តាមពិតធ្វើឲ្យខ្មែរក្រហមកាន់តែមានភ័យខ្លាចដែលនាំទៅដល់ការរំលោភនិងបោសសម្អាតនៅទូទាំងប្រទេស ដោយខ្មែរក្រហមយកលេសថាខ្លួនគ្រាន់តែបោសសម្អាតខ្មាំងបដិវត្តន៍ ។ លោក ការីម ខាន់ បានលើកឡើងពីការលំបាករបស់ ឌុច នៅចុងបញ្ចប់នៃសវនាការដោយឈរនៅលើជំហររបស់ក្រុមបណ្តឹងរដ្ឋប្បវេណី ជាពិសេសបុគ្គលម្នាក់ៗដែលមិនអាចផ្តល់ភ័ស្តុតាងជាឯកសារអំពីទំនាក់ទំនងសាច់ឈាមជាមួយបុគ្គលណាម្នាក់ដែលស្លាប់នៅមន្ទីរស-២១ ។ បើទោះជាតុលាការបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីតាំងពីដំបូង ក៏ចៅក្រមបានទទួលយកការជំទាស់ជាបន្តបន្ទាប់របស់ ឌុច ទុកជាការព្រមានចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ដែលមានគ្នា១៧នាក់ ត្រូវបានតំណាងដោយ ស៊ីលកេ ស្ទុដហ្សិនស្គី មកពីប្រទេសអាល្លឺម៉ង់ ។ ការបង្ហាញរបស់ ស្ទុដហ្សិនស្គី ផ្តោតសំខាន់ទៅលើគោលដៅរបស់កូនក្តី ពោលគឺចង់ស្វែងយល់ពីមូលហេតុដែលពួកគាត់ឬសាច់ញាតិរបស់ពួកគាត់ត្រូវខ្មែរក្រហមចាប់និងធ្វើបាបនៅគុកទួលស្លែង ។ បន្ទាប់មក សហមេធាវីកម្ពុជា លោក គង់ ពិសី បានធ្វើការបង្ហាញពីភ័ស្តុតាងទាក់ទងនឹងការរំលោភផ្លូវភេទដែលបានកើតមាននៅទួលស្លែង ដែលបញ្ហានេះមិនមែនជាផ្នែកមួយនៃដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនោះទេ ។ សហមេធាវីទាំងពីរបានធ្វើការរិះគន់សហព្រះរាជអាជ្ញាដោយមិនបានផ្តោតទៅលើឧក្រិដ្ឋកម្មនៃការរំលោភផ្លូវភេទនៅទួលស្លែង ។ លោក គង់ ពិសី បានធ្វើការរិះគន់ចំពោះការការពារខ្លួនរបស់ ឌុច ដោយលើកហេតុផលថា ឌុច ជាពេជ្ឈឃាតដោយគ្មានការបង្ខិតបង្ខំ ហើយ ឌុច មិនបានរួមចំណែកផ្តល់ការពិតទៅឲ្យសវនាការដូចដែលបានសន្យានោះទេ ។ នៅពេលមួយ នោះ លោកស្រី ស្ទុដហ្សិនស្គី បានចាប់ផ្តើមសម្តែងការខកចិត្តផងដែរក្នុងការដែលជនរងគ្រោះមានមិនបានទទួលការស្វាគមន៍ពីតុលាការ ព្រោះចៅក្រមមិនបានទទួលស្គាល់ការឈឺចាប់

របស់ជនរងគ្រោះ ដោយសុំឲ្យជនរងគ្រោះបង្ហាញពីស្លាកស្នាមរបួសនៅក្នុងសវនាការដោយចំហ និងដោយមិនខ្វល់អ្វីទាំងអស់ ។ ក្រោយពីនោះ ចៅក្រមតែងតែបន្ទាក់មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងមិនបានអរគុណជនរងគ្រោះសម្រាប់ការឡើងមកបំភ្លឺនៅសវនាការ ។ សេចក្តីសម្អាងទាំងអស់នេះបង្កឲ្យមានការឆ្លើយតបពីអង្គជំនុំជម្រះសាលាដំបូងដែលបានធ្វើការរំឭកទៅដល់សហមេធាវីថាវិធានពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងមិនមែនជាប្រធានបទដ៏សមស្របនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលនោះទេ ។ សហមេធាវីបានបន្តពេលពិភាក្សាទៅលើប្រធានបទការទាមទារសំណងដោយស្នើសុំថា ជនជាប់ចោទអាចសរសេរជីវប្រវត្តិផ្ទាល់ខ្លួន ហើយផ្តល់ថវិកាដែលបានមកពីការលក់សៀវភៅនេះទៅដល់ជនរងគ្រោះ ។ សហមេធាវីបានស្នើបន្ថែមទៀតថា ចំណែកខ្លះដែលបានមកពីលក់សំបុត្រនៅសារមន្ទីរទួលស្លែងគួរតែបានទៅលើជនរងគ្រោះ ហើយ ឌុច គួរតែស្នើសុំទៅដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការសុំទោសជាផ្លូវការ ។

តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី រួមបញ្ចូលទាំងមេធាវីជនជាតិបារាំងឈ្មោះ ហ្វីលីព កាណុន និង ម៉ារតាំង ចាកឃ្វីន ពិពណ៌នាកូនក្តីទាំង២៨របស់គាត់ជា «អ្នកជួយឲ្យមានយុត្តិធម៌» ។ នៅក្នុងការកត់សម្គាល់របស់គាត់ សហមេធាវីបានផ្តោតដោយផ្ទាល់ចំពោះ ឌុច ជាជាងចៅក្រម ។ មេធាវីបានហៅ ឌុច ឲ្យមើលទៅជនរងគ្រោះនិងសួរសំណួរទៅ ឌុច ថាតើបុរសម្នាក់ដែលមើលទៅគួរឲ្យគោរពបែរជាក្លាយជាមនុស្សដ៏គួរឲ្យខ្លាចបានយ៉ាងដូចម្តេច ។ កាណុន ក៏ទទួលស្គាល់ដែរថាក្រុមដើមបណ្តឹងរដ្ឋប្បវេណីកន្លងមកឥតមានរបៀបរៀបរយនៅក្នុងពេលសវនាការ ប៉ុន្តែគាត់បានចាត់ទុករឿងនេះថាជាកំហុសមួយដែលបានរិះគន់អ្នកដែលតុលាការបានបង្កើតឡើង ហើយគាត់ក៏បានក្រើនរំឭកពីការដែលតុលាការមិនឲ្យជនរងគ្រោះបាននិយាយដូចជា «រូបបដិមាដែលមិនចេះនិយាយ» ។ មេធាវីសម្អាងទៅលើការផ្តល់កសិណសាក្សីនិងលើសៀវភៅរបស់ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលជាអ្នកជាតិពិន្ទុវិទូម្នាក់បានផ្តល់កសិណសាក្សីនៅឯសវនាការ ។ ប៊ីហ្សូ ត្រូវបានចាប់ខ្លួនដោយខ្មែរក្រហមនៅឆ្នាំ១៩៧១ ។ គាត់ក៏ធ្លាប់ជាប់មន្ទីរឃុំឃាំងរបស់ ឌុច ដែល ប៊ីហ្សូ ពិពណ៌នាថា ឌុច ជាមនុស្សមាន «ឧត្តមគតិ ក្លៀវក្លា និងបរិសុទ្ធ» ។ ប៊ីហ្សូ បានរៀបរាប់ពីបទពិសោធន៍របស់ខ្លួនយ៉ាងកំសត់នៅក្នុងសៀវភៅដ៏គួរឲ្យចាប់អារម្មណ៍ និងពេលខ្លះទៀតគួរឲ្យរន្ធត់ (The Gate) ។ លោក កាណុន ក៏បានរិះគន់ ឌុច ដែលសូត្រកំណាព្យរបស់លោក អាល់ហ្វ្រេត ដឺ វីគនី ដែលមានចំណងជើងថា «ការស្លាប់របស់ឆ្កែចចក» ដោយប្រៀបធៀបខ្លួនឯងទៅនឹងឆ្កែចចក ដែលទទួលយកនូវភាពស្ងៀមស្ងាត់ពេលកំពុងបំពេញការងារដ៏លំបាក ។ លោក ចាកឃ្វីន បានសង្កត់ធ្ងន់ថា ជនដៃដល់ខ្មែរក្រហមមិនមានជំងឺផ្លូវចិត្តនោះទេ ប៉ុន្តែអ្នកទាំងអស់នោះមានជំនាញក្នុងការធ្វើពុតជាឈឺ ។

សហមេធាវីបានអះអាងថា អ.វ.ត.ក ធ្លាប់បានផ្តល់ឲ្យជនរងគ្រោះនូវសំណងដ៏មានតម្លៃបំផុត គឺសិទ្ធិក្នុងការចូលរួមនិងសិទ្ធិក្នុងការមានវត្តមាននៅតុលាការ និងឱកាសដើម្បីមានសាមគ្គីភាព ។ ការអាណិតអាសូរ ការយល់ចិត្ត និងសេចក្តីករុណា មិនគ្រប់គ្រាន់នោះទេ ។ ពួកគាត់ថែមទាំងចង់ឲ្យមានការបង្កើតនូវមូលនិធិស្ម័គ្រចិត្តមួយដើម្បីជនរងគ្រោះ ។ សមាជិកទីបីរបស់ក្រុមគាត់មេធាវីកម្ពុជា ឈ្មោះ ម៉ុច សុវណ្ណារី បានស្នើសុំឲ្យមានជម្រើសសំណងជានិមិត្តរូបថែមទៀតដូចជា ដាក់តាំងបញ្ជីឈ្មោះជនរងគ្រោះនៅគុកទួលស្លែងថែរក្សារូបភាពឧក្រិដ្ឋកម្មផ្សេងៗឯកសារនិងរណ្តៅសាកសព ព្រមទាំងសាងសង់កន្លែងសម្រាប់ធ្វើការស្មឹងស្មាធិ៍រំឭកដល់ជនរងគ្រោះនៅទូទាំងប្រទេស ។ សុវណ្ណារី សង្កត់ធ្ងន់ទៅលើតម្រូវការក្នុងការជួយជនរងគ្រោះក្នុងការស្តារផ្នែកនិតិសម្បទាឡើងវិញ តាមរយៈការព្យាបាល ។ ដូចគ្នាទៅនឹងក្រុមផ្សេងៗដែរ សំណងដែលបានធ្វើការស្នើសុំភាគច្រើនមិនបានពាក់ព័ន្ធទៅនឹងជនចុងចោទឬក៏ទ្រព្យសម្បត្តិរបស់គាត់ទេ ផ្ទុយទៅវិញគឺទាមទារឲ្យមានការពាក់ព័ន្ធពីរដ្ឋាភិបាល ដែលហួសពីអ្វីដែល អ.វ.ត.ក អាចបង្គាប់បាន ។

មេធាវីក្រុមទី៤តំណាងឲ្យជនរងគ្រោះ១០នាក់ ។ ហុង គឹមសួន បានចំណាយពេលជាច្រើន ដើម្បីរៀបរាប់ពីរឿងរ៉ាវលម្អិតរបស់កូនក្តីគាត់ ។ ទោះបីជាយ៉ាងនេះក៏ដោយ យើងមិនដឹងច្បាស់ថាតើនេះជាមធ្យោបាយមួយព្យាយាមរំឭកទៅដល់ការចងចាំរបស់កូនក្តីគាត់ម្នាក់ៗ ឬក៏គ្រាន់តែជាឧទាហរណ៍មួយបង្ហាញការគ្រប់គ្រងពេលវេលាមិនបានល្អ ។ សហមេធាវីបារាំង ព្យែ

អូលីវៀ ស៊ា អះអាងថា កូនក្តីរបស់គាត់អាចលើកលែងទោសឲ្យ ឌុច បានលុះត្រាតែពួកគាត់បានទទួលនូវការសារភាពទោសកំហុសដ៏ស្មោះត្រង់និងពេញលេញដែល ឌុច មិនបានធ្វើកន្លងមក ។ អូលីវៀ ស៊ា បានរំឭកតុលាការពីការធ្វើកសិណសាក្សីរបស់អ្នកជំនាញចិត្តសាស្ត្រដែលបានធ្វើការពិនិត្យ ឌុច ហើយរកឃើញថា ឌុច គាំទ្រនូវទ្រឹស្តីបត់បែនដើម្បីរស់ ហើយគាត់បង្ហាញពីការយល់ចិត្តតិចតួចបំផុត និងមិនមានសមត្ថភាពយល់ពីការឈឺចាប់របស់អ្នកដទៃ ។ អូលីវៀ ស៊ា បានចោទប្រកាន់ ឌុច ពីរឿងដែល ឌុច ក្តោបក្តាប់ពេលវេលានៅក្នុងពេលសវនាការនិងបានធ្វើការចោទប្រកាន់តុលាការដោយប្រយោលថាបានចូលដៃជាមួយ ឌុច កម្រិតការចូលរួមរបស់ជនរងគ្រោះ ។

### ៣) សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញា មានព្រះរាជអាជ្ញា វីលៀម ស្មីត ជាជនជាតិអង់គ្លេស និងលោកស្រី ជា លាង ជាជនជាតិកម្ពុជាបានប្រគល់នូវដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនៃដំណើរការនីតិវិធីដែលដីកានោះដកចេញពីការអង្កេតដែលបានបកប្រែយ៉ាងច្បាស់លាស់ជាមុន ។ អ្នកទាំងពីរបានសង្កត់ធ្ងន់ទៅលើតួនាទីរបស់ខ្លួននៅក្នុងតុលាការគឺដើម្បីបញ្ជាក់ពីការចោទប្រកាន់របស់ខ្លួនភ្ជាប់នឹងភស្តុតាងនៅក្នុងឯកសារដោយយោងទៅលើបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ អ្នកទាំងពីរបានតវ៉ាទាក់ទងនឹងមូលដ្ឋាននៃយុត្តាធិការរបស់អង្គជំនុំជម្រះ ដោយពិនិត្យមើលទៅលើការដាក់បន្ទុកប្រឆាំងនឹង ឌុច ការលើកយកភស្តុតាងដែលគាំទ្រដល់ការរាប់បញ្ចូលប្រឆាំងនឹង ឌុច ហើយបិទការពិភាក្សាទាក់ទងនឹងកត្តាដែលមានទំនាក់ទំនងទៅដល់ការកាត់ទោស ។

លោកស្រី ជា លាង បានសង្កត់ធ្ងន់ថា ឌុច អាចនឹងត្រូវចាត់ទុកជាមេដឹកនាំជាន់ខ្ពស់ម្នាក់ ទោះបីជាគាត់មិនមែនជាសមាជិកនៅក្នុងគណៈកម្មការអចិន្ត្រៃយ៍របស់ខ្មែរក្រហម ហើយមិនមានតួនាទីក្នុងការបង្កើតគោលនយោបាយក៏ដោយ ប៉ុន្តែគាត់ដូចជាមនុស្សម្នាក់ដែល «ទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកស្រី ជា លាង បានទទួលស្គាល់នូវការតវ៉ារបស់ ឌុច ដែលលើកឡើងថា គាត់គឺជាអ្នករងកំហុសឲ្យអ្នកឯទៀតដែលប្រឈមមុខនឹងការកាត់ទោសនៅពេលដែលមេគុកផ្សេងៗទៀតមិនត្រូវបានទទួលការកាត់ទោស ហើយប្រហែលជានឹងមិនប្រឈមមុខនៅក្នុងតុលាការទេ ។ ឆ្លើយតបទៅនឹងការតវ៉ានេះ លោកស្រី ជា លាង បានសង្កត់ធ្ងន់ថា មន្ទីរស-២១ គឺដូចជាកន្លែងសម្លាប់ផ្តាច់ពូជរបស់ខ្មែរក្រហមដ៏កំពូលបំផុត ។ ឌុច មានសិទ្ធិចូលរួមជាពិសេសហើយមានឥទ្ធិពលទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ។ លោកស្រី ជា លាង បានបញ្ជាក់ថា គុករបស់ ឌុច គួរតែត្រូវបានចាត់ទុកជាឋានមរណៈពីព្រោះគ្មាននរណាម្នាក់អាចមានឱកាសនឹងត្រូវបានដោះលែង ហើយបានចាប់បញ្ជូនអ្នកទោសដែលមានមានឋានៈខ្ពស់នៅពាសពេញផ្ទៃប្រទេសដោយរួមទាំងការបោសសម្អាតកម្មាភិបាលខ្មែរក្រហមទៀតផង ។ ការវិភាគទៅលើចម្លើយសារភាពទាំងមូលរបស់ ឌុច បានធ្វើឲ្យមានភាពងាយស្រួលសម្រាប់ការកាត់ទោសផ្នែកនយោបាយទៅលើប្រពន្ធ័ថ្នាក់ជាតិមួយ ។ ការរាប់បញ្ចូលនូវអារម្មណ៍រំជួលចិត្តរបស់ លោកស្រី ជា លាង ជាភាសាខ្មែរថាតើអ្នកទោសមកដល់ដោយរបៀបណា ការបង្ខំឲ្យត្រូវតែអនុវត្តនិងត្រូវបង្ខំឲ្យផ្តល់ចម្លើយសារភាពដែលមិនសមហេតុផល ហើយចុងក្រោយត្រូវសម្លាប់នៅមន្ទីរស-២១ បានធ្វើឲ្យអ្នកដែលចូលរួមតាមដាននៅក្នុងបន្ទប់សវនាការស្រក់ទឹកភ្នែក ។ លោកស្រី ជា លាង ក៏បានរៀបរាប់អំពីទម្រង់នៃការធ្វើទារុណកម្មដ៏សាហាវហើយនឹងការធ្វើបាប (ដូចជាការបង្ខំឲ្យមនុស្សស៊ីលាមកជាដើម) ក៏ដូចជាធ្វើពិសោធន៍ផ្នែកវេជ្ជសាស្ត្រ និងការធ្វើការវះកាត់ទៅលើអ្នកទោសនៅក្នុងមន្ទីរស-២១ ។

នៅក្នុងការបង្ហាញជាផ្លូវការដ៏វែងមាំមួយ ក្រោយមក លោកស្រី ជា លាង បានរាប់បញ្ចូលធាតុផ្សំនៃការដាក់បន្ទុកទៅលើឧក្រិដ្ឋកម្មដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការឃុំឃាំង ការយកមកធ្វើជាទាសករ ការធ្វើទារុណកម្ម ការសម្លាប់ ការកម្ទេចចោល ការធ្វើទុក្ខបុកម្នេញ និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀតជាដើម) ឧក្រិដ្ឋកម្មសង្គ្រាម (ការចាប់បង្ខាំងជនស៊ីវិលចូលរួមក្នុងការប្រព្រឹត្តបទល្មើស ការធ្វើបាបយ៉ាងព្រៃផ្សៃ ការធ្វើទារុណកម្ម ហើយនឹងមានចេតនាសម្លាប់) ហើយនិងឧក្រិដ្ឋកម្មជាតិនៅក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ការធ្វើទារុណកម្មនិងសម្លាប់) ។ នៅត្រង់ចំណុចនេះ លោស្រី ជា លាង បានរំឭក

ទៅដល់តុលាការថា ការស្នើសុំលើកចុងក្រោយរបស់សហព្រះរាជអាជ្ញាគឺដើម្បីពិភាក្សាអំពីឧក្រិដ្ឋកម្មនៃការរំលោភនៅគុកទួលស្លែង ដែលវាផ្ទុយពីការជំទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ។ នៅក្នុងការដាក់បញ្ចូលធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះ លោកស្រី ជា លាង បានពឹងផ្អែកទាំងស្រុងទៅលើលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងធាតុផ្សំនៃឧក្រិដ្ឋកម្ម ។



សហព្រះរាជអាជ្ញា វីលៀម ស្មីត និង លោកស្រី ជា លាង

ទាក់ទងទៅនឹងសំណួរដែលសួរថាហេតុអ្វីបានជាសហព្រះរាជអាជ្ញាចង់ដាក់បន្ទុក ឌុច ជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាមបន្ថែមពីលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លោកស្រី ជា លាង បានបកស្រាយថា វិធានច្បាប់បានចែងថា សហព្រះរាជអាជ្ញាត្រូវតែប្រើលក្ខន្តិកៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងច្បាប់អន្តរជាតិ ។ បន្ថែមពីលើនេះទៀត លោកស្រី ជា លាង បានបញ្ជាក់អំពីសារសំខាន់ដែលធ្វើឲ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃសន្ធិសញ្ញាទីក្រុងហ្សឺណែវដើម្បីធ្វើឲ្យប្រាកដថា ការលើកឡើងទាំងនេះមិនត្រឹមតែជាពាក្យដែលមានតែនៅលើក្រដាសប៉ុណ្ណោះទេ ប៉ុន្តែវាបានឆ្លុះបញ្ចាំងអំពីឧក្រិដ្ឋកម្មយ៉ាងពិតប្រាកដរបស់ជនជាប់ចោទនិងនិយាយប្រាប់អំពីដំណើររឿងនៃឧក្រិដ្ឋកម្មទាំងមូលដែលបានធ្វើឡើងនៅក្នុងគុកទួលស្លែង ជាពិសេសប្រឆាំងនឹងជនស៊ីវិលរបស់វៀតណាម និងឈ្លើយសឹក ។ លោកស្រី ជា លាង ត្រូវបានបង្ខំឲ្យសារភាព ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គ្មានភ័ស្តុតាងជាក់លាក់ណាមួយបង្ហាញថា អ្នកជាប់ឃុំឃាំងជនជាតិវៀតណាមត្រូវបានធ្វើទារុណកម្មឡើយ ។ លោកស្រី ជា លាង បានឆ្លើយតបទៅវិញថា ជនជាតិវៀតណាមបានទទួលរងការធ្វើទារុណកម្មស្មើគ្នា បើសិនជាមិនអាក្រក់ជាងគឺស្មើនឹងអ្នកជាប់ឃុំឃាំងជនជាតិខ្មែរដែរ ។ លោកស្រី ជា លាង បានបន្ថែមថា បើតាមភ័ស្តុតាងនៅក្នុងឯកសាររួមមាន របាយការណ៍នៅក្នុងប្រពន្ធ័ផ្សព្វផ្សាយ ឯកសារផ្ទៃក្នុងរបស់ខ្មែរក្រហម និងសក្ខីកម្មអ្នកជំនាញរបស់ ណាយ៉ាន់ ចាន់ដា (អតីតអ្នកត្រួតពិនិត្យរបស់ “Far Eastern Economic Review” និងជាសហអ្នកនិពន្ធសៀវភៅមួយចំនួនទៀតដែលទាក់ទងនិងទ្វីបអាស៊ី) ជម្លោះប្រដាប់អាវុធអន្តរជាតិមួយបានចាប់ផ្តើមនៅក្នុងប្រទេសកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៥ រយៈពេលពីរបីខែបន្ទាប់ពីខ្មែរក្រហមចូលលុកលុយប្រទេសកម្ពុជា ។ ផ្ទុយមកវិញ មេធាវីការពារក្តីក្រោយមកបានបដិសេធថា គ្មានជម្លោះប្រដាប់អាវុធអន្តរជាតិណាមួយបានកើតឡើងទេ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមបានចូលលុកលុយប្រទេសកម្ពុជាដើម្បីបណ្តេញខ្មែរក្រហមចេញ ។

សហព្រះរាជអាជ្ញា វីលៀម ស្មីត បានបំភ្លឺលើការកាត់ទោសទាក់ទងទៅនឹងការទទួលខុសត្រូវជាបុគ្គលរបស់ ឌុច ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅគុកទួលស្លែង ។ វីលៀម ស្មីត បានសង្កត់ធ្ងន់ថា ឌុច បានបង្ហាញនូវការទទួលខុសត្រូវគ្រប់ទម្រង់ទាំងអស់ ជាអ្នកបង្កើតគម្រោង អ្នកបញ្ជា មេគំនិត អង្គរក្ស អ្នកសមគំនិត និងជាជនដៃដល់ដោយផ្ទាល់ ។ វីលៀម ស្មីត ក៏បានបញ្ជាក់ផងដែរថា ឯកសារនៃការចូលរួមឧក្រិដ្ឋកម្មបានចាប់យកនូវសារសំខាន់នៃភាពគួរឲ្យទុកចិត្តបានរបស់ជនជាប់ចោទ ។ គាត់ក៏បានបង្ហាញថា តុលាការដទៃទៀតយល់ថាច្បាប់ចូលរួមនៃឧក្រិដ្ឋកម្ម គឺជាទម្រង់មួយរបស់គណៈកម្មការ ហើយអ្នកព្រៀងច្បាប់លក្ខន្តិកៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជ្រើសរើសភាសាដែលស្រដៀងទៅនឹងតុលាការដែលបានរៀបចំផ្សេងទៀត ដើម្បីណែនាំនូវច្បាប់ចូលរួមនៃឧក្រិដ្ឋកម្មផងដែរ ។ អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាបានបម្រើលើការគ្រប់គ្រងច្បាប់នៃការចូលរួមរបស់ឧក្រិដ្ឋកម្មរហូតដល់ការវិនិច្ឆ័យទោស ។

វីលៀម ស្មីត បានបង្ហាញថា ឌុច បានសារភាពពីអំណាចទាំងមូលរបស់គាត់ទៅលើមន្ទីរស-២១ និងការទទួលខុសត្រូវ

ទូទៅរបស់គាត់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ហើយគាត់បានយល់ស្របចំពោះតារាងនៃការទទួលស្គាល់ការពិតទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់បុគ្គលិក និងមន្ទីរស-២១ ។ វីលៀម ស្មីត បានបង្ហាញថា ទោះបីជាយ៉ាងណាក៏ដោយ មានការលុបចោលនិងភាពខ្វះចន្លោះនៅក្នុងសក្ខីកម្មរបស់ ឌុច ។ ឌុច បានធ្វើតាមការបញ្ជារបស់មេ ហើយក៏មិនបានសារភាពពីការទទួលស្គាល់តួនាទីរបស់គាត់ដោយស្ម័គ្រចិត្ត ហើយជំនួសមកវិញដោយការនិយាយថា គាត់ជា «ចំណាប់ខ្មាំងនៃរបបនេះ» ។ ទោះបីជា ឌុច ព្យាយាមបង្ហាញថា ខ្លួនឯងមិនបានដឹងពីភាពពិតឲ្យបានលម្អិត និងសកម្មភាពកន្លងមកនៅក្នុងស-២១ ឬក៏អាស្រ័យទៅលើការបញ្ជាពីមេរបស់គាត់ក៏ដោយ ក៏ការអះអាងទាំងនេះមិនមែនកើតឡើងដោយគ្មានភស្តុតាងនោះទេ ។ វីលៀម ស្មីត បានរំឭកទៅដល់តុលាការថា មនុស្សចំនួន១៥៥នាក់ដែលត្រូវបានសម្លាប់នៅគុកទួលស្លែងគឺជាអតីតបុគ្គលិកគុក ដែលជាកូនចៅផ្ទាល់របស់ ឌុច ។ វីលៀម ស្មីត បានរៀបរាប់ថា ឌុច និងមេរបស់គាត់មានម្នាក់នឹងនាំយកមកកាត់ទោសនៅឆ្នាំក្រោយ ជា «បងធំប្រដាប់អាវុធ» ។ គាត់ក៏បានបង្ហាញថា ឌុច បានរស់នៅនៅក្នុងជីវិតគ្រួសារដ៏មានផាសុខភាពមួយនៅអំឡុងរបបខ្មែរក្រហម នៅក្នុងផ្ទះវីឡាដ៏ធំមួយនៅខណៈដែលអ្នកទោសរបស់គាត់ត្រូវដាក់ច្រវ៉ាក់ជាប់នឹងកម្រាលឥដ្ឋ ។

និយាយពីការកាត់ទោសវិញ វីលៀម ស្មីត បានសង្កត់ធ្ងន់ថា យោងតាមភាពធំសម្បើមនិងស្ថានភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ ឌុច វាចម្លែកខ្លាំងណាស់ដែលថា ឌុច ទទួលបានការដាក់គុកតិចជាងការដាក់គុកដែលមានរយៈពេលវែង ។ វីលៀម ស្មីត បានសង្កត់ធ្ងន់លើឥទ្ធិពលនៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ ខ្សែបណ្តាញមិត្តភក្តិ និងសាច់ញាតិរបស់គេទាំងអស់ កម្រិតនៃការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទ ហើយនិងការចូលរួមយ៉ាងសកម្មរបស់គាត់នៅក្នុងឧក្រិដ្ឋកម្ម ។ ដោយសារតែកត្តាធ្ងន់ធ្ងរនេះ វីលៀម ស្មីត បានលើកយកគោលសំខាន់ៗនៃអំណាចរំលោភបំពានរបស់ ឌុច ភាពយង់ឃ្នងនៃសកម្មភាពរបស់គាត់ ហើយមិនបានការពារទៅលើជនរងគ្រោះទេ ។ ក្រោយមក វីលៀម ស្មីត មានការសោកស្តាយជាខ្លាំងចំពោះកត្តាសម្រាលទោសនិងការចោទប្រកាន់ទោស ដូចជាថា ឌុច កំពុងតែសម្តែង ហើយវាស្ថិតនៅក្រោមការបង្ខិតបង្ខំ ។ ចំណុចនេះ វីលៀម ស្មីត បានសង្កត់ធ្ងន់ថា ឌុច ជឿជាក់ទាំងស្រុងទៅលើបទបញ្ជាដែលគាត់ទទួលបាននិងយល់ព្រមធ្វើដោយស្ម័គ្រចិត្ត ។ ទោះបីជា ឌុច បានផ្តល់នូវការសហការមួយចំនួនបន្ទាប់ពីការចាប់ខ្លួនគាត់ហើយក៏ដោយ ក៏ ឌុច បានប្រើឈ្មោះក្លែងក្លាយ ហើយនៅតែរស់នៅជាមួយកូនចៅអតីតខ្មែរក្រហមរបស់គាត់អស់រយៈពេលរាប់ឆ្នាំដដែល មុនពេលឃុំឃាំងខ្លួនគាត់ ។ គាត់ទើបតែចាប់ផ្តើមសហការនៅពេលដែលអ្នកថតរូបជនជាតិអៀកឡង់ម្នាក់ ឈ្មោះ នីក ដុនឡុប បានរកឃើញទីកន្លែងរស់នៅរបស់គាត់នៅក្នុងឆ្នាំ១៩៩៩ ដូចដែលបានដាក់បញ្ចូលទៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ពេជ្ឈឃាតបាត់ខ្លួន» ។ ឌុច ក៏បានតវ៉ាទៅនឹងភស្តុតាងមួយចំនួនដូចជាការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មនៅមន្ទីរម-១៣ (មុនពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច) ហើយបដិសេធមិនយកបញ្ជីឈ្មោះមកបង្ហាញ ឬក៏ទទួលសេចក្តីថ្លែងការណ៍របស់សាក្សីជំនួសឲ្យការធ្វើសក្ខីកម្ម ។ សកម្មភាពទាំងនេះនៅក្នុងការស្នាបស្ទង់របស់ វីលៀម ស្មីត បានបញ្ជាក់អំពីការស្ម័គ្រចិត្តរបស់ ឌុច ចំពោះការទទួលយកទំនួលខុសត្រូវទាំងស្រុងសម្រាប់សកម្មភាពរបស់គាត់ ឬក៏បណ្តោយឲ្យការពិតហូរចូលដោយសេរី ។ វីលៀម ស្មីត បានបញ្ជាក់ថា ការប្រឆាំងនឹងការនាំយកភស្តុតាងនៃពិរុទ្ធភាពគឺជាសិទ្ធិរបស់ ឌុច ក្នុងនាមជាជនជាប់ចោទមួយរូប ប៉ុន្តែវាមិនសមមូលទៅនឹងការសហការដែលគាត់បានលើកឡើងនិងការទទួលខុសត្រូវ ។

វីលៀម ស្មីត បានកត់សម្គាល់ឃើញថា ការផ្សះផ្សារជាតិគោលបំណងដ៏សំខាន់នៃតុលាការនេះ ហើយការដាក់ទោសតិចតួចដល់ ឌុច ពិតជាប៉ះពាល់ដល់គោលដៅនេះដោយចៀសមិនផុត ។ វីលៀម ស្មីត យល់ថា ឌុច គួទទួលបាននូវការកោតសសើរសម្រាប់ពេលវេលាដែលគាត់បានបម្រើនៅក្នុងមន្ទីរឃុំឃាំងយោធាមុនពេលប្តូរគាត់ត្រូវបានបញ្ជូនមកកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ ។ ប៉ុន្តែ ឌុច ត្រូវបានឃុំឃាំងដោយល្មើសច្បាប់អស់មួយរយៈ ហើយស្ថិតនៅក្រោមភាពមិនប្រក្រតីនៃច្បាប់ផ្សេងៗទៀត វីលៀម ស្មីត ក៏បានបញ្ជាក់ដែរថា ការដាក់ទោសអស់មួយជីវិតគួរតែត្រូវបន្ថយមករយៈពេល៤៥

ឆ្នាំវិញ ។ វីលៀម ស្មឹត បានផ្តល់យោបល់ថា តុលាការគួរតែកាត់រយៈពេលប្រាំឆ្នាំទៀតចេញដើម្បីបង្ហាញពីការសហការរបស់ ឌុច ជាមួយនឹងតុលាការ និងការបង្ហាញពីអារម្មណ៍សោកស្តាយ ។

## ៤) មេធាវីការពារក្តី

ក្រោយមក ឌុច បានក្រោកឈរ ។ ការឡើងបង្ហាញរបស់គាត់គឺជាការបង្រៀនមួយ ការនិយាយផ្តេសផ្តាស ហើយទំនងជាការការពិពណ៌នាដែលមិនច្បាស់លាស់ ហើយសង្កត់ធ្ងន់ទៅលើឯកសារយោងនៅក្នុងឯកសារកាត់ទោសដែលប្រហែលជាផ្នែកតូចប៉ុណ្ណោះដែលស្ថិតនៅខាងមុខអ្នកតាមដានប្រវត្តិសាស្ត្រខ្មែរក្រហម ។ ឌុច បានសួរសំណួរជាច្រើនទាក់ទងនឹងសក្ខីកម្មរបស់គាត់ជាមួយនឹងសុភាសិតខ្មែរដូចជា «មុនពេលកាប់ដើមឫស្សី អ្នកត្រូវតែរាស់បន្លាចេញ» ដែលនៅក្នុងឃ្លានេះ ហាក់ដូចជាគួរឲ្យខ្លាច ជាពិសេសនៅក្រោយពេលដែលគាត់រៀបរាប់ពីការកម្ទេចកម្មាភិបាលខ្មែរក្រហមថាជា «បន្លានៅក្នុងភ្នែក» ។ សក្ខីកម្មរបស់ ឌុច រៀបតាមលំដាប់ចាប់ពីការបង្កើតបក្សកម្ពុជាប្រជាធិបតេយ្យទៅដល់ចុងនៃសម័យខ្មែរក្រហម ។ ឌុច បានធ្វើសក្ខីកម្មពី «នយោបាយគ្រប់គ្រងបច្ចេកទេស» ហើយរៀបរាប់ពីការធ្វើទារុណកម្មដែល «មិនអាចចៀសរួច» ។ ឌុច បានលើកឡើងថា សកម្មភាពទាំងនេះបានបន្លាចគាត់ ហើយថាគាត់មានការភ័យខ្លាចក្នុងការដកខ្លួនចេញ ។ នៅចំណុចផ្សេងៗទៀត សេចក្តីថ្លែងការណ៍របស់ ឌុច ទាក់ទងនឹងបញ្ហា (ដូចជារចនាសម្ព័ន្ធថ្នាក់ដឹកនាំរបស់ខ្មែរក្រហមពាសពេញភូមិភាគខុសៗគ្នា) ដែលគួរឲ្យធុញទ្រាន់និងយល់ដឹងបានតិចតួច ដែលធ្វើឲ្យអ្នកចូលមកតាមដានចាប់ផ្តើមងងុយគេង ទោះបីជាអ្នកទាំងនោះជាធម្មតាភ្ញាក់ដឹងខ្លួន ដោយសារបុគ្គលិកតុលាការដែលស្ថិតនៅក្រោមការបញ្ជារបស់អគ្គជំនុំជម្រះ ដើម្បីការពារការលង់លក់បែបនេះក៏ដោយ ។ ទាក់ទងទៅនឹងតួនាទីរបស់ ឌុច នៅក្នុងប្រវត្តិសាស្ត្រនេះ គាត់បានរៀបរាប់ថាខ្លួនឯងបាន «ជាប់» ចូលទៅក្នុងសកម្មភាពឧក្រិដ្ឋកម្ម ដែលមានសិទ្ធិតែបន្តិចបន្តួចប៉ុណ្ណោះក្នុងការប្រឆាំងការសម្រេចចិត្តថាតើនរណាគួរតែ «កម្ទេច» ។

ចុងក្រោយ សេចក្តីថ្លែងការណ៍របស់ ឌុច បានក្លាយទៅជារឿងមួយដែលគ្រាន់តែជាការគិតរបស់ខ្លួនច្រើនជាង ។ ឌុច បានលើកឡើងយ៉ាងច្បាស់ថា «ខ្ញុំនៅតែជាបុគ្គលតែម្នាក់ប៉ុណ្ណោះដែលទទួលខុសត្រូវចំពោះការស្លាប់មនុស្សចំនួន១២០០០នាក់ ហើយវានៅតែជាការទទួលខុសត្រូវរហូត» ។ ប៉ុន្តែ ការអានចេញពីការកត់សម្គាល់ដែលបានរៀបចំរួចរបស់ ឌុច ហើយមិនបានមើលទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ ឌុច បានធ្វើសក្ខីកម្មថា គាត់បានជំពាក់ការទទួលខុសត្រូវមួយចំពោះប្រជាជនកម្ពុជា ហើយថាគាត់មានការសោកស្តាយយ៉ាងខ្លាំងដែលបានបូជាជីវិតរបស់គាត់ ហើយនិងជំនាញរបស់គាត់ទៅដល់បក្សឧក្រិដ្ឋកម្មច្រើនជាងយកទៅបម្រើប្រជាជនរបស់គាត់ ។ គាត់បានបង្កប់ន័យពីមុនមកថា គាត់ត្រូវបានផ្តល់នូវជម្រើសពីរ ហើយនៅក្នុងជម្រើសទីពីរ គឺជាផ្លូវមួយដែលដឹកនាំគាត់ទៅរកការឈឺចាប់គ្មានថ្ងៃបញ្ចប់ ។ ទីមួយ គាត់បានក្លាយទៅជាកង់មួយរបស់ម៉ាស៊ីនដែលមិនអាចត្រឡប់ថយក្រោយបាន ។ ឌុច បានសុំទោសទៅកាន់អ្នកស្លាប់ និងអ្នកដែលនៅរស់រានជីវិត ។ ឌុច បានសុំឲ្យជនរងគ្រោះបើកទ្វារចំហសម្រាប់គាត់ធ្វើការសុំទោស ហើយទទួលស្គាល់គាត់ថាជាសមាជិកម្នាក់នៃមនុស្សជាតិដែរ ។

ការផ្តល់ឲ្យនូវសេចក្តីថ្លែងការណ៍ដដែលនេះរបស់ ឌុច ដែលមិនបានក្រឡេកមើលទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឲ្យវាមានការលំបាកក្នុងការរកឲ្យឃើញថាតើគាត់ស្មោះត្រង់ប៉ុនណា ហើយភាពសោកស្តាយនៃការបង្ហាញទាំងនេះបានសម្តែងចេញមកតាមរយៈភាសាកំណើតរបស់គាត់ ។ តាមពិត ឥទ្ធិពលនៃអារម្មណ៍ដែល ឌុច មានមិនបានជួយសម្រាលដល់គាត់ទេ នៅពេលដែលគាត់បន្តអាននូវលេខយោងចំនួន៣៨ ដោយមិនបានបង្ហាញនូវឯកសារយោងត្រឹមត្រូវរបស់គេឡើយ ។

ចុងក្រោយ សេចក្តីថ្លែងរបស់ លោក ការ សាវុត្ថ ដែលគាត់ជាសហមេធាវីការពារកម្ពុជា របស់ ឌុច ហាក់បីដូចជាមិនមានភាពសុីគ្នាត្រង់ថា មនុស្សម្នាក់អាចទទួលការលើកលែងទោសដោយនិយាយពីករណីកូនក្តីម្នាក់ទៀតទៅវិញ ។ ជាជាងការយកចិត្តទុកដាក់ទៅលើការសហការរបស់ ឌុច ហើយនិងសិទ្ធិសម្រាលទោស លោក ការ សាវុត្ថ បានប្រឆាំងទៅនឹងយុត្តាធិការរបស់អគ្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយលើកឡើងថា ឌុច មិនមែនជាមនុស្សម្នាក់ដែល «ទទួលខុសត្រូវខ្ពស់បំផុត» ចំពោះ

ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម នៅខណៈដែលមានគុកចំនួន១៩៦នៅជុំវិញផ្ទៃប្រទេសនៅអំឡុងសម័យខ្មែរក្រហម ហើយមានមេគុកដទៃផ្សេងទៀតកំពុងរីករាយនឹងកិច្ចការរបស់គេទេ ។ គាត់បានប្រឆាំងទៅនឹងការដាក់បន្ទុករបស់សហព្រះរាជអាជ្ញា ដោយបង្ហាញភ័ស្តុតាងដែលប្រឆាំងទៅនឹងជម្លោះផ្នែកប្រដាប់អាវុធអន្តរជាតិមួយ ដោយលើកឡើងថា មានតែឈ្លើយសឹកជនជាតិវៀតណាមពីរបីនាក់ប៉ុណ្ណោះនៅគុកទួលស្លែងរហូតដល់ឆ្នាំ១៩៧៨ ហើយគាត់បានតវ៉ាថា ឌុច គួរតែទទួលបានអត្ថប្រយោជន៍ពីច្បាប់លើកលែងទោស ។

ក្នុងការត្រួតពិនិត្យភ័ស្តុតាងឡើងវិញរបស់គាត់ លោក ការ សាវុត្ថ បានលើកឡើងថា សមាជិករបស់គណៈកម្មការអចិន្ត្រៃយ៍ត្រូវតែទទួលខុសត្រូវលើការលើការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងការសម្លាប់នៃមន្ត្រីរបស់របបមុនដែលជាឧក្រិដ្ឋកម្មមិនត្រូវបានដាក់បន្ទុកទៅលើ ឌុច ។ លោក ការ សាវុត្ថ បានឡើងថា បន្ទាប់ពីខ្មែរក្រហមបានពង្រឹងអំណាចរបស់ខ្លួននូវទូទាំងប្រទេស មានតែគណៈកម្មការភូមិភាគ កម្មាភិបាលសំខាន់ៗនិងកម្មាភិបាលមួយចំនួនប៉ុណ្ណោះដែលមានសិទ្ធអំណាចកាប់សសម្លាប់អ្នកទោស ។ លោក ការ សាវុត្ថ បាន ចោទ នួន ជា, ខៀវ សំផន ពីបទឧក្រិដ្ឋកម្មនៅក្នុងមន្ទីរស-២១ ជនជាប់ចោទទាំងពីរនឹងត្រូវកាត់ទោសនៅករណី០០២ នៅឆ្នាំក្រោយ ហើយបានប្រកាសថា ប៉ុល ពត ដែលបានស្លាប់អស់រយៈពេលដប់ឆ្នាំទៅហើយក៏គួរតែត្រូវលើកយកមកកាត់ទោសដែរ ។ លោក ការ សាវុត្ថ បានលើកឡើងម្តងហើយម្តងទៀតលើការពិភាក្សាថាកូនក្តីរបស់គាត់ទទួលកំហុសជួសអ្នកដ៏ទៃ ដោយសង្កត់ធ្ងន់ថា របាយការណ៍បង្ហាញថា ឌុច មិនដែលបានសម្លាប់ដោយផ្ទាល់ ហើយថាគ្មានអ្នកក្រោមបង្គាប់ណាម្នាក់របស់ ឌុច ឥឡូវប្រឈមនឹងតុលាការដែរ ។ គាត់ធ្វើការសន្និដ្ឋានដោយនិយាយថា ឌុច គួរតែត្រូវបានលើកលែងទោស ពីព្រោះគាត់គ្រាន់តែទទួលបញ្ជាពីថ្នាក់លើ ។ ឌុច ជាមនុស្សម្នាក់



ដែល «ជាជនរងគ្រោះក្នុងនាមជាអ្នកស្មោះត្រង់នៅក្នុងរបបមួយ» ហើយខ្លួនគាត់ក៏និងត្រូវស្លាប់ដែរ ប្រសិនបើគាត់ប្រឆាំងនឹងបទបញ្ជានេះ ។ លោក ការ សាវុត្ថ បានសង្កត់ធ្ងន់ថា មានតែតុលាការនេះយុត្តិធម៌ទេ ទើបព្រលឹងអ្នកដែលបានស្លាប់នាំទៅរកសុគតិភព ។

នៅព្រឹកបន្ទាប់ មេធាវីជនជាតិបារាំងរបស់ ឌុច គឺលោក ហ្វ្រង់ ស៊័រូ បានឡើងទៅកាន់វេទិកា ។ លោក ហ្វ្រង់ស៊័រ រូហ្ស ជាអ្នកពូកែម្នាក់នៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលក្នុងចំណោមរឿងរ៉ាវរបស់កូនក្តីធំៗផ្សេងទៀតបានការពារដោយជោគជ័យដូចជាករណីជនជាប់ចោទឈ្មោះ អ៊ីណាស បាល់ហ្គីឡេសស៊ីម៉ា នៅក្នុងសវនាការនៅប្រទេសរវ៉ាន់ដានិងករណីអ្នកបួន់យន្តហោះឈ្មោះ ហ្សាខារីយ៉ាស មូសាអ៊ូយ ដែលបានរួចផុតពីការដាក់ទោសប្រហារជីវិតសម្រាប់បទឧក្រិដ្ឋដែលបានប្រព្រឹត្តិយ៉ាងធ្ងន់ធ្ងបំផុតប្រចាំសតវត្សរ៍២០ក្នុងហេតុការណ៍វាយប្រហារថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ។ លោក រូហ្ស បានចាប់ផ្តើមបង្ហាញដោយប្រកាសថា នេះគឺជាលើកចុងក្រោយហើយដែលគាត់មានមុខនៅទីនេះ ព្រោះគាត់និងចាប់ផ្តើមការងាររបស់គាត់នៅឯតុលាការពិសេសសម្រាប់ប្រទេសឡេបាណន់ ។ គាត់ក៏បានសារភាពផងដែលថា គាត់ត្រូវបានគេបង្ខំឲ្យកែលំពាក្យពេចន៍របស់គាត់មួយថ្ងៃមុនហើយ លោក រូហ្ស បានបង្ហាញទៀតថា គាត់មិនយល់ព្រមទៅនឹងការដាក់បន្ទុកមួយចំនួនចំពោះកូនក្តីរបស់គាត់ទេ ។ លោក រូហ្ស បានទទួលស្គាល់នូវស្ថានភាពមួយដែលកូនក្តីរបស់គាត់បានធ្វើការសុំទោសនូវកំហុសរបស់ខ្លួន និងស្នើដល់តុលាការថា គាត់មិនបានធ្វើខុសទេ ស្រដៀងគ្នាទៅនឹងជនជាប់ចោទម្នាក់ឈ្មោះ អាល់បើត ស្បៀ ដែលទទួលខុសត្រូវនូវទង្វើរបស់ខ្លួន តែមិនបានធ្វើការសុំទោសជាផ្លូវការដូច ឌុច ទេ ហើយ លោក ស្បៀ ជាប់គុកត្រឹមតែ ២០ឆ្នាំប៉ុណ្ណោះ ។ លោក រូហ្ស បានព្យាយាមធ្វើការកត់សម្គាល់ទៅលើការពាក្យពេចន៍របស់ ឌុច ដោយគូសបញ្ជាក់ថា ការសុំទោសរបស់ ឌុច គឺជាការស្មោះត្រង់ «ពេលដ៏ស្មោះត្រង់» ហើយការស្រក់ទឹកភ្នែករបស់គាត់បានបញ្ជាក់ពីភាពស្តាយក្រោយដែលគ្មាននរណាម្នាក់សង្ស័យចំពោះរឿងនេះទេ ។

ការបង្ហាញចុងក្រោយរបស់លោក រូហ្ស ក្នុងបំណងបង្ហាញទៅដល់សហព្រះរាជអាជ្ញានិងការបរាជ័យក្នុងការផ្តល់គុណសម្បត្តិគ្រប់គ្រាន់ចំពោះ ឌុច ។ សង្កត់ធ្ងន់នៅលើចំណុចនេះ លោក រូហ្ស បានបញ្ចាំងខ្សែភាពយន្តដែលដកស្រង់ចេញពីការបិទការស៊ើបសួររបស់ជនជាប់ចោទ ភីធើ ម៉េកកូស្គី នៃសាលាក្តីយូហ្គោស្លាវី ក្នុងករណីអូប្រេណូវីកដោយទាក់ទងទៅនឹងមេបញ្ជាការយោធាម្នាក់ទទួលការចោទប្រកាន់ពីបទប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនៅស្រេប្រេនីកា ព្រះរាជអាជ្ញានៅក្នុងសាលាក្តីបានទទួលស្គាល់កំហុសរបស់ជនត្រូវចោទ វិប្បដិសារីដ៏ស្មោះត្រង់របស់ជនត្រូវចោទ និងការសហការរបស់គាត់ចំពោះសាលាក្តី ហើយបន្ទាប់គាត់ត្រូវទទួលទោស១៧ឆ្នាំ ។ នៅចុងបញ្ចប់នៃខ្សែវីដេអូ លោក រូហ្ស បាននិយាយថា នេះជាអ្វីដែលតុលាការនេះគួរតែធ្វើ ហើយបានបញ្ជាក់ថាកិច្ចសន្ទនាបន្ថែមរវាងមេធាវីការពារក្តីនិងព្រះរាជអាជ្ញាបានចៀសវាងការរអាក់រអួលមុនថ្ងៃសវនាការ ។ លោក រូហ្ស បានជំរុញឲ្យសាលាក្តីផ្តោតសំខាន់ទៅលើការបន្ធូរបន្ថយទោសជារឿងដែលថ្លៃថ្លាបំផុត ជាពិសេសអនុញ្ញាតឲ្យ ឌុច មានឱកាសបន្តសហការរឿងក្តី០០២បន្តទៀត ហើយការពិតទៅគាត់បានចំណាយអស់៣០ឆ្នាំរួចទៅហើយក្នុងការជាប់ទោស «ដូចជាការគេចខ្លួនបន្ទាប់មកត្រូវជាប់គុកយោធា» ជាដើម ។

លោក រូហ្ស ក៏បានអំពាវនាវដដែលៗផងដែរអំពីទស្សនៈនៃការស្តាប់បង្គាប់ ដោយនិយាយថា កូនក្តីរបស់គាត់មិនដែលរីករាយនូវស្ម័យភាពរបស់ខ្លួន ហើយមិនដែលប្រឌិតរឿងរ៉ាវប្រវត្តិសាស្ត្រឡើងវិញទេ ។ លោក រូហ្ស បានធ្វើការរិះគន់ដល់ព្រះរាជអាជ្ញាពីការកំណត់ថាកូនក្តីរបស់គាត់ត្រូវទទួលខុសត្រូវស្មើនឹងប៉ុលពតដែរ នៅពេលដែលភ័ស្តុតាងរួមមានសក្ខីកម្មដែលកើតចេញពីសាក្សីរបស់ព្រះរាជអាជ្ញាផ្ទាល់បានលាតត្រដាងថា ឌុច គួរតែត្រូវបានសម្លាប់បើសិនជាគាត់មិនធ្វើ ។

ត្រឡប់ទៅលើបញ្ហាច្បាប់វិញ លោក រូហ្ស បានធ្វើការតវ៉ាថា ឌុច មិនត្រូវបានចោទប្រកាន់ពីបទពាក់ព័ន្ធដោយផ្ទាល់ក្នុងអំពើទារុណកម្ម ដូចដែលព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ទេ ។ គាត់បានលើកឡើងថា ឌុច ដូចជាជនរងគ្រោះដ៏ទៃទៀតដែរ ឌុច ប្រហែលជាទទួលរងនូវជំងឺផ្លូវចិត្តធ្ងន់ធ្ងរដែលធ្វើឲ្យគាត់មានការច្របូកច្របល់ផ្នែកស្មារតី ដែលអាចពន្យល់ពីលក្ខណៈផ្លូវចិត្ត

បន្តិចម្តងៗរបស់ ឌុច ។ លោក រូហ្ស ទទូចឲ្យតុលាការនាំ ឌុច ត្រឡប់ទៅកាន់ «ភាពជាមនុស្សជាតិ» ឡើងវិញ ។

### ៥) ការចោទប្រកាន់ខុស

ការចោទប្រកាន់ខុសដែលផ្តល់ដល់ភាគីទាំងអស់ដើម្បីផ្តល់យោបល់ឲ្យគ្នាទៅវិញទៅមកចំពោះសេចក្តីថ្លែងការណ៍បញ្ចប់បានចាប់ផ្តើមឡើងភ្លាម ។ ក្រុមរដ្ឋប្បវេណីទាំងអស់បានចោទប្រកាន់ភាគីជាប់ចោទថា ជិះសេះពីរក្នុងពេលតែមួយ ដែលមានន័យថាសេចក្តីថ្លែងការណ៍មិនស៊ីសង្វាក់គ្នាជាការធ្វើទុក្ខបុកម្នេញដល់ដំណើការ ដែលបញ្ហានេះគួរតែត្រូវបានដោះស្រាយក្នុងបណ្តាមេធាវីការពារក្តីដោយខ្លួនឯង ។ លោក ការីម ខាន់ បានចោទប្រកាន់ ឌុច ថាមិនបានសហការជាមួយព្រះរាជអាជ្ញា ជាជាងយកចិត្តទុកដាក់នូវសំណួររបស់ព្រះរាជអាជ្ញា ។ លោកស្រី ស៊ុជហ្វីនស្គី បានហៅទង្វើរបស់ភាគីចុងចោទថាជាការ «ទះកំភ្លៀងចំកណ្តាលមុខ» របស់ភាគីរដ្ឋប្បវេណី ។ ភាគីរដ្ឋប្បវេណីទាំងអស់មានការសង្ស័យពីភាពមិនស្មោះត្រង់របស់ ឌុច ហើយ ចាក់យ៉ឺន ចោទប្រកាន់ ឌុច ថាខិតខំស្វែងរកការសណ្តោសប្រណីពីជនរងគ្រោះរបស់គាត់ដែលអ្នកទាំងនោះមិនដែលមានចិត្តអាណិតចំពោះ ឌុច ទាល់តែសោះ ។

បន្ទាប់ពីការកោតសសើរពីសេវាកម្មរបស់លោក រូហ្ស ចំពោះយុត្តិធម៌អន្តរជាតិ លោក ខាណុន បានចោទប្រកាន់ជនរួមជាតិរបស់គាត់ថាបានក្បត់ដៀលកូនក្តីរបស់គាត់ ដោយប្រៀបធៀបចំនួនជនជាតិកម្ពុជារាប់លាននាក់ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ លោក ហុង គឹមសួន ខ្លួនឯងជាជនរងគ្រោះម្នាក់បានព្យាមយាមនៅស្ងាត់ពីរដងក្នុងអំឡុងពេលជជែកតវ៉ានេះ ។ លោក បានចោទប្រកាន់លោក ការ សាវុត្ថ ថា ព្យាយាមកែប្រែសក្ខីកម្មរបស់កូនក្តីខ្លួនដែលប្រការនេះធ្វើឲ្យជនរងគ្រោះមានការឈឺចាប់ ។

បន្ទាប់មក សហព្រះរាជអាជ្ញាបានបង្ហាញពីការចោទប្រកាន់របស់ខ្លួន ហើយស្ថានភាពចាប់ផ្តើមមានភាពច្របូកច្របល់ឡើង ។ លោក វីលៀម ស្មីត ប្រាប់ចៅក្រមថាជនរងគ្រោះត្រូវបានធ្វើឲ្យយល់ខុសដោយសំណើភ្លាមរបស់ លោក ការ សាវុត្ថ ទៅលើរឿងភាពគ្មានទោសរបស់ ឌុច ។ តាមពិតទៅ សហព្រះរាជ្ញាបានធ្វើការពិភាក្សាថា ឌុច មិនគួរទទួលបាននូវអត្ថប្រយោជន៍ចេញពីការបន្ធូរបន្ថយទោសណាមួយចំពោះការសហការរបស់គាត់ទេ ដោយគាត់ស្វែងរកភាពគ្មានទោសរបស់គាត់ ។ លោក ស្មីត កំពុងតែមានការងឿងឆ្ងល់យ៉ាងខ្លាំងថាតើ លោក ការ សាវុត្ថ កំពុងដើរតាមការណែនាំពីក្រុមប្រឹក្សារបស់គាត់ដែរឬក៏អត់ ឬក៏គាត់ធ្វើឡើងដោយខ្លួនឯង ដោយទុកកូនក្តីរបស់គាត់មួយឡែក ។ លោក ស្មីត ជាអតីតជាអ្នកកាត់ក្តីម្នាក់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ហើយបានដឹងយ៉ាងច្បាស់ពីស្ថានភាពរបស់ អូប្រេនណូវីក ពីករណីដែលថា ជនជាប់ចោទ អូប្រេនណូវីក មានការរីករាយនឹងតួនាទីរបស់គាត់ជាមេបញ្ជាការយោធាម្នាក់មុននឹងចូលសមាហរណកម្មជាមួយរដ្ឋាភិបាលយូហ្គោស្លាវី ហើយត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវលើការបញ្ជាទ័ពដូចជាការបរាជ័យក្នុងការទប់ស្កាត់កងទ័ព ។

ម្យ៉ាងវិញទៀត ឌុច មានប្រវត្តិយូរអង្វែងពីការចូលរួមអំពើរំលោភបំពានមុនរបបខ្មែរក្រហម ។

លោកស្រី ជា លាង បានថ្លែងថា កិច្ចពិភាក្សាតវ៉ាតាមផ្លូវច្បាប់របស់លោក ការ សាវុត្ថ បានគូសបញ្ជាក់តិចតួចទៅនឹងច្បាប់អន្តរជាតិ ច្បាប់ក្នុងស្រុក និងវិធានរបស់តុលាការ ។ លោកស្រីបានលើកឡើងផងដែរថាប្រសិនបើ ឌុច បានរក្សាលំនឹងរបស់គាត់នៅអំឡុងពេលសវនាការ ជនរងគ្រោះទាំងអស់ប្រហែលជានឹងទទួលយកការសុំទោសរបស់គាត់ ។

ត្រង់ចំណុចនេះ លោក ការីម ខាន់ បានធ្វើអន្តរាគមន៍ចំពោះសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញា ហើយបានស្នើឲ្យតុលាការអញ្ជើញ ឌុច ឲ្យឆ្លើយឡើងវិញដើម្បីបញ្ជាក់ពីជំហររបស់ខ្លួនម្តងទៀត ។

លោក ការ សាវុត្ថ និង លោក រូហ្ស បានថ្លែងបញ្ជាក់ឡើងវិញពីអ្វីដែលខ្លួនបាននិយាយរួចហើយថា ទោះបីជា ឌុច លាលែងពីតំណែងនៅពេលនោះក៏ដោយ ក៏មានមនុស្សផ្សេងទៀតមកជំនួស ឌុច ជាមិនខាននៅមន្ទីរស-២១ ។ ទោះបីមិនមានច្បាប់ចែងក៏ដោយ លោក ស្មីត បានលើកឡើងម្តងទៀត ដោយស្នើជនត្រូវចោទជ្រើសរើសមេធាវីការពារម្នាក់ ។

ប្រធានសាលាក្តី លោក និល ណុន ជាចុងក្រោយបានកោះហៅជនជាប់ចោទដើម្បីនិយាយចុងក្រោយនិងនិយាយពីជំហរ

របស់ខ្លួនម្តងទៀត ។ ឌុច បានក្រោកឈរ ហើយនិយាយថា ៖

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ឱកាសដែលបានផ្តល់ឲ្យខ្ញុំដើម្បីនិយាយជាចុងក្រោយ ។ ជាដំបូង ខ្ញុំចង់ប្រាប់តុលាការអំពីកិច្ចសហប្រតិបត្តិការរបស់ខ្ញុំជាមួយនឹងតុលាការ ...ខ្ញុំបានប្តេជ្ញាថានឹងរាយការណ៍ទៅដល់តុលាការដោយការគោរព និងស្មោះត្រង់បំផុត ដោយផ្អែកលើការចងចាំទាំងឡាយរបស់ខ្ញុំ និងនៅតុលាការយោធា រាល់ឯកសារទាំងអស់ដែលខ្ញុំបានសហប្រតិបត្តិការកន្លងមក និងក្នុងការឆ្លើយតបរាល់សំណួររបស់លោកចៅក្រម ដែលបានផ្តល់រួចរាល់ទៅអង្គជំនុំជម្រះវិសាមញ្ញ ។ នៅទីនេះ នៅតុលាការនេះ ខ្ញុំបានឆ្លើយតបរាល់សំណួរដែលបានសួរមកខ្ញុំដោយសហចៅក្រមស៊ើបអង្កេត និងសំណួរបន្ថែមដោយសហព្រះរាជអាជ្ញា ។ រាល់ការកត់ត្រាកិច្ចសម្ភាសន៍នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានប្រើប្រាស់យ៉ាងល្អជាភ័ស្តុតាង និងតឹកតាង រាល់សំណួរត្រូវបានគេសួរខ្ញុំយ៉ាងពេញទំហឹងដោយភាគីដើមចោទនិងចុងចោទ និងដាក់កៅអីឲ្យខ្ញុំអង្គុយ ហើយខ្ញុំបានឆ្លើយយ៉ាងពេញទំហឹងទៅគ្រប់ប្រភេទនៃសំណួរនិងតឹកតាងត្រូវបានគេរកឃើញនៅក្នុងឯកសារចម្លងរាប់រយទំព័រ ។

ដូច្នេះ នៅទីនេះខ្ញុំនឹងប្រាប់ទៅតុលាការថា ខ្ញុំបានសហប្រតិបត្តិការយ៉ាងពេញទំហឹងជាមួយតុលាការគ្រប់កម្រិត រាប់បញ្ចូលតុលាការក្នុងស្រុក តុលាការយោធា និងតុលាការកូនកាត់នេះ ។ ចំណុចទីពីរ ខ្ញុំសូមសម្តែងនូវភាពខ្វល់ខ្វាយចំពោះការសុំទោសរបស់ខ្ញុំនិងការទទួលកំហុសរបស់ខ្ញុំ ។ ខ្ញុំមិនដែលភ្លេចម្តងណាទេចំពោះមនុស្សរាប់លាននាក់ដែលបានស្លាប់ក្នុងរបបខ្មែរក្រហមរាប់បញ្ចូលទាំងសាច់ញាតិរបស់ខ្ញុំដែរ ហើយខ្ញុំបានយល់ពីមនុស្សទាំងអស់នោះឈឺចាប់កម្រិតណាមុននឹងស្លាប់ ។ ហើយខ្ញុំក៏សូមប្រើពាក្យផ្សេងទៀតដែលដែលបទឧក្រិដ្ឋទាំងអស់នោះបានប្រព្រឹត្តដោយបក្សកុម្មុយនីសកម្ពុជា ដោយខ្លួនខ្ញុំផ្ទាល់ក៏ជាសមាជិកនៃបក្សនេះដែរ ហើយ ប៉ុល ពត បានសំដៅលើក្រុមមនុស្សទាំងនោះថាជាអ្នកសម្លាប់ ហើយខ្ញុំបានស្ថិតនៅក្នុងចំណោមសមាជិកទាំងនោះដែរ ។ ដូច្នេះ ខ្ញុំចង់ស្វែងរកការអភ័យទោសនៅចំពោះមុខប្រជាជនខ្ញុំ និងប្រទេសរបស់ខ្ញុំ ។ កាលពីម្សិលមិញ ព្រះរាជអាជ្ញាអន្តរជាតិ ព្រះរាជអាជ្ញាជាតិបានកំណត់ចំនួនថ្មីនៃចំនួនអ្នកស្លាប់ ១២៣០០នៅមន្ទីរស-២១ ។ ទោះបីជាយ៉ាងណា ខ្ញុំមិនដែលតវ៉ាប្រឆាំងនឹងចំនួននោះដែរ ពីព្រោះខ្ញុំបានសារភាពថា ទោះបីជាមានចំនួនច្រើនជាងនេះ ក៏ខ្ញុំនៅតែទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដោយមិនអាចប្រកែកបាដែរ ។ ខ្ញុំនៅតែរក្សាតួនាទីរបស់ខ្ញុំថា ខ្ញុំទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មទាំងឡាយក្នុងនាមជាសមាជិកនៃបក្សឧក្រិដ្ឋ ។

ក្រោយមក ឌុច បាននិយាយថា «ខ្ញុំនឹងទុកតួនាទីនេះឲ្យតុលាការជាអ្នកសម្រេច ។ ខ្ញុំនឹងស្នើទៅអង្គជំនុំជម្រះដើម្បីឲ្យដោះលែងខ្ញុំ ។ ខ្ញុំមានវប្បធិសារីជាទីបំផុត» ។ ចៅក្រម ស៊ីលវៀ ខាត់វ៉ាយ នៃប្រទេសញូស៊ីលែនបានស្នើម្តងទៀតទៅ ឌុច ដើម្បីបញ្ជាក់ឲ្យច្បាស់ឡើងវិញពីជំហររបស់គាត់ ហើយ ឌុច បានប្រគល់តួនាទីនេះទៅមេធាវីរបស់គាត់ឲ្យនិយាយជំនួស ។

បន្ទាប់មក លោក ការ សាវុត្ថ ក្រោកឈរនិងធ្វើការបញ្ជាក់ថាសំណើក្នុងការដោះលែងជាអ្វីដែលត្រូវធ្វើការសម្រេចជាផ្លូវការ មិនមែនជាការសម្រាលទោសទេ ។

ជាមួយនឹងពាក្យចុងក្រោយ ឌុច និង មេធាវីការពារក្តីរបស់គាត់បានច្រានចោលនូវការតស៊ូទ្រាំនៃការទទួលការខុសត្រូវ ការបញ្ជាក់នូវកំហុសដែលខ្លួនបានធ្វើ ហើយសង្ឃឹមថានឹងមានការបន្ធូរបន្ថយទោសសម្រាប់ខ្លួនគាត់ ។

## ៦) សេចក្តីសន្និដ្ឋាន

ច្រើនសប្តាហ៍កន្លងទៅប្រកបទៅដោយការចាប់អារម្មណ៍ដ៏លើសលប់ ។ ឧទាហរណ៍ នៅពេលដែល ឌុច បានឈានជើងចូលដល់បន្ទប់សវនាការលើកដំបូង គាត់តែងតែឱនលំទោនទៅដល់សាធារណជន បង្កើតនូវភាពញញឹមក្នុងចំណោមអ្នកស្តាប់ និងបើកឱកាសទទួលការឱនលំទោនត្រឡប់មកវិញ ។ ត្រង់ចំណុចមួយ ឌុច សរសេរពាក្យពេចន៍លើក្រដាសតូចមួយ រួចបិទលើកញ្ចក់ដែលសាធារណជនទូទៅដឹងពីរឿងនេះ ។ នៅពេលមួយទៀត ជនបរទេសម្នាក់បានសរសេរក្រដាសបិទលើជញ្ជាំងវិញដោយបង្ហាញនូវការការគោរពតបវិញ ។ មេធាវីជាច្រើនបានចោទសួរចំពោះការផ្លាស់ប្តូររបស់ ឌុច ទៅគ្រិស្តសាសនា ដែលជាជម្រើសមួយនាំគាត់ទៅរកការសុំទោស ។ ការជម្រះក្តីចុងក្រោយរំពឹងថានឹងធ្វើឡើងនៅរដូវផ្ការីកខាងមុខនេះ ។ **ប៊ែត ម៉ាន់ស្កាត់**

# យុត្តិធម៌អន្តរកាលដែលស្របពេចស្របពិលនៅ អ៊ូហ្គង់ដា និង ប៉ៃលិន

*ឈ្មោះរបស់អ្នកផ្តល់បទសម្ភាសន៍ត្រូវបានផ្លាស់ប្តូរ*

ពាក្យសម្តីរបស់ លៀម ហ្វូកណឺ ដែលថា «អតីតកាលមិនបានស្លាប់ទេ ។ តាមការពិត វាស្ទើរតែមិនមែនជាអតីតកាលផង» និង «ការគូសបន្ទាត់នៅពីក្រោមអតីតកាលនឹងមិនមែនជាដំណោះស្រាយតែមួយទៀតទេ ប្រទេសដែលទើបតែរួចផុតពីអំពើហិង្សានយោបាយត្រូវតែជ្រើសរើសផ្លូវដើម្បីប្រឈមមុខនឹងកេរដំណែលដែលបន្សល់ទុកពីការគាបសង្កត់និងការបង្ហូរឈាម» មានអត្ថន័យសម្រាប់សង្គមក្រោយជម្លោះនៅក្នុងពិភពលោក ។ ការពិភាក្សាក្រោយជម្លោះបង្ហាញពីកិច្ចការផ្សារពីរដែលមិនអាចកើតមាននៅពេលជាមួយគ្នាគឺថា របបថ្មីត្រូវប្រឈមមុខនឹងការជ្រើសរើសយុត្តិធម៌ ឬការផ្សះផ្សា ។ ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនិងគណៈកម្មការស្វែងរកការពិតគឺជាលទ្ធផលនៃការពិភាក្សាជាបន្តបន្ទាប់ដើម្បីស្វែងរកយន្តការដោះស្រាយបញ្ហា ។ ប៉ុន្តែ មានមនុស្សជាច្រើនមិនគាំទ្រនឹងយុត្តិសាស្ត្រនេះដោយអះអាងថា យុត្តិធម៌និងការផ្សះផ្សាបានលាយបញ្ចូលគ្នានៅអំឡុងពេលកសាងប្រទេស ។ តាមទស្សនៈនេះ ទំនាក់ទំនងរវាងយន្តការអន្តរកាលនិងដំណើរការកសាងប្រទេសមិនដំណើរការស្របគ្នាទេ ។ ការកសាងក្រោយជម្លោះពោរពេញទៅដោយភាពខុសគ្នារវាងអ្វីដែលបានរំពឹងទុក បញ្ហាអាចរាំងរាំង ភាពស្របពេចស្របពិល និងចំណុចប្រសព្វគ្នាជាច្រើនដែលបណ្តាលឲ្យការបកស្រាយពន្យល់របស់បុគ្គលក្លាយជាគ្មានខ្លឹមសារ ។ តាមរយៈការសិក្សាពី អ៊ូហ្គង់ដា នៅអាហ្វ្រិកខាងត្បូង និងប៉ៃលិន នៅប្រទេសកម្ពុជាឃើញថា «យុត្តិធម៌អន្តរកាលដែលស្របពេចស្របពិលនៅ អ៊ូហ្គង់ដា និងប៉ៃលិន» កើតមានដោយមនោគមន៍វិជ្ជា ។ បទសម្ភាសន៍ជាមួយប្រជាជនដែលរស់នៅក្នុងតំបន់បានផ្តល់ជាពន្លឺដល់ការស្វែងយល់ពីបរាជ័យ ភាពនៃគំរូដ៏តឹងរ៉ឹង ប៉ុន្តែវាធ្វើឲ្យទ្រឹស្តីពាក់ព័ន្ធនឹង «ភាពស្របពេចស្របពិល» កាន់តែមានភាពគួរឲ្យជឿជាក់ ។

អ៊ូហ្គង់ដា ដែលជាតំបន់មួយនៅក្នុងទីក្រុងការូ ត្រូវបានរកឃើញនៅក្នុងទសវត្សរ៍៩០គឺនៅចំពាក់កណ្តាលនៃការផ្លាស់ប្តូរលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ ដោយត្រូវបានបង្កើតឡើងដោយប្រជាជនអភិរក្សនិយមអាហ្វ្រិកខាងត្បូងដែលជាកន្លែងធ្លាប់មានការរើសអើងពីជនជាតិស្បែកសទៅលើជនជាតិស្បែកខ្មៅបានទាក់ទាញចំណាប់អារម្មណ៍អ្នកធ្លាប់មានទំនាក់ទំនងជាមួយអតីតគណបក្សជាតិរបស់រដ្ឋាភិបាលនិងអ្នកគាំទ្រតំបន់បំបែកខ្លួនរបស់ជនជាតិអាហ្វ្រិក ។ នៅពេលជាមួយគ្នានេះដែរ ខេត្តប៉ៃលិនដែលកាលពីមុនជាតំបន់សម្បូរទៅដោយរ៉ែ គឺជាទីបញ្ជាការរបស់ខ្មែរក្រហមនៅអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាលទ្ធផលនៃការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជាទាហានខ្មែរក្រហមជាច្រើនបានរត់ទៅខេត្តនេះដោយប្រើយកទីតាំងនៅតាមព្រំប្រទល់ដើម្បីធ្វើសង្គ្រាមស៊ីវិលទ័ពព្រៃ ។ ប៉ៃលិនគឺជាតំបន់ក្រោយគេដែលចុះចូលជាមួយរដ្ឋាភិបាលថ្មីបន្ទាប់ពីត្រូវបានខ្មែរក្រហមគ្រប់គ្រងអស់ប៉ុន្មានទសវត្សរ៍ ។ អ៊ូហ្គង់ដា ក៏ជាស្រុកកំណើតរបស់អតីតសមាជិករបស់របបមួយចំនួនផងដែរ ។


ទាហានជុំរ៉ាំនៅខេត្តប៉ៃលិន

ដោយតំបន់ទាំងពីរនេះមានលក្ខណៈ

ពិសេស វាបានបង្ហាញពីបញ្ហាក្រោយជម្លោះមួយចំនួន។ ដោយបានដឹងពីប្រវត្តិសាស្ត្រ បទពិសោធន៍ដែលកើតមាននៅអូរ៉ាំងនា និង ប៉ៃលិន បានបង្ហាញយ៉ាងច្បាស់ថាយុត្តិធម៌និងការផ្សះផ្សាកើតមានដោយរបៀបណានៅក្នុងរយៈពេលអន្តរកាល។ អាហ្វ្រិកខាងត្បូងនិងកម្ពុជាបានប្រើប្រាស់មធ្យោបាយផ្សេងៗជាច្រើនដើម្បីដោះស្រាយបញ្ហាអតីតកាល។ រដ្ឋាភិបាលសភាជាតិអាហ្វ្រិកខាងត្បូងបានបង្កើតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាដែលជាយន្តការសាធារណៈដើម្បីដោះស្រាយឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៦០-៩៤ ដែលជារយៈកាលសំខាន់នៃរបបអាប៉ាថេត ការរើសអើងរបស់ប្រជាជនស្បែកសទៅលើប្រជាជនស្បែកខ្មៅ(នៅអាហ្វ្រិកខាងត្បូង)។ ដើម្បីស្វែងរក «ការពិត» សម្រាប់ប្រវត្តិសាស្ត្រ គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាបានផ្តល់ការលើកលែងទោសដល់ជនដៃដល់ ដោយឲ្យអ្នកទាំងនោះសារភាពពីសកម្មភាពរបស់ខ្លួន។ ប្រទេសកម្ពុជាក៏ទើបតែបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាតុលាការកាត់ទោសឧក្រិដ្ឋកម្មសង្រ្គាម ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដែរ។ ខណៈពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានវិសាលភាពអាចកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ អ្នកគាំទ្រមួយចំនួនយល់ថា តុលាការគឺជាមធ្យោបាយសម្រាប់ដោះស្រាយនិទ្ទណ្ឌភាពនិងសម្រាប់ដាក់ឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយស្ថិតនៅក្នុងចំណុចសំខាន់នៃការព្យាយាមស្វែងរកយុត្តិធម៌អន្តរកាល ប្រជាជននៅប៉ៃលិន និងអូរ៉ាំងនា មានរឿងជាច្រើនត្រូវនិយាយទាក់ទងនឹងជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងប្រទេសឡើងវិញនិងការធ្វើឲ្យប្រទេសសម្រេចបាននូវគោលដៅនៃយុត្តិធម៌ និងការផ្សះផ្សា។ តើប្រជាជននៅក្នុងតំបន់អាចប្រាប់អ្វីដល់យើងចំពោះការប្រើប្រាស់គំរូដូយគ្នានេះ? តើទស្សនៈរបស់អ្នកទាំងនេះអាចធ្វើឲ្យយើងយល់ពីយន្តការអន្តរកាលបានដែរឬទេ? ឬតើទស្សនៈរបស់អ្នកទាំងនេះធ្វើឲ្យយើងគិតទៅដល់គំរូវិភាគដែលផ្លាស់ប្តូរឬទេ?

អ្វីដែលបានកើតនៅ អូរ៉ាំងនា និង ប៉ៃលិន នឹងត្រូវបានដោះស្រាយដោយការផ្សះផ្សានិងតុលាការដែលមានយុត្តិធម៌។ ដូចដែលបានរៀបរាប់ខាងលើ តុលាការឧក្រិដ្ឋកម្មសង្រ្គាមតែងតែដឹងពីបញ្ហាបែបនេះនៅពេលដំណើរការការផ្សះផ្សា។ អ្នកដឹកនាំនយោបាយនិងបញ្ញវន្តតែងតែអះអាងថា ការដាក់ទោសតាមរយៈការកាត់ទោសនៅតុលាការធ្វើឲ្យបញ្ហាកាន់តែអាក្រក់ឡើង ហើយនៅក្នុងករណីខ្លះវាអាចធ្វើឲ្យមានអំពើហិង្សាកាន់តែខ្លាំង។ នៅប្រទេសកម្ពុជា អ្នកគាំទ្រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវប្រឈមមុខនឹងអ្នកដែលអះអាងថា យន្តការដាក់ទោសអាចជះឥទ្ធិពលដល់ស្ថិរភាពនៅក្នុងប្រទេស។ ទាក់ទងនឹងឥទ្ធិពលរបស់តុលាការ ប្រជាជននៅប៉ៃលិនបានបង្ហាញទស្សនៈរបស់ខ្លួនថា កម្ពុជាទទួលបានការផ្សះផ្សារួចហើយ។ អ្នកផ្តល់បទសម្ភាសន៍ខ្លះបានអះអាងថាតុលាការជាកាតាលីករមួយដែលជួយជំរុញឲ្យមានការកសាងសន្តិភាព។ ជាក់ស្តែង តារា ជាអតីតកម្មាភិបាលខ្មែរក្រហមបាននិយាយទាក់ទងនឹងអង្គជំនុំជម្រះថា «ដោយធ្វើការកាត់ទោសអ្នកទាំងនេះ យើងដែលជាប្រជាជនកម្ពុជាអាចជួយដល់ការផ្សះផ្សាជាតិនិងធ្វើដំណើរទៅមុខដើម្បីអភិវឌ្ឍន៍ប្រទេស»។ ខណៈពេលដែលទស្សនៈវិជ្ជមានចំពោះតុលាការពឹងផ្អែកទៅលើវិសាលភាពនៃការកាត់ទោសដ៏តូចចង្អៀត អង្គជំនុំជម្រះហាក់ដូចជាមិនបានបង្កឲ្យមានសង្រ្គាមដូចដែលបានរំពឹងទុកដោយទ្រឹស្តីអន្តរយុត្តិធម៌បច្ចុប្បន្នទេ។

ទ្រឹស្តីទាំងនេះតែងតែចាត់ទុកប្រទេសក្រោយសង្រ្គាមថាជាសង្គមដែលត្រូវប្រឈមមុខនឹងទុគ្រោះគឺ «ជម្រើសរវាងការផ្សះផ្សានិងយុត្តិធម៌»។ តុលាការជ្រើសរើសឲ្យតម្លៃទៅលើការទទួលខុសត្រូវ។ រីឯគណៈកម្មការស្វែងរកការពិតបោះបង់ការជ្រើសរើសយកយុត្តិធម៌ដើម្បីកសាងសន្តិភាព។ ដើម្បីជាការឆ្លើយតប ប្រជាជននៅប៉ៃលិនមិនគាំទ្រនឹងដំណើរការជ្រើសរើសនេះទេ។ ឡាសកា អតីតពេទ្យខ្មែរក្រហមចាត់ទុកតុលាការថាជាមធ្យោបាយសម្រាប់ «ធានាថាប្រជាជនរស់នៅជាមួយគ្នាដោយសន្តិភាព»។ សម្តីរបស់គាត់បានរារាំងដំណើរការជ្រើសរើសខាងលើ។ សុវណ្ណៈ អតីតកម្មាភិបាលថ្នាក់ខ្ពស់ខ្មែរក្រហមបាននិយាយថា «តុលាការនឹងជួយឲ្យប្រជាជននិយាយរកគ្នា ព្រមទាំងធ្វើឲ្យអ្នកទាំងនោះចេះបំភ្លេចនិងអភ័យទោស»។ ទោះបីជាអ្នកផ្តល់សម្ភាសន៍ជាច្រើនបានសម្តែងនូវអារម្មណ៍ភ័យខ្លាចថា

អន្តរជនិន្នាំជម្រុះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបែរមកកាត់ទោសកម្មាភិបាលថ្នាក់ក្រោមបន្ថែមទៀតក៏ដោយ ក៏អ្នកទាំងនោះមិនបានរិះគន់តុលាការថាបានបង្កើនការមិនពេញចិត្តនៅក្នុងសហគមន៍ ឬបន្សាក់ដំណើរការផ្សះផ្សាទេ ។

អ្វីដែលបានអះអាងដោយ សុវណ្ណៈ កាន់តែមានភាពគួរឲ្យចាប់អារម្មណ៍បើប្រៀបធៀបនឹងប្រតិកម្មរបស់ប្រជាជននៅអ៊ូហ្គាន់ដា ចំពោះគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា ។ ដូចដែលបានរៀបរាប់ខាងលើ គណៈកម្មការស្វែងរកការពិតត្រូវបានចាត់ទុកថាជាយន្តការកសាងសន្តិភាពដែលមានប្រសិទ្ធភាពជាងតុលាការ ។ នៅពេលដែលមានការទទួលស្គាល់ថាបញ្ហាទាក់ទងនឹង «ការពិត» របស់ប្រវត្តិសាស្ត្រមានសក្តានុពលអាចបំបែកប្រជាជន គណៈកម្មការដែលមានយន្តកម្មបែបនេះទំនងជារួមបញ្ចូលគោលដៅនៃការអភ័យទោស ការធ្វើឲ្យមានសន្តិភាព ការរំងាប់កំហឹង និងការយល់ចិត្ត ។ អាហ្វ្រិកខាងត្បូងបានប្រើប្រាស់គំនិតអន្តរកាលថ្មីដោយផ្លាស់ប្តូរការផ្សះផ្សានិងការពិតដោយចំណងមួយដែលបានកែទស្សនៈនៃគោលបំណងរបស់យន្តការបែបនេះរួចទៅហើយ ។ ផ្ទុយទៅវិញ មិនមានតុលាការឧក្រិដ្ឋកម្មសង្គ្រាមណាបានបញ្ចូលពាក្យ «ការផ្សះផ្សា» នៅក្នុងឈ្មោះរបស់ខ្លួនទេ ។ ប៉ុន្តែដោយពិចារណាទៅលើអារម្មណ៍របស់ប្រជាជននៅ អ៊ូហ្គាន់ដា និងប៉ៃលិន យើងប្រហែលជាយល់ថាភាពផ្ទុយគ្នានេះគឺជាការពិត ។ ជាក់ស្តែង អ្នកផ្តល់បទសម្ភាសន៍នៅអ៊ូហ្គាន់ដា បានស្តីបន្ទោសដល់គណៈកម្មការដែលបានធ្វើឲ្យប្រជាជនអាហ្វ្រិកស្បែកសដែលរស់នៅអាហ្វ្រិកខាងត្បូងមិនគាំទ្រ ។ ទោះបីជាគណៈកម្មការនេះមានគោលដៅធ្វើឲ្យមានការទទួលស្គាល់និងការយល់ចិត្តក៏ដោយ ក៏ពាក្យសម្តីរបស់មន្ត្រីនៅអ៊ូហ្គាន់ដា ចូហាន ដែលថាដំណើរការនេះគឺជា «ការវាយប្រហារតែម្ខាង» បានឆ្លុះបញ្ចាំងការមិនពេញចិត្តចំពោះគណៈកម្មស្វែងរកការពិតនិងផ្សះផ្សានេះដែរ ។ ប្រជាជននៅក្នុងស្រុកមួយចំនួនបានចាត់ទុកសវនាការថាជាឧបករណ៍មួយរបស់ជនជាតិអាហ្វ្រិកស្បែកស «ផ្សេងទៀត» សម្រាប់បង្ខំឲ្យសហគមន៍ទាំងមូលធ្វើការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងរបបអាប៉ាថេត ។

បញ្ញត្តិលើកលែងទោសរបស់គណៈកម្មការមិនបានធ្វើឲ្យប្រជាជននៅអ៊ូហ្គាន់ដារំសាយកំហឹងទេ ។ ផ្ទុយទៅវិញ នៅក្នុងក្រសែភ្នែករបស់អ្នកផ្តល់បទសម្ភាសន៍ ការសម្របសម្រួលដោយនិទ្ទណ្ឌភាពគឺមិនសមហេតុផល ហើយមិនមានការគាំទ្រ និងនិយាយថា «ប្រជាជនអាហ្វ្រិកស្បែកសជាមនុស្សដែលបើកឱកាសដល់អ្នកដទៃ» ។ អាស្រ័យហេតុនេះ អតីតទាហាន ហិនរីក យល់ថាប្រជាជនអាហ្វ្រិកស្បែកស ត្រូវបាន «ធ្វើបាបដោយការចោទប្រកាន់» បោះបង់ចោលដោយអាហ្វ្រិកខាងត្បូងថ្មីនិងត្រូវបានដកចេញមិនឲ្យទទួលបានការផ្សះផ្សា ។ ភាពផ្ទុយគ្នារវាងការធ្វើបាបដោយការចោទប្រកាន់និងសុទិដ្ឋិនិយមដែលបង្ហាញដោយប្រជាជននៅប៉ៃលិនបានបង្កើតជាសំណួរមួយចំនួន ។ ហេតុអ្វីបានជាមានការគាំទ្រនៅក្នុងករណីទាំងពីរនេះ? តើកត្តាអ្វីខ្លះដែលចូលរួមកែប្រែទស្សនៈរបស់ប្រជាជននៅក្នុងតំបន់ចំពោះយុត្តិធម៌និងការផ្សះផ្សា? តើបទពិសោធន៍របស់អ្នកដែលធ្លាប់ហៅ ប៉ៃលិននិងអ៊ូហ្គាន់ដា ថាជាផ្ទះបានបង្កឲ្យមានដែនកំណត់នៃគំរូខុសគ្នាពីរដោយរបៀបណា?

ជាថ្មីម្តងទៀត អ្នកផ្តល់បទសម្ភាសន៍បានចង្អុលទៅគោលជំហរសង្គមរបស់អតីតសមាជិករបបនោះថា បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការផ្សះផ្សា រំខានដល់តួនាទី «តាមបែបប្រពៃណី» របស់តុលាការនិងគណៈកម្មាការ ។ ជាឧទាហរណ៍កងទ័ពខ្មែរក្រហមដូចជា ឡាសកា ហាក់ដូចជាពេញចិត្តនឹងអន្តរកម្មក្រោយជម្លោះរបស់កម្ពុជាដែលបានភ្ជាប់ជ័យជម្នះនៃកិច្ចខំប្រឹងប្រែងកសាងសន្តិភាពដើម្បីឲ្យមេដឹកនាំខ្មែរក្រហមចុះចូលជាមួយរដ្ឋាភិបាលថ្មី ។ ដោយលើកឡើងពីតួនាទីសំខាន់របស់កម្មាភិបាលជាច្រើនដែលនៅសាលាខេត្តប៉ៃលិន និងរដ្ឋបាលជាតិ ប៊ុនថនកម្មាភិបាលថ្នាក់លើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើកំណត់សម្គាល់ថា «ដោយមានកម្មាភិបាលខ្មែរក្រហមនៅក្នុងរដ្ឋាភិបាល បច្ចុប្បន្នយើងទាំងអស់គ្នាចង់រស់នៅក្នុងសន្តិភាពដើម្បីជួយអភិវឌ្ឍន៍ប្រទេសក្នុងពេលអនាគត» ។ ស្រដៀងគ្នានេះដែរ ទាហានខ្មែរក្រហម ទេរិទ្ធ បាននិយាយថា «ខ្ញុំមានអារម្មណ៍ថាខ្ញុំគឺជាផ្នែកមួយនៅក្នុងសង្គមចាប់តាំងពីមានការចុះចូលក្នុងរដ្ឋាភិបាល ពីព្រោះខ្ញុំឃើញថាមនុស្សជាច្រើនដែលធ្លាប់ធ្វើជាកម្មាភិបាលខ្មែរក្រហមដូចជាខ្ញុំបច្ចុប្បន្នបានរួបរួមជាមួយរដ្ឋាភិបាល ហើយយើងអាចធ្វើការជាផ្លូវមួយ» ។ តាមទស្សនៈរបស់អ្នកផ្តល់បទសម្ភាសន៍

អំណាចរបស់ ម៉ែន សំអន និង ជា ស៊ីម ដែលនៅកម្ពុជាបានជួយសម្របសម្រួលដល់ការផ្សះផ្សា និងបានលុបបំបាត់ការមិនទុកចិត្តសង្គម ។ ជាងនេះទៅទៀត ប្រជាជនប៉ៃលិនមួយចំនួនបានទទួលស្គាល់ការងាររបស់រដ្ឋាភិបាលបន្ទាប់ពីមានការបង្រួបបង្រួមគ្នាថាជាកត្តាដ៏សំខាន់ដើម្បីការពារកុំឲ្យមានបទពិសោធន៍ដូចដែលបានកើតឡើងចំពោះប្រជាជននៅ អ្រូវ៉ាន់ដា ។ ជាឧទាហរណ៍ ទេរិទ្ធ មានការលំបាកទោះបីជាគាត់យល់ថាហេតុផលដែលថាហេតុអ្វីបានជាគាត់មិនត្រូវបានគេរាប់បញ្ចូលនៅក្នុងសង្គមក្រោយរបបខ្មែរក្រហម ។ គាត់បាននិយាយថា «ខ្ញុំបម្រើឲ្យទាហានរដ្ឋាភិបាលទទួលប្រាក់ខែពីរដ្ឋាភិបាល ដូច្នេះខ្ញុំគឺជាផ្នែកមួយនៃសង្គម» ។

ផ្ទុយទៅវិញ ប្រជាជននៅអ្រូវ៉ាន់ដាតែងតែចង្អុលបង្ហាញពីប្រវត្តិសាស្ត្រនៃការបែងចែកពូជសាសន៍របស់អាហ្វ្រិកខាងត្បូងនៅក្នុងគំនិតរិះគន់របស់គណៈកម្មការស្វែងរកការពិត និងផ្សះផ្សា ដោយលើកឡើងពីជម្លោះជាតិសាសន៍ដែលធ្លាប់កើតមាននៅប៉ុន្មានសតវត្សរ៍មុន ដែលជាបញ្ហាធំក្នុងការកែប្រែប្រទេសទៅជាប្រជាជាតិឥន្ទធនូ ។ ដោយមិននិយាយអំពី «បុព្វបុរសទូទៅ» របស់កម្ពុជា អ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានអះអាងថា ក្រុមផ្សេងគ្នានៅអាហ្វ្រិកខាងត្បូងមិនធ្លាប់មានបទពិសោធន៍បែករំលែកជាតិសាសន៍ ឬមានអត្តសញ្ញាណដូចគ្នាទេ ។ អ្នកខ្លះបានរៀបរាប់ពីការរស់នៅរបស់ប្រជាជនអាហ្វ្រិកស្បែកសដំបូងគេ ក្រោយមកជំរុំកណ្តាលរបស់អង់គ្លេស និងការបំបែកបដិវត្តន៍ទស្សវាហកម្ម ដើម្បីបកស្រាយពីការប្រឆាំងបន្តបន្ទាប់គ្នា ។ អ្នកខ្លះទៀតបានលើកឡើងពីកិច្ចខំប្រឹងប្រែងរបស់ប្រជាជនអាហ្វ្រិកស្បែកសកាលពីមុនដែលព្យាយាមចង់បង្កើតភូមិកំណើតមួយដាច់ពីគេ ដោយអះអាងថា បញ្ហាដែលមិនមានការពេញចិត្តពីសង្គមមិនមែនកើតមានដោយសកម្មភាពរបស់រដ្ឋាភិបាលអាប៉ាថាយបច្ចុប្បន្ន ។ អាស្រ័យហេតុនេះ ការខ្វះខាតភ័ស្តុតាងដើម្បីបញ្ជាក់ថាប្រទេសបានរួបរួមគ្នា អ្នកផ្តល់បទសម្ភាសន៍មិនសូវជឿលើអំណាចដោះស្រាយរបស់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាទេ ។ ខណៈពេលដែល ដារ៉ា ដែលជាប្រជាជនប៉ៃលិនបាននិយាយទៅកាន់សមាជិកខ្មែរក្រហមថា «យើងមិននៅម្នាក់ឯងទេ» ការបែកបាក់គ្នានិងការធ្វើមិនឲ្យមានសារសំខាន់គឺជាធាតុដែលស្ថិតនៅក្នុងទស្សនៈរបស់ប្រជាជនអាហ្វ្រិកស្បែកស ។ តាមរយៈភាពខុសគ្នារវាងការអះអាងរបស់ ដារ៉ា និងទស្សនៈរបស់ប្រជាជន នៅអ្រូវ៉ាន់ដាស្តីអំពីការផ្សះផ្សា គន្លងនៃការវិវត្តនយោបាយរបស់សង្គមបានផ្លាស់ប្តូរទស្សនៈរបស់ប្រជាជនក្នុងស្រុកចំពោះការស្តាបនាប្រទេសឡើងវិញក្រោយពីមានជម្លោះ ។ យើងមិនអាចបង្កើតសេចក្តីណែនាំជាសាកលសម្រាប់ណែនាំប្រទេសនីមួយៗឲ្យប្រឈមមុខនឹងយន្តការអន្តរកាលទេ ។ បទពិសោធន៍ផ្ទុយគ្នារវាង អ្រូវ៉ាន់ដា និង ប៉ៃលិន បានគាំទ្រគំនិតនេះ ដែលធ្វើឲ្យមានការយល់ដឹងអំពីយុត្តិធម៌ និងការផ្សះផ្សា ។

ទស្សនៈរបស់អ្នកផ្តល់បទសម្ភាសន៍ទៅលើ «រឿងរ៉ាវ» ដែលលើកឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាកាន់តែបង្ហាញឲ្យឃើញពីកំហុសក្នុងការបកស្រាយពន្យល់អំពីយុត្តិធម៌អន្តរកាល ។ ការបកស្រាយពន្យល់ផ្សេងគ្នាអំពីរឿងរ៉ាវប្រវត្តិសាស្ត្របានឆ្លុះបញ្ចាំងពីបញ្ហាដែលមានជាប់ពាក់ព័ន្ធនឹងការកំណត់ព្រំដែននៃយុត្តិធម៌សម្រាប់ការកាត់ទោស ។ ប៉ុន្មានឆ្នាំថ្មីៗនេះ បញ្ញវន្តមួយចំនួនបានបង្កើតគំរូសម្រាប់ការទទួលខុសត្រូវដែលហួសពីគំរូយុត្តិធម៌អន្តរកាល ។ យុត្តិធម៌តាមរយៈការផ្សះផ្សាក្រៅតុលាការគឺជាគំរូមួយដែលបានលើកឡើង និងជាពាក្យមួយដែល «ភ្ជាប់ជាមួយចលនាវីកលូតលាស់នៃសង្គមដែលធ្វើឲ្យយុត្តិសាស្ត្រសន្តិភាពជួបប្រទះនឹងការខូចខាត ព្រមទាំងការរំលោភលើច្បាប់និងសិទ្ធិមនុស្ស» ។ យុត្តិសាស្ត្រសន្តិភាពប្រភេទនេះបានដាក់បន្ទុកទៅលើការកសាងឡើងវិញនូវទំនាក់ទំនង និងសង្គមដែលបានបាក់បែកដែលតម្រូវឲ្យមានការចូលរួមពីជនរងគ្រោះនិងជនដៃដល់ដើម្បីជាប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល ។ គណៈកម្មការស្វែងរកការពិត ការបង់ថ្លៃសំណង សេវាសង្គម ការជួសជុលសាលារៀន ការសុំខមាទោសដោយជនដៃដល់និងអ្វីផ្សេងៗទៀតស្ថិតនៅក្នុងយុត្តិសាស្ត្រផ្សះផ្សាក្រៅតុលាការ ។ ដើម្បីជាការឆ្លើយតបនឹងការអនុវត្តទាំងនេះ បញ្ញវន្តមួយចំនួនបានអះអាងថា យុត្តិសាស្ត្រផ្សះផ្សាក្រៅតុលាការតំណាងឲ្យទម្រង់យុត្តិធម៌តិចតួចប៉ុណ្ណោះ ហើយវាគឺជាទម្រង់ជំនួសដ៏តូចមួយនៅក្នុងការដាក់ទោសតាមផ្លូវតុលាការ ។

ប៉ុន្តែ ពាក្យសម្តីរបស់ប្រជាជននៅ អ្រូវ៉ាន់ដា និងប៉ៃលិន បាន

ធ្វើឲ្យយុត្តិធម៌កាន់តែមានភាពស្មុគស្មាញ ។ ដោយប្រឈមមុខនឹងកិច្ចការមនោគមន៍វិជ្ជាដ៏តូចចង្អៀត ប្រជាជនដែលនៅតំបន់ទាំងពីរអាចដើរតួនាទីជាភ័ស្តុតាងផ្សេងៗគ្នាដែលធ្វើឲ្យការទទួលខុសត្រូវលេចឡើង ។ ដូចដែលបានរៀបរាប់ខាងលើ គោលដៅចម្បងរបស់តុលាការខ្មែរក្រហមក្រោមការដាក់ទណ្ឌកម្មសង្គ្រាមគឺធ្វើការចោទប្រកាន់ «ជនដៃដល់» នៃជម្លោះនិងបង្កើតគំរូច្បាប់មួយសម្រាប់អនាគត ។ ចំពោះទស្សនៈរយៈពេលយូរ យន្តការទទួលខុសត្រូវដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរួមបញ្ចូលនិងដោះស្រាយបញ្ហានិទណ្ឌភាពដែលធ្លាប់មានពីមុននិងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃជម្លោះតាមរយៈការដាក់ទោសដោយតុលាការ ។ អាស្រ័យហេតុនេះ តុលាការផ្តោតទៅលើករណីជាក់លាក់ចំពោះការកាត់ទោសដោយបន្សល់ទុកនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏ទូលំទូលាយដល់ផ្នែកផ្សេងទៀតនៅក្នុងសង្គម ។ ផ្ទុយទៅវិញ គណៈកម្មការស្វែងរកការពិតតែងតែកំណត់គោលដៅចម្បងរបស់ខ្លួនថាជាការបង្កើតព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់លាក់ណាមួយ ដោយធ្វើការបែងចែកការទទួលខុសត្រូវចំពោះការសម្លាប់មនុស្សបង្ហាញពីភាពមិនពិតនៃជំនឿដែលនៅសល់បកស្រាយពន្យល់ពីដើមហេតុនៃជម្លោះ កត់ត្រារឿងរ៉ាវចម្រូងចម្រាស និងអ្វីផ្សេងៗទៀត ។ ការធ្វើកំណត់សម្គាល់របស់អ្នកផ្តល់បទសម្ភាសន៍បានផ្តល់ជាពន្លឺដ៏សំខាន់ក្នុងការដាក់ឲ្យជនដៃដល់ធ្វើការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ។ ខណៈពេលដែលគំរូយុត្តិធម៌តាមរយៈការផ្សះផ្សាក្រៅតុលាការបានរួមបញ្ចូលការស្វែរការពិត បទពិសោធន៍របស់ប្រជាជននៅប៉ៃលិន និងអូរ៉ាំងនា បានបង្ហាញថា ព្រឹត្តិការណ៍ប្រវត្តិ-សាស្ត្រគួរតែដើរមុខគេ ។

ដោយនិយាយពីកម្ពុជា ប្រជាជននៅប៉ៃលិនបាននិយាយពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយឥរិយាបថធម្មតាហាក់ដូចជាមិនរងឥទ្ធិពលដោយដំណើរការនីតិវិធីដែលកំពុងដំណើរការឡើយ ។ អតីតកម្មាភិបាលខ្មែរក្រហមមិនបានដឹងពីសាលក្រមរបស់តុលាការទាក់ទងនឹងសកម្មភាពនៅក្នុងរបបទេ ។ ផ្ទុយទៅវិញ អ្នកផ្តល់បទសម្ភាសន៍បានបកស្រាយពីដំណើរការរបស់តុលាការយ៉ាងខ្លី ដោយផ្តោតតែទៅលើការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ទាំងប្រាំរូប ។ ជាឧទាហរណ៍ ដារ៉ា បាននិយាយថា «ប្រទេសមួយត្រូវតែមានតុលាការដើម្បីអនុវត្តច្បាប់ ។ តុលាការអាចស្រាវជ្រាវដឹងថា ជនណាមានទោស ជនណាគ្មានទោស ព្រមទាំងរកឃើញថាអ្នកណាប្រព្រឹត្តកំហុស និងធ្វើអំពើអាក្រក់ទេ» ។ ចំពោះសម្តីនេះ ដារ៉ា បានចាត់ទុកតុលាការថាជាយន្តការតែមួយដែលមានជាប់ពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់ និងមិនមានទំនាក់ទំនងនឹងដំណើរការនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រឡើយ ។ សុវណ្ណៈ ក៏និយាយស្រដៀងគ្នាថា «ខ្ញុំមិនគិតថា តុលាការនឹងនិយាយថាខ្ញុំជាមនុស្សល្អឬអាក្រក់ទេ ។ តុលាការមិនដែលនិយាយដូច្នោះឡើយ ឬចាត់ទុកក្រុមរបស់យើងថាជាក្រុមអាក្រក់មួយនោះទេ» ។ ដោយពិចារណាទៅលើពាក្យសម្តីនេះ អ្នកផ្តល់បទសម្ភាសន៍មិនជឿថាតុលាការនឹងកាត់ទោសទៅលើតួនាទីជាបុគ្គលរបស់អ្នកទាំងនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។

គណៈកម្មការផ្សះផ្សា និងស្វែងរកការពិត បានផ្តោតទៅលើ «ការស៊ើបអង្កេតនិងការបង្កើតជារូបភាពពេលលេញមួយ មូលហេតុនិងការរាលដាលនៃការរំលោភសិទ្ធមនុស្ស» ដោយស្វែងរកថា អ្នកដែលត្រូវទទួលស្គាល់ចំពោះប្រព័ន្ធអាប៉ាថេត និងទឹកន្លែងដែលរចនាសម្ព័ន្ធនយោបាយមិនស្មើភាពគ្នាកើតមានដំបូង ។ ដោយដឹងពីវិសាលភាពនៃគោលដៅរបស់គណៈកម្មការ ប្រជាជននៅអូរ៉ាំងនាយល់ថា សវនាការគឺជាការប្រឆាំងនឹងសហគមន៍អាហ្វ្រិកស្បែកស ។ នៅពេលជាមួយគ្នានេះ វីលហេម បានអះអាងថា សកម្មភាពរបស់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាបានបំផ្លាញដល់ទឹកចិត្តរបស់ប្រជាជនអាហ្វ្រិកស្បែកស ។ នៅក្នុងទស្សនៈរបស់លោក គណៈកម្មការត្រូវបាន «ប្រើប្រាស់ជាឧបករណ៍សម្រាប់បង្ហាញមនុស្សល្អនិងអាក្រក់ បន្ទាប់មកបន្ថែមពីភាពជឿជាក់ទៅលើវា» ។ អ្នកខ្លះយល់ថា ដំណើររបស់គណៈកម្មការគឺជា «ការគំរាមកំហែងដ៏ធំមួយ» និងជា «ការធ្វើឲ្យស្ថានភាពកាន់តែមានភាពស្មុគស្មាញ» ។ ដូចដែលបានបង្ហាញនៅខាងលើ ការមិនយល់ស្របគ្នាទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រអាចប៉ះពាល់ដល់ការផ្សះផ្សារបស់គណៈកម្មការ និងយុត្តិធម៌របស់តុលាការ ។ នៅក្នុងករណីជាក់ស្តែងខ្លះ អតីតសមាជិកនៃរបបអាចនឹងកាន់តែមានការឈឺចាប់ក្នុងការសារភាពប្រាប់រដ្ឋាភិបាលថា ខ្លួនសុខចិត្តទទួលការចោទប្រកាន់ជាជាងឃើញកូនទាហានរបស់ខ្លួនប្រឈម

មុខនឹងការជាប់ពន្ធនាគារ ។ ការបំផ្លិចបំផ្លាញដែលត្រូវបានគេទទួលស្គាល់ជាផ្លូវការ ឬយ៉ាងហោចណាស់ ការរិះគន់ដល់មនោគមន៍វិជ្ជាដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងចិត្តមនុស្សម្នាក់គឺជាការវាយប្រហារ មួយដល់អត្តសញ្ញាណរបស់បុគ្គល ។

ដោយធ្វើការវិភាគទៅលើផលប៉ះពាល់នៃមនោគមន៍វិជ្ជា អ្នកជំនាញការ មីសែល អ៊ីញណាធីហ្វ បានបង្កើតទ្រឹស្តីមួយថា ខណៈពេលដែលគណៈកម្មការកម្រនឹងអាចស្វែងរកការពិតទាំងស្រុង វាក៏អាច «កាត់បន្ថយការការនិយាយលាក់បាំងខ្លះដែរ» ។ គណៈកម្មការផ្សះផ្សានិងស្វែងរកការពិតអាចស្វែងរកការពិតដែលមានការទទួលស្គាល់មួយដោយធ្វើឲ្យប្រទេសអាចមើលឃើញភាពអាក្រក់នៃរបបអាប៉ារថេត ។ ទោះបីជាផ្នែកខ្លះនៃប្រវត្តិសាស្ត្ររបស់អាហ្វ្រិកខាងត្បូងគឺជារឿងវិវាទក៏ដោយ ក៏គណៈកម្មការបានធ្វើឲ្យសាធារណជនទទួលស្គាល់ថា អាប៉ារថេតគឺជាប្រព័ន្ធមួយដែលមិនមានភាពយុត្តិធម៌និងធ្វើឲ្យមានភាពអាម៉ាស់ដែរ ។ ជាក់ស្តែង អ្នកផ្តល់បទសម្ភាសន៍នៅអូវ៉ានាដែលស្អប់ខ្ពើមរបបនោះបែរជាទទួលស្គាល់ «ការពិតដែលមានការទទួលស្គាល់» ដែលបង្កើតឡើងនូវគណៈកម្មការនេះ ។ ជាឧទាហរណ៍ វីលហេម បាននិយាយថា គណៈកម្មការស្វែងរកការពិត និងផ្សះផ្សាបានស្វែងរក «ការពិតដែលនៅខ្សែមូលដ្ឋាន» ខណៈពេលដែល ហង្ស បានចាត់ទុកភ័ស្តុតាងដែលបន្សល់ទុកដោយភាពឃោរឃៅនៃរបប អាប៉ារថេតថាជារឿង «ដែលមិនអាចប្រកែកបាន» ។ អ្នកទាំងនេះសុទ្ធតែអះអាងថា តួនាទីរបស់ប្រជាជនស្បែកខ្មៅនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលគណបក្សជាតិគឺអាក្រក់ដែលមិនអាចប្រកែកបានវាជា «សុបិនអាក្រក់ពិតមួយ» ។ ដោយពិចារណាទៅលើការអង្កេតនេះ វាបង្ហាញយ៉ាងច្បាស់ថាប្រជាជននៅអូវ៉ានាធ្លាប់បានគិតទៅដល់លទ្ធផលនៃរបបនេះ ព្រមទាំងប្រឈមមុខនឹងការពិតនិងរឿងរ៉ាវដែលផ្ទុយពីជំនឿរបស់ខ្លួន ។

លើសពីនេះទៅទៀត តាមរយៈបទសម្ភាសន៍ ប្រជាជនទាំងអស់បានរៀបរាប់ពីរឿងរ៉ាវរបបអាប៉ារថេតថាបានងាករេចេញពីផ្លូវរបស់ខ្លួន ដូចជានៅពេល «រួមបញ្ចូលកម្លាំងពលករស្បែកខ្មៅ» នៅក្នុងទីក្រុងឬនៅអំឡុងពេលស្ថានភាពសន្តិសុខនៅក្នុងទីក្រុងមានការធ្លាក់ចុះជាដើម ។ ទោះបីជាមានអ្នកផ្តល់បទសម្ភាសន៍ខ្លះបាននិយាយពីចំណុចវិជ្ជមានរបស់គណបក្សជាតិ ប៉ុន្តែអ្នកទាំងនោះនៅតែចំណាយពេលជាច្រើនដើម្បីប្រឈមមុខនឹងកេរដំណែលដែលបន្សល់ទុកដោយរបបអាប៉ារថេត ។ ជាឧទាហរណ៍ ហិនរីកដែលមិនអាចបំភ្លេចពីអំពើបាបដែលធ្លាប់កើតមានឡើងបាននិយាយថា «វាពិបាកនឹងយកមកពន្យល់នៅពេលសព្វថ្ងៃនេះណាស់» ។ ហេតុអ្វីបានជាមានការព្យាយាម «បកស្រាយពន្យល់» និងវិភាគទៅលើភាពសាហាវឃោរឃៅនៃរបបអាប៉ារថេត? អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនបាននិយាយថារឿងរ៉ាវនៃរបបអាប៉ារថេតដែលបង្កើតឡើងដោយគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាគឺជាកត្តាមួយដែលជំរុញឲ្យមានប្រតិកម្មចំពោះប្រព័ន្ធគណបក្សជាតិ ។ ជាលទ្ធផលទស្សនៈដែលថាប្រជាជនស្បែកសអាចគេចផុតពីការទទួលទោសដែលជាសេចក្តីព្រមព្រៀងលើកលែងទោសរបស់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានឹងក្លាយជាមានប្រសិទ្ធភាព ប្រសិនបើយើងមិនផ្តោតទៅលើការដាក់ទោសពិត ។ ការមិនគិតទៅដល់សារសំខាន់នៃលទ្ធផលដំបូងរបស់ទស្សនវិជ្ជានិងមនោគមន៍វិជ្ជាគឺជាកំហុសមួយ ។ ជាក់ស្តែង បញ្ញវន្តអាហ្វ្រិក ស្បែកស លីហ្វ វ៉ាន រ៉ូព្រេក បាននិយាយថាគណៈកម្មការបានធ្វើឲ្យ «ប្រជាជនអាហ្វ្រិកស្បែកសមិនអាចនៅស្ងៀមចំពោះភាពគ្មានសីលធម៌របស់អាប៉ារថេត» ទៀតទេ ដូច្នេះវាមានការលំបាកក្នុងការធ្វើឲ្យអ្នកដែលមានជាប់ពាក់ព័ន្ធទទួលស្គាល់ពីអ្វីដែលខ្លួនបានធ្វើ ។ តើការធ្វើឲ្យមានការទទួលដឹងព្រះនេះមិនមែនជាផ្នែកខ្លះដែលធ្វើឲ្យមានយុត្តិធម៌ឬយ៉ាងហោចណាស់គឺជាផ្នែកមួយនៃទណ្ឌកម្មទេឬ?

ម្យ៉ាងវិញទៀត អ្នកផ្តល់បទសម្ភាសន៍នៅប៉ៃលិនហាក់ដូចជាពេញចិត្តនឹងនៅបន្តនៅក្នុងភាពខ្វាងងឹត មិនមានការភ័យខ្លាចអំពីអតីតកាលដ៏អាក្រក់ និងមិនទទួលផលប៉ះពាល់ពីការត្រួតពិនិត្យទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រឡើយ ។ អតីតកម្មាភិបាលសារភាពថា ខ្លួនមិនបានចំណាយពេលវេលាច្រើនគិតទៅដល់របបកម្ពុជាប្រជាធិបតេយ្យទេ ។ ជាក់ស្តែង ទេវិទ្ធ បាននិយាយថា «ខ្ញុំមិនដែលសម្លឹងមើលទៅក្រោយទេ ហើយខ្ញុំក៏មិនដែលគិតពីវាដែរ ។ អ្វីៗទាំងអស់បានបន្តដំណើរទៅមុខ ដូច្នេះយើងមិនចាំបាច់មើលទៅក្រោយទេ» ។ ឡាស្កា ក៏និយាយស្រដៀងគ្នានេះដែរ «ខ្ញុំមិនគិតអំពីវាទេ ។ ខ្ញុំគឺជាពលរដ្ឋល្អម្នាក់» ។ ខុសពីគណៈ

កម្មការស្វែងរកការពិតនិងផ្សះផ្សា ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហាក់ដូចជាមិនបានធ្វើឲ្យអ្នកផ្តល់បទសម្ភាសន៍ពិបាកចិត្តឬធ្វើឲ្យអ្នកទាំងនោះចាប់ផ្តើមវាយតម្លៃទៅលើប្រព័ន្ធដឹកនាំរបស់ខ្មែរក្រហមឡើយ ។ បន្ថែមពីលើនេះទៅទៀត អតីតទាហានខ្លះមិនអាចបដិសេធថារបបនោះបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរទេ ។ ចំពោះករណីនេះ ប៊ុនថន បាននិយាយអំពី «ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា វាមិនខុសទេ វាគឺជាប្រព័ន្ធស្វ័យ័ត» ។ ខ្ញុំមិនឃើញនរណាម្នាក់បាត់បង់ជីវិតទេ...» ។ ដោយបង្ហាញអំពីបញ្ហាជីវភាព និងសេរីភាពក្នុងការផ្លាស់ប្តូរ ប៊ុនថន ជឿថា «ប្រជាជនសុទ្ធតែស្រឡាញ់របបនេះពីព្រោះរបបនោះពិតជាស្អាតស្អំណាស់ ។ របបនោះមិនមានអំពើពុករលួយ ហើយប្រជាជនមានសិទ្ធិរស់នៅស្មើៗគ្នា» ។ ការបង្ហាញថា ខ្មែរក្រហមជារបបល្អបានធ្វើឲ្យមានការភ្ញាក់ផ្អើលនៅក្នុងបទសម្ភាសន៍ ។ លក្ខិណា ក៏ដូចជា ប៊ុនថន ដែរ បានអះអាងថាការដែលនិយាយថាមានការលំបាកវេទនានៅក្នុងរបបនោះគឺជាការនិយាយពន្លើស ពីព្រោះគាត់មិនដែល «ឃើញការសម្លាប់អ្វីឡើយ» ហើយគាត់បានចាត់ទុក ខៀវ សំផន, អៀង សារី និងសមាជិករបស់របបនេះថាជា «មនុស្សធម្មតា និងជាមនុស្សល្អ» ។ នៅពេលដែលសួរថាតើគាត់ធ្វើការប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះដោយរបៀបណា លក្ខិណា បាននិយាយថា «ខ្ញុំមានអារម្មណ៍ធម្មតាពីព្រោះខ្ញុំមិនបានជឿទៅលើអ្វីដែលបានកើតឡើងទេ» ។ ដោយមានហេតុផលដូចគ្នា អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀតបានអះអាងថា ខ្លួននិងមេដឹកនាំខ្មែរក្រហមមិនមានអ្វីត្រូវធ្វើការសុំទោសទេ ។

មុននឹងឈានទៅដល់ការវិភាគឲ្យស៊ីជម្រៅទៅលើបទសម្ភាសន៍ យើងគួរពិចារណាទៅលើការពិតមួយដែលថា អ្នកផ្តល់បទសម្ភាសន៍នៅអូរ៉ាំនាជាអ្នកមានចំណេះដឹងធ្វើឲ្យអ្នកទាំងនោះអាចសង្កត់ធ្ងន់ទៅលើរបបអាប៉ាថេតជាងប្រជាជនកម្ពុជាដែលនិយាយអំពីរបបខ្មែរក្រហម ។ ទស្សនៈខុសគ្នារវាងប្រជាជននៅអូរ៉ាំនា និងប្រជាជននៅប៉ៃលិន បានឆ្លុះបញ្ចាំងពីការពិតដែលថា ប្រជាជនកម្ពុជានិងប្រជាជនអាហ្វ្រិកធ្លាប់ទទួលបានការអប់រំពីប្រព័ន្ធផ្សេងគ្នាដែលធ្វើឲ្យអ្នកទាំងនេះមានទស្សនៈខុសគ្នាទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ទោះបីជាយ៉ាងណាក៏ដោយ ឥទ្ធិពលនៃការអប់រំនេះមិនបានជះឥទ្ធិពលដល់យន្តការយុត្តិធម៌អន្តរកាលដែលអត្ថបទនេះកំពុងតែផ្តោតទៅលើទេ ។ កត្តាដែលបានពិភាក្សាខាងលើបានបង្កើតជាបរិយាកាសសង្គមនិងនយោបាយដែលធ្វើឲ្យសមាជិកខ្មែរក្រហមមិនមានការសោកស្តាយ ។ អាស្រ័យហេតុនេះ ហេតុផលខ្លះដែលបណ្តាលឲ្យអ្នកផ្តល់បទសម្ភាសន៍នៅប៉ៃលិននិយាយដោយមិនដាក់បន្ទុកលើខ្លួនឯងប្រហែលជាដោយសារតែអវត្តមានដំណើរការដែលស្រដៀងទៅនឹងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាដែលជាយន្តការសាធារណៈអាចជាទម្រង់គណៈកម្មការ កម្មវិធីអប់រំប្រវត្តិសាស្ត្រនៅសាលារៀន ឬជាគំនិតផ្តួចផ្តើមមិនផ្លូវការមួយ ដែលមានគោលដៅធ្វើឲ្យមានការទទួលស្គាល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និង «កាត់បន្ថយការនិយាយលាក់បាំង» ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់គោលដៅដ៏គួរឲ្យកោតសរសើរមួយសម្រាប់ខ្លួនឯង ដូចជាការកាត់បន្ថយនិទ្ទណ្ឌភាព ការរួមបញ្ចូលសំឡេងរបស់ជនរងគ្រោះការបង្កើតគំរូមួយសម្រាប់អនាគត ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្វីជាច្រើនទៀត ។ អត្ថបទនេះនឹងមិននិយាយអំពីសមិទ្ធផលរបស់តុលាការឬអះអាងថាអរូបិយប្រសើរជាងរូបិយនោះទេ ។ ប៉ុន្តែទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលបានជោគជ័យទៅលើផ្នែកនេះក៏ដោយ ក៏អង្គជំនុំជម្រះមិនទាន់បានចេញសាលក្រមជាផ្លូវការដើម្បីកាត់ទោសរបបនេះដែលបណ្តាលឲ្យអ្នកផ្តល់បទសម្ភាសន៍នៅប៉ៃលិននៅតែបន្តរស់នៅ «ដោយមិនដឹងពីការពិត» ដែលផ្ទុយពីប្រជាជននៅអូរ៉ាំនាទេ ។ វាជាសេរីភាពដែលមិនគួរទទួលបានបើប្រៀបធៀបទៅនឹងទម្រង់និទ្ទណ្ឌភាពដែលមានការទទួលស្គាល់ ។ អ្វីដែលបានអះអាងដោយអតីតខ្មែរក្រហមដូចគ្នាទៅនឹងប្រជាជននៅអូរ៉ាំនា អ្នកទាំងនេះសុទ្ធតែទាមទារឲ្យមានការពិភាក្សាទទួលស្គាល់ព្រឹត្តិការណ៍ប្រវត្តិ-សាស្ត្រពីព្រោះវាជាទម្រង់នៃការទទួលខុសត្រូវមួយ ។ ជាងនេះទៅទៀត ជាមួយនឹងបញ្ហាដែលបណ្តាលឲ្យមានការបង្កើតសម្ព័ន្ធភាពរវាងគណៈកម្មការស្វែងរកការពិត និងការផ្សះផ្សា បទពិសោធន៍របស់ប្រជាជននៅអូរ៉ាំនាបង្ហាញពីបញ្ហាយុត្តិធម៌នៅតុលាការ ។

បទសម្ភាសន៍នៅអូរ៉ាំនា និងប៉ៃលិនបានបង្ហាញថា សង្គម

*ក្រោយជម្លោះគួរតែប្រើប្រាស់យុត្តិសាស្ត្រចម្រុះដើម្បីឆ្ពោះទៅកាន់យុត្តិធម៌អន្តរកាលដោយអនុវត្តន៍នូវយន្តការផ្សេងៗជាច្រើនទាំងផ្លូវការនិងមិនផ្លូវការ ។ ដើម្បីអនុវត្តការងារបំពេញគ្នាទៅវិញទៅមក ប្រទេសដែលស្ថិតនៅក្នុងស្ថានភាពអន្តរកាលដ៏លំបាកត្រូវតែធានាថាខ្លួនបានដោះស្រាយបញ្ហាពីចំណុចដ៏មានប្រសិទ្ធភាព ។ ប្រសិនបើកម្ពុជាសម្រេចជ្រើសរើសប្រើប្រាស់តុលាការកម្ពុជា វាប្រហែលជាមិនគិតពីការជះឥទ្ធិពលទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទេ ។ ប៉ុន្តែ ជាមួយនឹងសៀវភៅអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងយុត្តិសាស្ត្រនៃការប្រាប់ដែលអាចនឹងកើតមានឡើងប្រជាជនកម្ពុជាបានឈានជំហានដ៏សំខាន់ឆ្ពោះទៅកាន់ការធ្វើឲ្យប្រទេសប្រសើរឡើងវិញ ។ យុត្តិសាស្ត្រផ្សេងៗគ្នានេះតម្រូវឲ្យមានទស្សនៈយុត្តិធម៌និងការផ្សះផ្សាធំទូលាយជាងមុនដែលអាចធ្វើឲ្យមានលទ្ធផលល្អ ហើយអាចធ្វើឲ្យមានការពិនិត្យយ៉ាងគ្រប់ជ្រុងជ្រោយទៅលើបញ្ហានេះ ។*

*នៅពេលដែលលទ្ធផលចេញជាផ្លែផ្កា ប្រជាជននៅអ៊ូហ្គង់ដា និងប៉េរូ ប្រហែលជានឹងមិនយល់ច្បាស់ពីវាទេ ។ ប៉ុន្តែ ប្រសិនបើប្រទេសណាមួយប្រកាន់ភ្ជាប់នូវគំរូសាកល វាពិតជាធ្វើឲ្យមានការភ្ញាក់ផ្អើលមួយដែលថា គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាបានធ្វើឲ្យប្រជាជនអាហ្វ្រិកមានការខឹងសម្បារ ។ នេះជាការភ្ញាក់ផ្អើលមួយដែលថា ខណៈពេលដែលគណៈកម្មការអាចសម្រេចបានយុត្តិធម៌ខ្លះតាមរយៈការប្រាប់ពីប្រវត្តិសាស្ត្រ ប៉ុន្តែ វាមិនបានធ្វើឲ្យមានកម្រិតនៃផ្សះផ្សាកើនខ្ពស់នៅក្នុងអ៊ូហ្គង់ដាទេ ។ ទោះបីជាពីមុនមានការសន្និដ្ឋានថា តុលាការនឹងបំបែកអាហ្វ្រិកខាងត្បូង ព្រមទាំងបំផ្លាញដល់ដំណើរការកសាងសន្តិភាពក៏ដោយ ក៏យន្តការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចបន្ថយការកំហឹងនិងការមិនជឿជាក់របស់ប្រជាជនដែរ ។ ចំពោះករណីនៅកម្ពុជា វាក៏មានការភ្ញាក់ផ្អើលមួយដែលថា អង្គជំនុំជម្រះមិនទាន់បានធ្វើឲ្យអ្នកនៅប៉ៃលិនមានការមិនពេញចិត្ត ។ ការអះអាងរបស់ទាហានបង្ហាញថា ទោះបីជាមិនទាន់មានការដាក់ទោសតាមច្បាប់គ្រប់គ្រាន់ ក៏ប៉ុន្តែយន្តការស្វែងរកការពិតក៏អាចនឹងបង្កើតជាទម្រង់នៃការដាក់ទណ្ឌកម្មទៅលើអតីតកម្មាភិបាលដ៏មានន័យដែរ ។ នៅក្នុងបរិបទនៃអន្តរកាល លទ្ធផលដែល «មិនបានរំពឹងទុក» បេះតែមានជាបន្តបន្ទាប់ដែលអាចធ្វើឲ្យមានឥទ្ធិពលដល់អ៊ូហ្គង់ដា ក៏ដូចជាប៉ៃលិន ។*

*ហេតុអ្វីបានជាមានលទ្ធផលមិនប្រក្រតីទាំងនេះ? ហេតុអ្វីបានជាការសិក្សានៅអ៊ូហ្គង់ដា និងប៉ៃលិនខុសពីគំរូដែលមានបទដ្ឋាន? ចម្លើយគឺថា យុត្តិធម៌និងការផ្សះផ្សាមិនអាចត្រូវបានយកមកបង្កើតជាក្រុមដាក់លាក់ផ្សេងៗគ្នាបានទេ ។ ធាតុទាំងពីរតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយនៅពេលដែលមានកិច្ចខំប្រឹងប្រែងដើម្បីបង្កើតអ្វីមួយ ធាតុទាំងពីរនេះតែងតែរួមបញ្ចូលគ្នាដែលមិនអាចធ្វើឲ្យយើងបែងចែកបាន ។ អាស្រ័យហេតុនេះនៅពេលវាយតម្លៃទៅលើយុត្តិធម៌និងការផ្សះផ្សា ព្រមទាំងទំនាក់ទំនងនៃយន្តការយុត្តិធម៌អន្តរកាលផ្សេងទៀត យើងមិនអាចបែងចែកវាជាក្រុមបានទេដែលប្រៀបដូចជាយករឿងពីរផ្ទុយគ្នាទៅដាក់បញ្ចូលគ្នា ។ ជាសរុបសេចក្ដីមក ខ្ញុំចង់វិលទៅនិយាយអំពីដំណើរការ «ដែលស្រពេចស្រពិល» ។ ដោយធ្វើការប្រមើមើលទៅលើលទ្ធផលនៃសៀវភៅប្រវត្តិសាស្ត្រថ្មីរបស់កម្ពុជាដែលមានចំណងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» យើងឃើញថាការបង្កើនការអប់រំពីអំពើប្រល័យពូជសាសន៍នឹងនាំមកនូវយុត្តិធម៌ និង «កាត់បន្ថយការនិយាយលាក់បាំងខ្លះ» ។ ដោយដើរទៅតាមខ្សែសង្វាក់នៃលទ្ធផលដែលអាចកើតមាននៅពេលខាងមុខ កិច្ចខំប្រឹងប្រែងនេះអាចផ្ដល់ជាការផ្សះផ្សានិងការផ្សព្វផ្សាយ «មេរៀនប្រវត្តិសាស្ត្រ» ដែលជាគ្រាប់ពូជនៃសន្តិភាព ។ មេរៀនទាំងនេះអាចត្រូវបានចាត់ទុកថាជាទម្រង់យុត្តិធម៌មួយសម្រាប់ជនរងគ្រោះ វាអាចជួយធានាថាអតីតកាលនឹងមិនកើតមានម្ដងទៀត ហើយនឹងមិនមានប្រជាជនកម្ពុជាណាមួយធ្វើអំពើហិង្សាទៅលើប្រជាជនកម្ពុជាគ្នាឯងទៀតទេ ។ ការដោះស្រាយភាពមិនច្បាស់លាស់នៃគំនិតនេះជាការងារដ៏លំបាកមួយ ។ ប៉ុន្តែ ប្រសិនបើប្រទេសក្រោយជម្លោះចង់ដើរទៅមុខចេញពីអតីតកាលដ៏ច្របូកច្របល់ ប្រទេសទាំងនេះចាំបាច់ត្រូវតែឈប់ឆ្លើយចម្លើយដែលងាយទៀត ។ រឿងរ៉ាវរបស់ប្រជាជននៅអ៊ូហ្គង់ដា និងប៉ៃលិន បានកាត់បន្ថយភាពសាមញ្ញមួយចំនួនដែលធ្វើឲ្យយើងឆ្ពោះទៅមុខគឺថាអតីតកាល មិនមែនជាអតីតកាលទេ ហើយអ្វីៗទាំងអស់មិនតែងតែកើតឡើងដូចការគិតទេ ។* **ខាល ដែលបឹក**

# ជីវិតគ្រួសារខ្ញុំក្នុងរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ ញ៉ិល សល្យ កើតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ នៅភូមិរកា ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។ ឪពុករបស់ខ្ញុំឈ្មោះ ហែល ញ៉ិល បច្ចុប្បន្នរស់នៅស្រុកពារាំង ខេត្តព្រៃវែង។ ម្តាយរបស់ខ្ញុំឈ្មោះ សុខ ភ្លាញ ស្លាប់នៅឆ្នាំ១៩៩៣ដោយសារជំងឺ ។ ខ្ញុំមានបងប្អូនបង្កើតចំនួនប្រាំពីរនាក់ (ប្រុស៥នាក់ និងស្រី២នាក់) ។

កាលពីឆ្នាំ១៩៧៥ ពេលដែលឪពុកម្តាយរបស់ខ្ញុំជាអាជីវករលក់ដូរនៅផ្សារស្វាយពល ក្នុងភូមិស្វាយពល ខេត្តព្រៃវែង គាត់ត្រូវរត់គេចខ្លួនជាញឹកញាប់ដោយសារការទម្លាក់គ្រាប់បែករបស់កងទ័ពអាមេរិកាំងដើម្បីកម្ទេចជំរំចលនាដែលប្រឆាំងនឹងរដ្ឋាភិបាលលោកសេនាប្រមុខ លន់ នល់ ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលកងទ័ពខ្មែរក្រហមបានចូលមកកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង គ្រួសាររបស់ខ្ញុំមិនទាន់ត្រូវបានជម្លៀសចេញពីភូមិទេ ។ លុះដល់ឆ្នាំ១៩៧៦ ទើបគ្រួសាររបស់ខ្ញុំក៏ដូចជាគ្រួសារដទៃទៀតត្រូវបានជម្លៀសទៅភូមិរកា ដែលមានចម្ងាយប្រហែលបីគីឡូម៉ែត្រពីភូមិស្វាយពល ។

នៅទីនោះ ខ្មែរក្រហមបានប្រគល់ផ្ទះគំរូពីរខ្នងដែលបានសង់ទុកសម្រាប់ប្រជាជនថ្មីដែលទើបជម្លៀសមកពីទីក្រុងឲ្យស្នាក់នៅសិន ដោយមួយគ្រួសារទទួលបានផ្ទះមួយខ្នង ។ បន្ទាប់មក គ្រួសាររបសខ្ញុំត្រូវបានអង្គការបំបែកឲ្យទៅធ្វើការនិងរស់នៅតំបន់ឆ្ងាយៗពីគ្នា ។ ខ្មែរក្រហមបានបញ្ជូនឪពុករបស់ខ្ញុំទៅធ្វើការនៅវាលស្រែដែលមានចម្ងាយប្រហែល២០ម៉ែត្រពីកន្លែងរស់នៅ ដោយត្រូវធ្វើការចាប់ពីព្រលឹមរហូត ដល់ល្ងាចនិងទទួលរបបអាហារបន្តិចបន្តួចប៉ុណ្ណោះ ។ ដោយភាពស្រេកឃ្លានខ្លាំងពេក ឪពុករបស់ខ្ញុំបានដើរលួចចាប់ក្តាមនិងកូនក្អុកយកមកស្ងោរហូបបន្ថែមទៀត ។ តែជាអកុសល ឪពុករបស់ខ្ញុំស្រាប់តែត្រូវកងសន្តិសុខខ្មែរក្រហមចាប់បាន រួចនាំគាត់ទៅអប់រំរយៈពេលបីយប់បួនថ្ងៃទើបដោះលែងឲ្យមានសេរីភាពវិញ ។ ចាប់ពីពេលនោះមក ឪពុករបស់ខ្ញុំលែងហ៊ានលួចរបស់របរអង្គការទៀតហើយ ដោយសុខចិត្តធ្វើការទាំងហេវហត់ ។



ញ៉ិល សល្យ អំឡុងពេលចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចំណែកម្តាយរបស់ខ្ញុំវិញ បន្ទាប់ពីខ្មែរក្រហមជម្លៀសទៅដល់ភូមិរកា គាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើជាប្រធានរោងបាយក្នុងសហករណ៍៤ ដែលជាកន្លែងរស់នៅថ្មី។ នៅទីនេះ ម្តាយរបស់ខ្ញុំក៏ធ្វើការចាប់ពីព្រលឹមដល់ព្រលប់ទើបត្រឡប់មកកងដូចឪពុករបស់ខ្ញុំដែរ ។ ប៉ុន្តែគាត់មិនសូវទទួលរងការវាយលំបាកប៉ុន្មានទេ ដោយសារតែឪពុកមាបង្កើតរបស់គាត់មានតួនាទីជាប្រធានឃុំនៅទីនោះ ។ ចំណែករបបអាហារវិញ ម្តាយ

របស់ខ្ញុំទទួលបានរបបហូបចុកគ្រប់គ្រាន់ ។

បងស្រី និងបងប្រុសរបស់ខ្ញុំដែលមានអាយុពេញវ័យត្រូវចាត់តាំងឲ្យចូលរួមក្នុងកងចល័ត លើកទំនប់ទន្លេតូចដែលស្ថិតនៅក្នុងភូមិព្រៃកចំប៉ា ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង ចម្ងាយប្រហែល១៥គីឡូម៉ែត្រពីកន្លែងស្នាក់នៅ ។ នៅទីនោះគាត់ទាំងពីរនាក់ត្រូវបានបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរបំផុត ដូចជាលីសែង កាប់គាស់តាំងពីព្រឹក រហូតដល់កណ្តាលអធ្រាត្រ រហូតដល់ធ្លាក់ខ្លួនឈឺ ។ ចំណែកអាហារវិញ មិនដែលហូបគ្រប់គ្រាន់ទេ ។ ដូច្នេះហើយ ក្រោយពីសម្រាកការងារ គាត់ទាំងពីរនាក់តែងតែទៅលួចគាស់ដំឡូងហូបជានិច្ច រួចយកមើមដំឡូងខ្លះមកចងវេចនឹងក្រមាដើរសំដៅមកផ្ទះ ។ ថ្ងៃមួយ ខ្មែរក្រហមបានមកទាន់ រួចវាយគាត់ទាំងពីរយ៉ាងដំណំ ហើយបញ្ជូនទៅដាក់នៅក្នុងមន្ទីរឃុំឃាំងរយៈពេល៥ថ្ងៃដើម្បីធ្វើការអប់រំ ។ នៅទីនោះ គាត់ត្រូវខ្មែរក្រហមធ្វើទារុណកម្មជាខ្លាំង ហើយថែមទាំងបង្អត់បាយទៀត ។ ដោយសារតែជាកំហុសលើកដំបូង អង្គការក៏ដោះលែងវិញ ប៉ុន្តែត្រូវបង្ខំឲ្យធ្វើការធ្ងន់ជាងមុន ដើម្បីជាការព្រមានដល់អ្នកផ្សេងទៀតកុំឲ្យយកគំរូតាម ។ ការងារទាំងនេះពិតជាពិបាកខ្លាំងណាស់ រហូតដល់បងស្រីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ធ្ងរ ។ ដោយសារតែព្រួយបារម្ភខ្លាំងពេក ម្តាយរបស់ខ្ញុំក៏បានសុំការអនុញ្ញាតមកមើលថែទាំកូន រហូតដល់ជាសះស្បើយពីជំងឺ ទើបត្រឡប់ទៅកងវិញ ។

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ គ្រួសាររបស់ខ្ញុំដែលមានឪពុកម្តាយ បងប្រុស និង បងស្រី ព្រមទាំងអ៊ំស្រីរបស់ខ្ញុំបានវិលត្រឡប់មករស់នៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែងវិញ ។

ទោះបីក្រុមគ្រួសាររបស់ខ្ញុំមិនមាននរណាម្នាក់បាត់បង់ជីវិតក៏ដោយ តែរបបនេះពិតជាសាហាវ ព្រៃផ្សៃណាស់ ដោយបានសម្លាប់ប្រជាជនអស់ជិតពីរលាននាក់ ។ ដូច្នេះ ក្នុងនាមខ្ញុំជាអ្នកអប់រំប្រវត្តិសាស្ត្រម្នាក់ ខ្ញុំនឹងខិតខំធ្វើយ៉ាងណាអប់រំសិស្សានុសិស្ស និងនិស្សិតទាំងអស់ឲ្យយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ដោយឈរលើគោលការណ៍បង្រួបបង្រួមជាតិ ការផ្សះផ្សាជាតិ និងការអភិវឌ្ឍ ដើម្បីកសាងប្រទេសជាតិឲ្យមានការរីកចម្រើនដូចបណ្តាប្រទេសនានាលើពិភពលោក និងធ្វើយ៉ាងណាការពារទប់ស្កាត់មិនឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ។

**ញ៉ិល សល្យ**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញា ចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការ ព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។

**សូមអរគុណ**

# ការអត់ឱនទោសជាការពិបាកណាស់សម្រាប់ វក ទី

វក ទី ជាស្ត្រីជនជាតិចាមដែលកំពុងរស់នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ឥឡូវនេះ វក ទី មានអាយុ៤៥ឆ្នាំ ហើយនៅពេលខ្មែរក្រហមបានគ្រប់គ្រងស្រុកកំពង់ត្រឡាចនៅឆ្នាំ ១៩៧៥ វក ទី ទើបតែមានអាយុ១៥ឆ្នាំប៉ុណ្ណោះ ។ វក ទី មាននិយាយដោយប្រយ័ត្នប្រយែងថា គាត់មិនបានចាំព្រឹត្តិការណ៍ដែលបានកើតឡើងមុនរបប លន់ នល់ ទេ ហើយគាត់អាចរៀបរាប់ប្រាប់ពីព្រឹត្តិការណ៍ដែលកើតឡើងនៅភូមិរបស់គាត់នៅពេលដែលខ្មែរក្រហមបានឡើងកាន់អំណាចនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។ វក ទី មិនបានចាំថានៅពេលណាសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកបេ-៥២នៅក្នុងទឹកដីកម្ពុជាទេ ដែលរូបភាពនេះនៅតែដិតជាប់ក្នុងអារម្មណ៍របស់ជនរងគ្រោះដែលនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះ ។ អ្វីដែល វក ទី ចងចាំជារូបភាពស្រពេចស្រពិលនិងសំឡេងយន្តហោះដែលហោះទាបនឹងដីដែលធ្វើឲ្យមនុស្សនាំគ្នារត់គេចគ្រប់គ្នា ។

នៅពេលដែលបានសួរអំពីទស្សនៈរបស់ វក ទី ចំពោះសហរដ្ឋអាមេរិក វក ទី បាននិយាយថា គាត់មិនបានដឹងពីគោលនយោបាយរបស់សហរដ្ឋអាមេរិកទេសព្វថ្ងៃនេះទេ ឬក៏អ្វីដែលសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជាដែរ ។ ចំណុចមួយដែលគាត់ដឹងអំពីសហរដ្ឋអាមេរិក គឺជនជាតិអាមេរិកាំងដែលមកភូមិរបស់គាត់ ហើយបានសួរអ្នកភូមិរបស់គាត់អំពីស្ថានភាពរបស់នៅប្រចាំថ្ងៃ ។ ជនជាតិអាមេរិកាំងមួយចំនួនបានជួយបង្រៀនភាសាអង់គ្លេសនៅក្នុងភូមិរបស់គាត់ ហើយមានគម្រោងផ្តល់ជំនួយតូចៗមួយចំនួនទៀត ។ ឥឡូវនេះ ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជាកំពុងផ្តល់ជំនួយទៅកាន់សហគមន៍ អ៊ីមាំ សានរបស់គាត់ដើម្បីធ្វើការស្រាវជ្រាវគម្រោងតូចមួយលើភាសាប្រពៃណីចាមដើម ។ វក ទី បាននិយាយថា ជនជាតិអាមេរិកាំងភាគច្រើនដែលខ្ញុំបានជួប គឺសុទ្ធជាមនុស្សល្អ ដូច្នេះខ្ញុំចូលចិត្តសហរដ្ឋអាមេរិក ។

នៅក្នុងរបបរបបខ្មែរក្រហម វក ទី បានបាត់បង់បងស្រីម្នាក់ដែលត្រូវបានសម្លាប់បន្ទាប់ពីបានលួចហូបអាហារនៅខេត្តកំពង់ឆ្នាំង ។ វក ទី មិនបានដឹងទីតាំងដែលបានកប់សាកសពបងស្រីរបស់គាត់ឬព័ត៌មានដែលទាក់ទងនឹងការស្លាប់របស់បងស្រីគាត់ទេ ។ ព័ត៌មាននៃការស្លាប់របស់បងស្រីគាត់បានដឹងតាមរយៈអ្នកភូមិម្នាក់ដែលចិត្តល្អបានប្រាប់ដំណឹងដ៏សោកសៅដល់គ្រួសាររបស់គាត់ ។ ប៉ុន្តែ វក ទី នៅតែដឹងគុណព្រះអាឡាដែលសមាជិកគ្រួសាររបស់គាត់ដទៃទៀតនៅរស់រានមានជីវិតលើកលែងតែបងស្រីរបស់គាត់តែម្នាក់ប៉ុណ្ណោះដែលបានស្លាប់នៅក្នុងរបបនេះ ។ វក ទី មិនដែលបន្ទោសព្រះអាឡាពីការឈឺចាប់របស់គ្រួសារគាត់ ឬការស្លាប់របស់បងស្រីគាត់ទេ ប៉ុន្តែ វក ទី បានដឹងគុណចំពោះព្រះអាឡាដែលក្រុមគ្រួសាររបស់គាត់មិនបានជួបទុក្ខលំបាកខ្លាំងដូចគ្រួសារដទៃទៀតនៅក្នុងភូមិ ។ នៅមុនឆ្នាំ១៩៧៥ នៅភូមិចាន់គៀកមានប្រជាជន៦៣គ្រួសារ ក៏ប៉ុន្តែនៅឆ្នាំ១៩៩៩ នៅសល់តែ៣៣គ្រួសារប៉ុណ្ណោះដែលត្រឡប់មកភូមិវិញ ។ ជំនឿរបស់ វក ទី នៅក្នុងសាសនាអ៊ីស្លាមនៅតែមានដដែល ហើយកាន់តែខ្លាំងជាងកាលពីមុនរបបខ្មែរក្រហមទៅទៀត ។ មិនតែប៉ុណ្ណោះ អ្នកភូមិជាច្រើនទៀតក៏មានគំនិតដូចគាត់ដែរ ។ បងប្អូនអ្នកភូមិមើលឃើញថា ការឈឺចាប់នៅក្រោមរបបខ្មែរក្រហមកើតមានចំពោះគ្រប់ៗគ្នារួមទាំងអ្នកកាន់ព្រះពុទ្ធសាសនា គ្រិស្តសាសនា ហិនឌូនិងមូស្លីម ។ ដូច្នេះ ព្រះមិនបន្ទោសឡើយ ។

អ្នកភូមិចាន់គៀកជាច្រើនត្រូវបានជម្លៀសចេញពីលំនៅឋានរបស់ពួកគាត់នៅពេលដែលខ្មែរក្រហមបានឡើងកាន់អំណាចទាំងស្រុងនៅកម្ពុជា ។ អ្នកភូមិទាំងនោះត្រូវបានជម្លៀសទៅកន្លែងជាច្រើន ដោយមួយចំនួនទៅកាន់ភូមិខ្មែរ មួយចំនួនទៀតទៅកាន់ភូមិចាម ។ អ្នកភូមិភាគច្រើនត្រូវបង្ខំឲ្យហូបសាច់ជ្រូក ហើយស្ត្រីមិនអនុញ្ញាតអោយទុកសក់វែងឡើយ ។ លើសពីនេះទៅទៀត ពួកគាត់មិនត្រូវបានអនុញ្ញាតអោយនិយាយភាសាចាមឡើយ ។ បងប្អូនជនជាតិចាមត្រូវបានបង្ខំឲ្យប្តូរឈ្មោះចាមរបស់ពួកគាត់ទៅជាឈ្មោះខ្មែរវិញ ។ គម្ពីរកូរ៉ានត្រូវបានប្រមែ

ប្រមូលហើយដុតបំផ្លាញ ។ ទោះបីជាយ៉ាងណាក៏ដោយ បើតាមអ្នកភូមិស្ត្រីម្នាក់នៅភូមិនេះបាននិយាយថា កម្មាភិបាលខ្មែរក្រហមម្នាក់ក៏ធ្លាប់បានបង្ហាញពីការអនុវត្តតាមកាលៈទេសៈនៃមនោគមន៍វិជ្ជារបស់ខ្មែរក្រហមដែរ ។ កម្មាភិបាលខ្មែរក្រហមបានបង្ខំឲ្យស្ត្រីម្នាក់ហូបបាយជាមួយសាច់ជ្រូកដែលលាក់ទុកនៅក្នុងបាយនោះ ។ នៅពេលដែលគាត់ហូបបាយនោះហើយ គាត់បានបោះបាយចោលនៅមុខកម្មាភិបាលខ្មែរក្រហម ។ កម្មាភិបាលខ្មែរក្រហមបានគិតថា ការបោះបាយចោលបង្ហាញថាការមិនហូបសាច់ជ្រូកមិនគ្រាន់ជាជំនឿប៉ុណ្ណោះទេ ថែមទាំងបញ្ជាក់ថាចាមមិនអាចហូបសាច់ជ្រូកទៀត ។ ដូច្នេះហើយ កម្មាភិបាលខ្មែរក្រហមមិនដែលឲ្យគាត់ហូបសាច់ជ្រូកទៀតហើយ ។ ប្រុសៗមួយចំនួនបាននិយាយថា ជនជាតិចាមម្នាក់បានស្លាប់ដោយសារជំងឺនៅពេលដែលអ្នកភូមិម្នាក់នោះត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ។

នៅដើមឆ្នាំ១៩៧៥ គ្រួសាររបស់ វក ទី បានផ្លាស់ពីភូមិចាន់កៀកទៅកាន់ភូមិតូចមួយដែលមានចម្ងាយ១៥គីឡូម៉ែត្រស្ថិតនៅទិសខាងត្បូងឧត្តុង្គ ។ នេះជាលើកទីមួយហើយដែល វក ទី បានជួបខ្មែរក្រហម នៅពេលដែលខ្មែរក្រហមដង្ហែក្បួនចូលភូមិ ហើយបង្ខំឲ្យអ្នកភូមិចាកចេញពីភូមិ ។ វក ទី បានបន្តទៀតថា គ្រួសាររបស់គាត់និងគ្រួសារផ្សេងទៀតបានចាកចេញយ៉ាងប្រញាប់ប្រញាល់តាមផ្លូវលំលំបាកមួយ ដោយអ្នកភូមិបានដើរដង្ហែគ្នាជាមួយអីវ៉ាន់របស់ខ្លួន ។ គ្មាននរណាម្នាក់ហ៊ានដើរចេញពីភូមិឡើយ ពីព្រោះខ្មែរក្រហមនឹងបាញ់សម្លាប់ភ្លាមប្រសិនបើអ្នកភូមិប្រឆាំង ។ គ្រួសាររបស់ វក ទី ត្រូវបញ្ជូនទៅរស់នៅខេត្តកំពង់ចាម ។ វក ទី ត្រូវធ្វើការនៅក្នុងកងកុមារ ។ វក ទី ធ្លាប់បាននិយាយជាមួយកម្មាភិបាលខ្មែរក្រហម ហើយនិងឈ្លបភូមិនៅស្រែ ។ វក ទី បាននិយាយថា គាត់ខ្លាចខ្មែរក្រហម ក៏ប៉ុន្តែគាត់មិនដែលធ្លាប់ត្រូវខ្មែរក្រហមធ្វើបាបម្តងណាទេ ។ វក ទី បានឃើញក្មេងម្នាក់ដែលត្រូវបានធ្វើទារុណកម្មដោយយកថង់ប្លាស្ទិចមកគ្របក្បាលរបស់ក្មេងនោះ ហើយវាយរហូតដល់ក្មេងនោះស្ទើរតែសន្លប់ ។ ក្រោយមក ក្មេងម្នាក់នោះក៏បានបាត់ខ្លួន ។

ទោះបី វក ទី មិនបានទទួលការឈឺចាប់ខ្លាំងដូចជនរងគ្រោះនៃរបបខ្មែរក្រហមដទៃទៀតក៏ដោយ ក៏ វក ទី មិនអាចអត់ឱនទោសឲ្យមេដឹកនាំខ្មែរក្រហមដែរ ។ វក ទី ជឿជាក់ថា ស្ត្រីផ្សេងទៀតដែលគាត់បានស្គាល់ក៏មិនអាចអត់ឱនឲ្យមេដឹកនាំខ្មែរក្រហមដែរ ពីព្រោះអ្នកទាំងនោះបានបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់របស់ខ្លួន ។ វក ទី បាននិយាយថា «ការបាត់បង់សមាជិកគ្រួសារជារឿងដែលមិនអាចអត់ឱនឲ្យបានទេ» ។ វក ទី បានដឹងថាមានតុលាការសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនៅទីក្រុងភ្នំពេញតាមរយៈការផ្សព្វផ្សាយតាមអត្ថបទកាសែត វិទ្យុ និងកញ្ចក់ទូរទស្សន៍ ។ វក ទី ក៏បានឮផងដែរថា អ្វីដែលសាលាក្តីខ្មែរក្រហមធ្វើមានគោលបំណងជួយប្រជាជនឲ្យមានអារម្មណ៍ធូរស្រាលដែលជនរងគ្រោះទទួលបានផ្នែកខ្លះនៃយុត្តិធម៌ ក៏ប៉ុន្តែនឹងមិនទទួលយុត្តិធម៌ពេញលេញដែលជនរងគ្រោះគួរតែទទួលបានទេ ។ វក ទី បានបន្ថែមថា «យុត្តិធម៌គ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ។ ប្រសិនបើមេដឹកនាំខ្មែរក្រហមដែលកំពុងជាប់ឃុំឃាំងត្រូវបានដោះលែង នោះនឹងធ្វើឲ្យជនរងគ្រោះមានការអាក់អន់ចិត្តជាមិនខាន ។ ខ្ញុំចង់ឲ្យមេដឹកនាំខ្មែរក្រហមបន្តឃុំឃាំងរហូតអស់មួយជីវិត ។ **អេង កុកថាយ**

# ដំណឹងស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ ស៊ុន ភី មានអាយុ៤៣ឆ្នាំ រស់នៅភូមិគោកធំ ឃុំណាគាវ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ មានឪពុកឈ្មោះ ស៊ុន ហួ និង ម្តាយឈ្មោះ ធី ។ ខ្ញុំសូមប្រកាសស្វែងរកបងប្អូន៦នាក់ ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ៖ ១) បងប្រុស ស៊ុន ហួង ២) បងស្រី ស៊ុន រិន ៣) បងប្រុស ស៊ុន ពន្លក ៤) បងស្រី ស៊ុន នឿន ៥) ប្អូនប្រុស ស៊ុន ថៃ ៦) ប្អូនស្រី ស៊ុន ថុល ។ នៅឆ្នាំ១៩៧៦ រយៈពេលពីរទៅបីថ្ងៃក្រោយថ្ងៃដែលខ្មែរក្រហមចាប់ខ្លួនឪពុករបស់ខ្ញុំយកទៅ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ខ្ញុំទៅកាន់ព្រៃស ។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏បាត់ដំណឹងពីគាត់រហូត ដោយមិនដឹងថានៅរស់ឬក៏ស្លាប់ទេ ។

ប្រសិនបើបងប្អូនណាបានឃើញ ឬបានស្គាល់ សូមទាក់ទងមកអាសយដ្ឋានខាងលើ ឬតាមរយៈលេខទូរស័ព្ទ ០១២ ២៩០ ៨៨១ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 126, June 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.